01427318 E1/354.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ**

**សាធារណៈ – កោសលុប**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៣៣៥**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 29-Mar-2017, 08:50
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ែន
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ
លោក នីកូឡូ ប៉ុងស៍ *(Mr. Niccolo PONS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត
លោក ឌេល លីសាក់ *(Mr. Dale Lysak)*
លោក ត្រាវីស ហ្វារ *(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ
លោក លីវ សុវណ្ណា
លោក វ៊ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡេ្យា ជុនធី

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ឌុច ផារី | ខ្មែរ |
| លោក បាន សៀក (2-TCW-950) | ខ្មែរ |
| លោក សុះ រំលី (2-TCW-904) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក បាន សៀក ហៅ ហង្ស ផុស ហៅ ហង្ស ស៊ុនហួ** (2-TCW-950)

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី..........................................................................ទំព័រ ៣

ស្ួរដោយកញ្ញា អង់តា ហ៊្គីសសេ ផ្ដើមពី.................................................................ទំព័រ ៣២

សួរដោយលោក គង់ សំអុន ផ្ដើមពី ..........................................................................ទំព័រ ៦០

**ការសួរសំណួរទៅសាក្សី៖ លោក សុះ រំលី** (2-TCW-904)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ..............................................................................ទំព័រ ៦៤

# កិច្ចដំណើរការនីតិវិធី

[០៩:០៣:០០]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី បាន សៀក ហើយនិងមានសាក្សីបម្រុង 2-TCW-904 ហើយមេធាវីប្រឹក្សាសាក្សីនៅថ្ងៃនេះ គឺលោកមេធាវី ឌុច ផារី។

ក្រឡាបញ្ជីសវនាការលោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក បាន សៀក លោកមានវត្តមានរួចហើយជាមួយនឹងមេធាវីប្រឹក្សារបស់លោកនៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះដែរ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-904 សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោកហិតឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលនៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា

ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់ សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថាដោយគាតមានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និង មានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥។ បានឃើញកំណត់ហេតុ ពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជន ជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ បានកត់សម្គាល់ស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះមានអាការៈឈឺចង្កេះ ជាប្រចាំ និងមានសភាពខ្លាំង និងបានផ្តល់អនុសាសន៍ថា សូម អង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោម សាលសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

សូមអញ្ជើញលោកមេធាវី ឌុច ផារី!

**លោក ឌុច ផារី៖**

សូមគោរពឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម នៅក្នុងកិច្ចដំណើរការនីតិវិធី ថាតើខ្ញុំអាចសុំអនុញ្ញាតប្រើប្រាស់កុំព្យូទ័រផ្ទាល់ខ្លួនរបស់ខ្ញុំដើម្បីកត់ត្រាអ្វីដែលសំខាន់ សំណួរសំខាន់ៗបានដែរឬទេបាទ? សូមអរគុណលោកប្រធាន។

[០៩:០៧:៤៦]

**ប្រធានអង្គជំនុំ៖**

បាទមិនអីទេអង្គជំនុំជម្រះអនុញ្ញាត មិនមានបញ្ហាប្រឈមអ្វីនៅក្នុងដំណើរការសវនាការនេះទេ។

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិការជូនទៅក្រុមមេធាវីការពារក្តី ដើម្បីមានឱកាសសួរ

ដេញដោលចំពោះសាក្សីរូបនេះ។ ហើយជាដំបូងនេះផ្តល់វេទិការជូនទៅក្រុមសហមេធាវីការពារក្តី លោក ខៀវ សំផន -- អ៎! មេធាវីការពារក្តី នួន ជា!

**លោក វ៉ិចទ័រ កូប៉េះ**

បាទ សូមអរគុណលោកប្រធាន។

ជម្រាបសួរ លោក លោកស្រីចៅក្រម សហចៅក្រមទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ជម្រាបសួរលោក បាន សៀក ខ្ញុំជាសហមេ-- ខ្ញុំៗគឺជាមេធាវីអន្តរជាតិការពារក្តីលោក នួន ជា នឹងសួរសំណួរលោកខ្លះៗនៅព្រឹកនេះ។ ខ្ញុំនឹងសួរលោក សំណួរមួយចំនួនអំពីការបះបោរនៅស្រុកក្រូចឆ្មារ ក្រោយខែឧសភា ១៩៧៨ ប៉ុន្តែលោកក៏បានសួរអំពីបញ្ហានេះច្រើនដែរហើយកាលពីម្សិលមិញ។ តើលោកដឹងទេ បីឆ្នាំមុនឆ្នាំ៧៨ <គឺនៅក្នុងស្រុកដដែលហ្នឹង> ក៏មានការបះបោរនៅកោះផលនិងស្វាយឃ្លាំង <ហើយអាចនៅភូមិទ្រា>ផងដែរ។ តើលោកដឹងការបះបោរទាំងនោះទេ?

[០៩:០៩:៣៤]

**លោក បាន សៀក៖**

**ឆ៖** បាទ លោក ខ្ញុំបាទអត់ដឹងទេ ការបះបោរមុនពេលខ្ញុំទៅ ដល់ពេលខ្ញុំទៅអត់មានបងប្អូនអ៊ីស្លាមទេ មានបងប្អូនយុទ្ធជនខ្មែរខ្លះដែលមានការបះបោរនៅកន្លែងមួយនោះ។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលនិយាយតំបន់៤២ ក្នុងឆ្នាំ៧៦, ៧៧។ ខ្ញុំសូមអានសម្រង់ចេញពីសារទូរលេខមួយដែលចុះហត្ថលេខាដោយ កែ ពក ចុះខែមេសា ១៩៧៦។ លោកប្រធានឯកសារនេះគឺឯកសារ E3/952, ERN ជាភាសាអង់គ្លេស 00182658, ខ្មែរ <00000766> , បារាំង 00350762 ដល់ 63។ លោកសាក្សីដូចដែលខ្ញុំប្រាប់អម្បាញ់មិញ គឺថាជាសារទូរលេខពី កែ ពក ផ្ញើទៅប៉ុល ពត។ ខ្ញុំសូមអានសម្រង់ចេញពីសារទូរលេខនេះឲ្យលោកស្តាប់ ហើយសួរមើល៍ ថាតើលោកមានយោបល់ថាម៉េច។ "ស្ថានភាពខ្មាំង នៅតំបន់ឧត្តរទាំងមូល ជាមូលដ្ឋាន ខ្មាំងមិនទាន់បានធ្វើសកម្មភាពអ្វីខ្លាំងដែលធ្វើឲ្យប៉ះពាល់ប្រជាជន ក៏ដូចជាចលនាបង្កបង្កើនផលនៅឡើយទេ ជាៗទូទៅស្ថានភាពនឹងនរ តែទន្ទឹមនឹងនេះ វាមានការធ្វើសកម្មភាពខ្លះៗដែរ ដូចជាមានការឃោសនា<ថា>បដិវត្តន៍មានការតឹងតែង វាឃោសនា<ប្រឆាំងនឹងសហករណ៍ និងប្រព័ន្ធភ្លឺស្រែថ្មី។> ហើយក៏<វា>ធ្វើការឃោសនាថាមានការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អត់ឃ្លានដែរ ជាពិសេស<> សកម្មភាពខ្លះគឺកើតមាននៅស្រុកចំការលើ។ ពួកអាខ្មាំងជាទាហានចាស់រួមផ្សំជាមួយពួកចាម និង<អតីតប្រធាន>ពួក<សហករណ៍។> គេប្រើរូបថតចម្លងរបស់ លន់ នល់ <និង>សេចក្ដីថ្លែងការណ៍<របស់ លន់ នល់> ថ្ងៃទី១៨ មីនា ៧០ <ហើយបិតនៅលើដើមឈើ>នៅ<ជិត>ភូមិត្រពាំង<> ស្រុកចំការលើ ហើយក៏មានធ្វើសកម្មភាពខ្លះដូចជា ដុតព្រៃ បំផ្លិចបំផ្លាញដំណាំដូចជា ចេក ល្ហុង<>។" លោកសាក្សីនៅពេលនោះ ឬក៏ថាក្រោយមកទៀត <ប្រហែល>នៅក្នុងឆ្នាំ១៩៧៧ លោកដឹងអំពីសកម្មភាពទាំងអស់នេះ ដែលបានរៀបរាប់នៅក្នុងសារទូរលេខនេះដែរទេ?

**ឆ៖** បាទលោក ខ្ញុំបាទអត់ដឹងទេ ព្រោះកាលដល់ឆ្នាំ៧៧ ទាល់ចុងឆ្នាំបានខ្ញុំមកគីឡូនេសាទមកលោក។

[០៩:១៣:៣៨]

**ស៖** ប៉ុន្តែសកម្មភាពមួយចំនួន ដូចជាដុតព្រៃចោល ដែលធ្វើឡើងដោយចាម ហើយនិងទាហានមួយចំនួននោះ លោកដឹងទេ គឺសកម្មភាពទាំងអស់នេះ លោកដឹងទេ មកដល់ឆ្នាំ៧៧ ឬក៏ក្រោយ៧៧មកទៀត លោកដឹងដែរទេ?

**ឆ៖** បាទលោក ខ្ញុំបាទអត់ដឹងទេ។

**ស៖** លោកបានផ្ដល់សក្ខីកម្មពីម្សិលមិញ ឆ្លើយទៅនឹងសំណួរ អំពីការបោសសម្អាតកម្មាភិបាលនៅអតីតភូមិភាគឧត្តរ ហើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក លោកថាគេបោសសម្អាតថ្នាក់ដឹកនាំ មានន័យថាអ្នកដែលជាប់ពាក់ព័ន្ធជាមួយ សេ.អ៊ី.អា។ តើលោកចង់មានន័យថាម៉េចនៅពេលដែលលោកនិយាយថា មានជាប់ពាក់ព័ន្ធ មានជាប់ទាក់ទង ជាមួយនឹងខ្សែ សេ.អ៊ី.អា នោះ?

**ឆ៖** បាទលោក ខ្ញុំបាទបានដឹងតាមបងៗដែលធ្វើការនៅតំបន់ដូចជាអួន អឿន អីគាត់ប្រាប់ថានៅក្នុងភូមិភាគយើងគឺថា ធុច ជាមេសេ.អ៊ី.អា។ ដូច្នេះគេបោសតាំងពីលើដល់ក្រោម។ ដល់កម្មាភិបាលបក្សជនហ្នឹង សម្ព័ន្ធយុវជននិងជនបង្គោល បើនិយាយប៉ុណ្ណឹងទៅទាំងអស់ ឲ្យតែប្រធានក្រុមឡើងទៅអស់ទាំងអស់បាទ។

**ស៖** ជាការពិត<លោកបានយល់នៅពេលនោះ>ហើយ<ថា> អឿន <>មិនមែន<ចង់និយាយ>ថា <កុយ ធួន> ជាមេ សេ.អ៊ី.អា ទេ ពីព្រោះ<យើងទាំងអស់គ្នាដឹងហើយ>ថា សេ.អ៊ី.អា នេះជាអង្គការចាត់តាំងមួយរបស់អាមេរិក។ តើ<អឿន>ចង់មានន័យថាម៉េច<>នៅពេលដែល<គាត់>និយាយថា កុយ ធួន នេះជាមេ សេ.អ៊ី.អា?

**ឆ៖** បាទ គាត់ថាចម្លើយ សេ.អ៊ី.អា ដូចជាក្រោយមកចាប់ ជ័យ របស់ប្អូនថ្លៃរបស់ អឿន ហ្នឹងក៏ថា សេ.អ៊ី.អា ដែរបាទ។

**សៈ** នៅក្នុងចម្លើយមួយនៃកំណត់ហេតុស្តាប់ចម្លើយលោកឆ្លើយថា កុយ ធួន ជាមេ សេ.អ៊ី.អា ហើយ សោម ភឹម ជាមេ កា.ហ្សេ.បេ <នៅភូមិភាគបូព៌ា>។ <ឥឡូវ> យើងដឹង<ទាំងអស់គ្នា> ហើយថា កា.ហ្សេ.បេ នេះគឺជាអង្គការចាត់តាំងមួយរបស់<សហភាព>សូវៀត ហើយយើងដឹង<> សោម ភឹម <គឺមិនមែនជាជនជាតិរុស្ស៊ីទេ>។ តើលោកចង់និយាយថាម៉េចនៅពេលដែលលោកនិយាយថា សោ ភឹម នេះ ជាមេរបស់ កា.ហ្សេ.បេ នៅភូមិភាគបូព៌ា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[០៩:១៧:១៩]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

សូមឲ្យមេធាវីផ្តល់លេខឯកសារ និងលេខERN មុននឹងយកសម្រង់នេះមកសួរខ្ញុំ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំយោងទៅលើឯកសារ E3/375, អង់គ្លេស ERN 00360757, បារាំង 00369919 និងខ្មែរ 00348797 ដល់ 98 <ហើយឯកសារនេះបានសរសេរ>ថា៖ "<ពួក>គេទើបតែប្រាប់យើងថា កុយ ធួន ហៅ ធុច <គឺ>ជា<មេ> សេ.អ៊ី.អា <>ហើយ សោ <យ៉ាន> ហៅ ភឹម នេះ ជាមេ កា.ហ្សេ.បេ នៅភូមិភាគបូព៌ា។" <លោកសាក្សី ឥឡូវនេះ ដូចខ្ញុំនិយាយអ៊ីចឹង សោ ភឹម មិនមានជាជនជាតិរុស្ស៊ីទេ ហើយគាត់ក៏មិនមែនជាមេ>កា.ហ្សេ.បេ <តើនៅពេលនោះ>លោកយល់ថា<វាមានន័យ>ដូចម្តេចដែរចំពោះ<រឿង>នេះ?

**លោក បាន សៀក៖**

**ឆ៖** បាទលោក ខ្ញុំបាទអត់យល់ទេ ព្រោះគ្រាន់តែដាក់ផ្លាកខ្មៅតាមជុំវិញកន្លែងធ្វើការមួយ គេដាក់ កា.ហ្សេ.បេ និង សេ.អ៊ី.អា។ កា.ហ្សេ.បេ ផ្អែបម្រើអាមេរិកាំង -- សេ.អ៊ី.អា ផ្អែបម្រើអាមេរិកាំង, កា.ហ្សេ.បេ ជាផ្អែបម្រើយួន។

[០៩:១៩:០៣]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** លោកនិយាយថា កា.ហ្សេ.បេ ឬក៏ សេ.អ៊ី.អា គឺថាមានន័យថា គឺជាការសហការជាមួយអាមេរិកាំង និងជាការសហការជាមួយវៀតណាមអ៊ីចឹង លោកចង់និយាយថាអ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** បាទ លោក។

**ស៖** ឥឡូវនេះ ខ្ញុំចូលនិយាយដល់តំបន់៤២ តែម្តង។ មុនពេល<ដែល>សាច់ថ្លៃរបស់លោក <ឈ្មោះ> អឿន ក្លាយទៅជាមេតំបន់៤២ តើលោកដឹងថាអ្នកណាជាអ្នកកាន់តំណែងប្រធានលេខាតំបន់៤២ មុន អឿន ទេ?

**ឆ៖** បាទលោក ខ្ញុំបាទអត់ដឹងទេទាន។

**ស៖** ចុះបើខ្ញុំនិយាយពីឈ្មោះមនុស្សម្នាក់ ឈ្មោះ តុល តើលោកនឹកឃើញទេ?

**ឆ៖** បាទ ខ្ញុំបាទនឹកឃើញ តុល នៅភូមិបាក់ស្នា ឃុំបាក់ស្នា បាទ។

**ស៖** តើគាត់ជាប្រធានតំបន់៤២ រហូតដល់គេចាប់ខ្លួនគាត់ក្នុងឆ្នាំ១៩៧៧ មែនទេ?

**ឆ៖** បាទលោក ខ្ញុំបាទអត់ដឹងទេទាន។

**ស៖** ម្សិលមិញលោកនិយាយពីឈ្មោះ អឿន ដែលជា<ប្អូនប្រុសបង្កើត>របស់ឈ្មោះ ស៊ូ សឿន នេះដែលលោកថាស្លាប់ដោយសារជំងឺអេតដ៍។ <>អឿន គឺថាជា<លេខាតំបន់៤២។ តើលោកនៅចាំឈ្មោះ> អឿន មួយទៀត<បានទេ?> គឺ<ឈ្មោះ អឿន ដែលជា>ប្រធាន<កងពលធំ>៣១០ ដែល<ចំណុះឲ្យ>អតីតភូមិភាគ ឧត្តរចាស់នេះ ដែរ<ឬ>ទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ បាទ។

**ស៖** ចុះលោកចាំអ្វីខ្លះដែលអំពី កុយ ធួន? <តើគាត់ជានរណា?> តើគាត់មានមុខងារជាអ្វី? ហើយ<ចុងក្រោយ> ហេតុអីបានជាគេចាប់ខ្លួនគាត់?

**ឆ៖** បាទ ខ្ញុំបាទអត់ចាំទេ។ គ្រាន់តែគាត់ប្រាប់ថា កុយ ធួន ជាប្រធានភូមិភាគកណ្តាល ហើយក្រោយមកទៅជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បាទ។

**ស៖** <ក្រៅពីធ្វើជា> “មេ សេ.អ៊ី.អា” តើលោកយល់ថាគាត់ធ្វើអ្វីខុស? បាទ មូលហេតុដែលតើលោកយល់ថាគាត់បានប្រព្រឹត្តអ្វីខុសដែលនាំឲ្យមានការចាប់ខ្លួនគាត់?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ។

**ស៖** ម្សិលមិញ លោក<ត្រូវបានសួរផ្ទៀង>ជាមួយនឹងសម្រង់មួយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់កូនប្រុស កែ ពក ឈ្មោះ កែ ពេជ្រវណ្ណៈ គឺឯកសារ E3/35, ERN អង់គ្លេស

00346148, ខ្មែរ<00340562 ហើយបារាំង>--

**អ្នកបកប្រែ៖**

សូមការអនុញ្ញាតម្តងទៀត លោកប្រធាន។ ញាប់ពេកតាមអត់ទាន់។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី បង្ហាញអត្តសញ្ញាណលេខឯកសារឡើងវិញ ព្រោះអ្នកបកប្រែបកមិនទាន់ទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអភ័យទោសលោកប្រធាន។ ខ្មែរ ERN 00340562, បារាំង 00367720។ កូនប្រុសរបស់ កែ ពក និយាយអំពី កុយ ធួន ហើយក៏និយាយអំពីមេបញ្ជាការកងពល៣១០ ឈ្មោះ អឿន។ សូមដកស្រង់៖ " អុំ អឿន ជាប្រធានកងពល១ ហើយក៏ជា<អតីតអ្នកជំនិត និង>នីរសាររបស់<លោកតា> ធុច។" <ឥឡូវនេះ> ខ្ញុំ<ទើបតែ>ដឹងថាលោក<បាននិយាយថាលោក>មិនស្គាល់<ឈ្មោះ> អឿន មួយផ្សេងទៀតទេ។ <ប៉ុន្តែ តើ>លោក<មានស្គាល់នរណាដែលជាប្រធានកងពល១ ហើយជាអតីតអ្នកជំនិត និង>ជានីរសាររបស់ កុយ ធួន ដែរទេ?

**ឆ៖** បាទលោក ខ្ញុំបាទអត់ស្គាល់ទេ។

[០៩:២៥:២៥]

**ស៖** នៅក្នុងខែមិថុនា ២០១៥ គឺថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥ នៅក្នុងបន្ទប់សវនាការនេះ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្ម<យុទ្ធជន>ម្នាក់មកពីកងពល៣១០ ឈ្មោះ សែម ហឿន គឺឯកសារ E1/319 នៅថ្ងៃនោះ នៅម៉ោងប្រហែលជា១៥:៣៤, សែម ហឿន បានផ្តល់សក្ខីកម្មដូចតទៅ ខ្ញុំសូមអានសក្ខីកម្មរបស់គាត់ <ហើយខ្ញុំសួរពីប្រតិកម្មរបស់លោក>៖ "សួរ៖ ខ្ញុំសុំចាប់ផ្តើមជាមួយតួនាទីរបស់លោកក្នុងការបះបោរ លោកនិយាយថា អឿន បានឱ្យលោកដឹកនាំកង<អនុសេនា>តូច <ហើយឱ្យឡានធំចំនួន៥៥ ដើម្បី>ដឹកកាំភ្លើង<>ទៅ<លាក់ទុកនៅ>កំពង់ចាម<។> តើលោកធ្វើតាមការបញ្ជាឱ្យគាត់ដឹកអាវុធយកទៅលាក់នៅកំពង់ចាមនោះទេ? ចម្លើយ៖ ខ្ញុំបានធ្វើតាមការបញ្ជារបស់គាត់។ សួរ៖ តើលោកលាក់កាំភ្លើងទាំងនោះនៅឯណា នៅកំពង់ចាមហ្នឹង? ឆ្លើយ៖ ខ្ញុំដឹកកាំភ្លើងទាំងនោះទៅកំពង់ចាម ហើយខ្ញុំប្រគល់ទៅឱ្យ តុល ដែលជាសមាជិកគណ:<>តំបន់<នោះ។> ខ្ញុំមិនដឹងថាគាត់លាក់អាវុធទាំងនោះនៅកន្លែងណាទេ។" លោកសាក្សី <ឥឡូវ> សែម ហឿន <នេះ> បានផ្តល់សក្ខីកម្មជូនតុលាការ<អំពីរឿងផ្សេងៗទៀតជាច្រើន។ គឺថាសំដៅទៅរក>ការប្រមូលអាវុធយកទៅលាក់

ទុក ដើម្បីធ្វើការបះបោរនៅភូមិភាគឧត្តរ ដែលដឹកនាំដោយ ត្រូវដឹកដោយ កុយ ធួន និងមេបញ្ជាការកងពលឈ្មោះ អឿន ហើយនិង តុល ហើយមនុស្សមួយចំនួនទៀត។ នៅពេល ខ្ញុំអានចម្លើយនេះឲ្យលោកស្តាប់ តើលោកនឹកឃើញអំពីការសកម្មភាពទាំងអស់នេះដែរទេ នៅក្នុងតំបន់៤២ នាពេលនោះ?

[០៩:២៧:៤៣]

**ឆ៖** បាទលោក ខ្ញុំបាទអត់ដឹងទេ ព្រោះនៅឡើតនៃសាទ ជាយុវជនអត់ដឹងទេលោក។

**ស៖** បាទ ខ្ញុំយល់ហើយ ប៉ុន្តែក្រោយមកទៀត លោកក៏បានឡើងបុណ្យស័ក្តិរហូត លោកជិតដិតជាមួយ កែ ពក, ជាមួយ អឿន<។> តើអ្នកទាំងនោះមានប្រាប់លោកអំពីអ្វីដែលបានកើតឡើងនៅក្នុងឆ្នាំ១៩៧៧ នៅអតីតភូមិភាគឧត្តរទេ? ហើយហេតុអ្វីបានជាមានការចាប់ខ្លួនមនុស្សទេ <ឧទាហរណ៍> នៅក្នុងស្រុក គឺស្រុកចំការលើនេះ ដែលក្រោយមកលោកក្លាយជាអនុលេខាស្រុកចំការលើនេះ។ តើ<> អ្នកទាំងនោះមានប្រាប់លោកពីសកម្មភាពទាំងនេះដែរទេ?

**ឆ៖** បាទលោក ប្រាប់ ប្រាប់អំពីភូមិភាគឧត្តរ ភូមិភាគកណ្តាលហ្នឹង វាសុទ្ធតែពួក សេ.អ៊ី.អា ដែលគេចាប់សុទ្ធតែ សេ.អ៊ី.អា។

**ស៖** ហើយតើសកម្មភាពទាំងអស់នោះមានបំណងយ៉ាងម៉េចដែរ <> គឺសកម្មភាពរបស់ "<ភ្នាក់ងារ> សេ.អ៊ី.អា"?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងសកម្មភាពរបស់គេទេបាទ។

**ស៖** តើលោកមានបានដឹងថា ពួកគេព្យាយាមធ្វើរដ្ឋប្រហារ វាយប្រហារព្រលានយន្តហោះពោធិ៍ចិនតុង បិទស្ថានីយ៍វិទ្យុ បញ្ជូនកងទ័ពមកកាន់ទីក្រុងភ្នំពេញ លោកធ្លាប់ឮអំពីសកម្មភាពទាំងនេះទេ?

[០៩:២៩:៥១]

**ឆ៖** បាទ ឮ គេថាទូស្សេនៅក្នុងអាវ បិតឡេវហើយទៅដល់ភ្នំពេញ ហើយគេចាប់អស់។

**ស៖** សូមលោកបញ្ជាក់ឲ្យបានលម្អិតបន្តិចមើល ក្រៅពីការលាក់អាវុធ ឬក៏គ្រាប់រំសេវហ្នឹង ក្រៅសកម្មភាពពីរនេះ លោកអាចបញ្ជាក់សកម្មភាពផ្សេងៗទៀតឲ្យបានលម្អិតបន្តិចបានទេ?

**ឆ៖** បាទ ដូចខ្ញុំបាទគ្រាន់តែដឹងថា អ្នកបះបោរខាងភ្នំពេញទេ គេនិយាយអ្នកភ្នំពេញហ្នឹងទាហានហ្នឹង ពាក់អាវុធ ដាក់លាក់អាវុធ ដាក់ទុស្សេក្នុងអាវ ហើយជិះឡានទៅសំដៅទៅភ្នំពេញ។ អត់ដឹងរឿងអីទេពួកហ្នឹងនោះ។ ស្រាប់ទៅដល់ហ្នឹង ស្រាប់ភ្នំពេញគេដឹង គេកាក់ឡាន ចាប់អស់រលីងទៅ។ រួចដល់ហ្នឹង គេថាពួកហ្នឹង ការបោះបោររបស់ កុយ ធួន គឺបោះបោរធ្វើរដ្ឋប្រហារ ប៉ុល ពត បាទ។

**ស៖** តើលោកដឹងថា <ការ>ព្យាយាមធ្វើរដ្ឋប្រហារ<របស់ កុយ ធួន ត្រូវបានលាតត្រដាងឲ្យដឹងដោយរបៀបណា? តើពួកគេមានគម្រោងអ្វីខ្លះ?> តើលោកដឹងថាសកម្មភាពពិតប្រាកដមែនទែន ជាសកម្មភាពអ្វីខ្លះដែរ?

**ឆ៖** បាទលោក ខ្ញុំបាទអត់ដឹងទេទាន។

**ស៖** លោកសាក្សី កាលពីម្សិលមិញលោកបាននិយាយអំពីអង្គភាពមួយហៅថា "បក្សពលករ"។ ហើយកំណត់ហេតុស្តាប់ចម្លើយរបស់លោកជូនសហចៅក្រមស៊ើបអង្កេត <លោក>និយាយអំពីបក្សពលករនេះដែរ។ ឥឡូវ ខ្ញុំសូមយកសម្រង់ឲ្យចំតែម្តងមកអានឲ្យលោកស្តាប់។ ឯកសារ E3/375, ERN ជាភាសាអង់គ្លេស <00360757>, បារាំង 00369919, ខ្មែរ 00348798 នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លោកបានឆ្លើយថា៖ "សួរ៖ ហេតុអ្វីបានពួកគេត្រូវបានចាត់ទុកថាជា សេ.អ៊ី .អា និង កា.ហ្សេ.បេ?" ហើយចម្លើយរបស់លោកនោះ "ខ្ញុំគិតថា នៅពេលនោះ បញ្ហាដែលបណ្តាលឲ្យមានការកើតចលាចលគឺមកពីមានបក្សចំនួនបី។ ទី១ គឺបក្សកុម្មុយនីស្តកម្ពុជា ដើរតាមមាគ៌ាម៉ៅសេទុង។ ទី២ បក្សសេរីកា គឺសេ.អ៊ី.អា និងទី៣ បក្សពលករ<> គឺកា.ហ្សេ.បេ នេះឯង"។ ហើយកាលពីម្សិលមិញយោងទៅតាមសេចក្តីព្រាងប្រតិចារឹក លោកបានឆ្លើយថា លោកបានឆ្លើយនូវប្រហែលជាម៉ោង១៥:២០ "តាមដែលខ្ញុំដឹង នៅទីតាំងរបស់ខ្ញុំមានកម្មាភិបាលដែលទទួលការបណ្តុះបណ្តាលនៅវៀតណាម គេជាផ្នែកមួយនៃ<>បក្សពលករ ហើយនៅពេលវៀតណាមចូលមកកាន់កម្ពុជា គឺថាគេ<ជាផ្នែកនៃកងកម្លាំងដែល>មានលទ្ធភាពកសាងកម្លាំងប្រដាប់អាវុធនៅនឹងកន្លែង <ហើយក្រោយពួកនេះត្រូវបានគេបោសសម្អាត>"។ លោកនិយាយអំពីបក្សពលករនេះពីរដង។ តើលោកដឹងថា បក្សពល-ករនេះជាអ្វីដែរ? ហើយអ្នកណាជាសមាជិករបស់បក្សពលករ?

[០៩:៣៤:២៥]

**ឆ៖** បាទលោក បញ្ហាបក្សពលករ គឺថាពួក កា.ហ្សេ.បេនេះ ជាបក្សពលករ។ បក្សពលករ គឺបក្សឥណ្ឌូចិន គឺចូលខាងវៀតណាម។ ដូច្នេះពួកហ្នឹង ដែលសំខាន់មេធំជាងគេ គឺនៅបូព៌ា សោ យ៉ាន ហៅ ភឹម ហើយបន្ទាប់មក ខ្ញុំអត់ស្គាល់ទេ ឮសួរគេហៅថាអ៊ីចឹង ព្រោះថាគេសម្លាប់ខ្លួនឯងនៅនឹងបូព៌ា។ ឯក្រោយមក បានទៅជារឿងផ្ទុះឡើងដោយបងៗហ្នឹង បានផ្តាច់ខ្លួនទៅចូលទៅវៀតណាមទៅបង្កើតជាអ៊ីចឹងទៅ បាទ។

**ស៖** លោកបានឆ្លើយថា សោ ភឹម ជាមេបក្សពលករ។ ចុះលោកមានស្គាល់សមាជិកគណៈ

អចិន្ត្រៃយ៍ ឬក៏ថាសមាជិកសំខាន់ៗដទៃទៀតនៅក្នុងបក្ស<ពលករកម្ពុជា>នេះដែរទេ?

**ឆ៖** បាទ លោក ខ្ញុំអត់បាទអត់ស្គាល់ទេ។

**ស៖** លោកដឹងទេថា បក្សពលករត្រូវបានបង្កើតឡើងនៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំដឹងតាម កែ ពក គាត់បានថា គាត់ពីដើមក៏បក្សពលករដែរ ប៉ុន្តែគាត់ចូលបក្សកុម្មុយនីស្តកម្ពុជាមក បានអត់មានបញ្ហាអី។ បក្សពលករនេះ ការតស៊ូតាំងពី តាមខ្ញុំដឹង៦៧-៦៨ ខ្ញុំដឹងទេ បាទ ៦៧-៦៨ហ្នឹង គេធ្វើការតស៊ូ ហើយចេញជាបក្សកុម្មុយនីស្តហើយបាទ។ ហើយនេះបក្សពលករមកចូលបក្សកុម្មុយនីស្តវិញបាទ។

[០៩:៣៦:៤១]

**ស៖** ធ្វើម៉េចបានជាលោកដឹងថាបក្សពលករបង្កើតឡើងនៅឆ្នាំ១៩៦៧<>? លោកទទួលបានប្រភពព័ត៌មាននេះមកពីណា?

**ឆ៖** បាទ កាលនោះ កែ ពក គាត់និយាយរឿងរ៉ាវអង្កាល់ពីគាត់ចូលព្រៃនៅឆ្នាំ៥៣-៥៤ ហើយដឹង។ គាត់និយាយថាការតស៊ូនៅក្នុងព្រៃ អាហ្នឹងគាត់និយាយថាបក្សពលករការធ្វើការហ្នឹងនោះ។ រួចដល់ពេលក្រោយបានគាត់ទៅចូលបក្សកុម្មុយនីស្តទៅ គាត់អត់មានមកខាងបក្សពលករទេ បាទ ដឹងតាមគាត់ គាត់និយាយប្រាប់មកអីចឹង ខ្ញុំសួរគាត់។ សួរគាត់ថា ម៉េចបានជារឿងប្រទេសដល់អីចឹងបង? គាត់មកផ្ទះម្តងហ្នឹងសួរគាត់ទៅ គាត់ថា មិត្តឯងមិនដឹងទេ រឿងហ្នឹងធំធេងណាស់ណា។ បើសិនជាណាបងមានរឿងអីចឹងក៏មិនស្រួលដែរ ប៉ុន្តែបងចូលទៅបក្សទុកចិត្ត មិនធ្វើអីទេ ភូមិភាគកណ្តាលនៅសល់តែបងម្នាក់ឯងហ្នឹង គ្មានសល់ទេ។ ខ្ញុំថាចុះប្អូន អឿន? អឺ! អឿន ពីដើមនៅសៀមរាបហ្នឹង ទើបយកមកនេះគេកើតរឿងហើយហ្នឹង។ ខ្ញុំដឹងប៉ុណ្ណឹងលោក។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារ E3/375 នៅពេលដែលលោកនិយាយពីឈ្មោះបក្សពលករ<,> កា.ហ្សេ.បេ <ខ្ញុំសូមដកស្រង់៖ “>បើសិនណាជាចង់ដឹងលម្អិត<ជាងនេះ> គឺ<លោកអាច>សួរ មឿន <បាន ដែល>សព្វថ្ងៃ<រស់នៅ និង>លក់សាំងនៅអន្លង់វែង<ហើយ>ជាប្រពន្ធ ពេជ្រ ជាង ហៅ តាចូ អតីតឯកអគ្គរដ្ឋទូតប្រចាំប្រទេសចិននៅសម័យកម្ពុជាប្រជាធិបតេយ្យ។” ហេតុអីក៏លោកនិយាយថា បើចង់ដឹង<ព័ត៌មានលម្អិតសូម>សួរ មឿន នោះ មឿន អាចនិយាយប្រាប់លម្អិត<ជាងលោក>អំពីបក្សពលករ?

**ឆ៖** បាទ ព្រោះគាត់អ្នកធំដែរ ប្តីគាត់ធ្វើទូតហើយ គាត់ដឹងរឿងទាំងអស់ ព្រោះការងារទូត។

**ស៖** តើខ្លួនលោកផ្ទាល់ដែលនិយាយទៅកាន់ មឿន អំពីពក្សពលករនេះដែរទេ ហើយតើ <គាត់>មានបាននិយាយគ្នាលម្អិតអំពីអត្ថិភាពនៃបក្សពលករ និងគោលបំណងនៃបក្សពលករនេះទេ?

**ឆ៖** បាទ អត់ដែរទេលោក។

**ស៖** លោកដឹងទេ សព្វថ្ងៃនេះ មឿន នៅរស់រានមានជីវិត ឬក៏យ៉ាងណាដែរ?

**ឆ៖** ឥឡូវខ្ញុំអត់ដែលឃើញទេពីរបីឆ្នាំនេះ ព្រោះមុនឃើញគាត់នៅហ្កាវ៉ាសសាំងនៅមុនវត្ត អន្លង់វែងបាទ។

[០៩:៤០:០០]

**ស៖** តាមរយៈការបកប្រែ លោក<ហៅ>ថា មឿន ថាគាត់ៗ "ហ៊ី" ប៉ុន្តែតាមពិត មឿន ស្រីទេ អ៊ីចឹង ឬក៏យ៉ាងណា លោក?

**ឆ៖** បាទ បងមឿន គឺស្រីទេ ប្រពន្ធរបស់ ពេជ្រ ជាង ហៅ ថូ ទូតចិនបាទ។

**ស៖** លោកសាក្សី កាលពីម្សិលមិញ លោកបាននិយាយឡើងអំពីឈ្មោះ ហេង សំរិន ពីរបីដង ហេង សំរិន និង ជា ស៊ីម។ តើលោកអាចនិយាយ ជម្រាបជូនតុលាការបានទេ ហេង សំរិន ជាអ្នកណាដែរ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ គ្រាន់តែឮគេថា ទៅធ្វើការហើយ ថា ហេង សំរិន ហ្នឹងជាប្រធានយោធាភូមិភាគបូព៌ាបាទ។ សម្តេច ជា ស៊ីម ជាប្រធានតំបន់២២ កាលហ្នឹង គេប្រាប់អ៊ីចឹង បាទ។

**ស៖** ខ្ញុំនឹងសួរលោកអំពី ជា ស៊ីម បន្តិចទៀតនេះ។ ប៉ុន្តែខ្ញុំចង់សួរលោកឲ្យបានច្រើនបន្តិចអំពី ហេង សំរិន លោកថាគាត់ជាមេបញ្ជាការកង<ទ័ព>នៅភូមិភាគបូព៌ា។ តើលោកដឹងទេ ថាគាត់នេះបានក្លាយទៅជាមេបញ្ជាការកងទ័ពភូមិភាគបូព៌ាពីពេលណាមកដែរ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ។

**ស៖** ចុះលោកដឹងអ្វីខ្លះទៀតដែរ អំពី ហេង សំរិន?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ។

**ស៖** តើលោកដឹងថាគាត់មានប្អូនស្រី<ម្នាក់>ដែលរៀបការជាមួយលេខាតំបន់២១ ឈ្មោះ <តូច ថែម ហៅ សុទ្ធ> លោកដឹងទេ?

[០៩:៤៣:០១]

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ។

**ស៖** កូនប្រុស កែ ពក ក៏បាននិយាយអំពី ហេង សំរិន ដែរ គឺឯកសារ E3/35, ERN អង់គ្លេស 00346153, ខ្មែរ 00340567 និងបារាំង 00367725។ កូន កែ ពក ក៏បាននិយាយស្របគ្នាជាមួយនឹងលោកដែរ ថាគាត់ជាមេបញ្ជាការកង<ពល>ភូមិភាគបូព៌ា ហើយគាត់ក៏និយាយថា ហេង សំរិន នេះ គឺជាប្រធានតំបន់២០ នៃភូមិភាគបូព៌ា។ តើលោកអាចបញ្ជាក់រឿងនេះបានទេ ឬក៏លោកមិនដឹងទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ ទាន។

**ស៖** ឥឡូវនេះ ខ្ញុំ<សូមអានឲ្យលោកស្ដាប់>--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[០៩:៤៤:៤៣]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឲ្យមេធាវីការពារក្ដីនេះ ចង្អុលបង្ហាញឲ្យច្បាស់មើល៍ កូនប្រុស កែ ពក និយាយកន្លែងណាថា ហេង សំរិន ជាមេបញ្ជាការកងទ័ពភូមិភាគបូព៌ា<>នោះ<។> <ពីព្រោះ>ខ្ញុំក៏មិនបាន<មើលឃើញកំណត់ហេតុមួយណាដែល>ថា គាត់នេះគឺជាប្រធានតំបន់២០ <និងជាប្រធានកងពលទេ>។ ដូច្នេះ ខ្ញុំរីករាយណាស់ប្រសិនណាបើមេធាវីចង្អុលបង្ហាញឲ្យចំកន្លែងដែលកូន កែ ពក ហ្នឹង និយាយហ្នឹងមើល៍។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺ<ខ្ញុំយោងទៅលើ>ឃ្លាតែមួយ<ដែលដូចគ្នាបេះបិទ។ នេះជាវិធីដែលខ្ញុំបកស្រាយ>ចម្លើយ<របស់កូនប្រុស កែ ពក។> ហេង សំរិន ខ្លួនគាត់ផ្ទាល់<ក៏បានទទួលស្គាល់នៅក្នុងចម្លើយរបស់គាត់> ថាគាត់គឺជាអនុប្រធានកងទ័ពនៃភូមិភាគបូព៌ាទាំងមូលតែម្ដង។ <ដូច្នេះ គាត់អាចជាប្រធាន ឬជាអនុប្រធាន បើតាមការនិយាយរបស់គាត់ផ្ទាល់។> ឥឡូវនេះ<យើងត្រឡប់មក>និយាយ<អំពី ហេង សំរិន វិញ>--

**ប្រធានអង្គជំនុំ៖**

អំមិញនេះ ចង់បញ្ជាក់ពីអត្តសញ្ញាណឯកសារ ហើយនិងលេខ ERN ដែលចង្អុលបង្ហាញចំណុចនោះឲ្យច្បាស់លាស់។ ហើយលោកដូចព្យាយាមជៀសពីបញ្ហាការបង្ហាញឲ្យច្បាស់លាស់ ទី១ គឺម្សិលមិញលោកតវ៉ាច្រើនអំពីភាគីម្ខាងទៀតសួរ សំណួរចាកចេញផុតពីអង្គហេតុ ការប្រព្រឹត្តចំពោះជនជាតិ

ចាមម្តងហើយម្តងទៀត នៅពេលលាតត្រដាងផុតពីអង្គហេតុពាក់ព័ន្ធ។ ឥឡូវនេះ លោកដើរតាមអ្វីដែលលោកចង់ធ្វើដោយខ្លួនឯង។ ទី២ គឺលោកមិនឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាទេ ដែលបង្ហាញចំណុចពាក់ព័ន្ធដោយបង្ហាញនូវកថាខណ្ឌ នូវលេខ ERN ច្បាស់លាស់ជៀសវាងការដកស្រង់មិនត្រឹមត្រូវ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន <>ខ្ញុំ<ទើបតែ>បានផ្តល់<លេខ>ឯកសារ និង ERN<។> ប៉ុន្តែខ្ញុំ<រីករាយ>នឹងបង្ហាញឡើងវិញ<។ វាជាលេខដដែលដូចដែលខ្ញុំបាននិយាយ> គឺជាអង់គ្លេស 0034 6153, ខ្មែរ 00340567 និងបារាំង 00367725 ហើយខ្ញុំនឹងអាន<ឲ្យលោកស្តាប់> ដើម្បីកុំឲ្យមានភាពច្របូកច្របល់<។>

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[០៩:៤៨:១០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ ប្រសិនបើខ្ញុំស្តាប់មិនច្រឡំទេ គឺលោកនិយាយទៅដល់ចម្លើយផ្ទាល់របស់លោកហេង សំរិន ខ្ញុំមិនបានស្តាប់ឮថាលោកនិយាយអំពីការយោងទៅលើឯកសារហ្នឹងទេ ហើយក៏អត់មានឮ ERN ដែរ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយោងទៅលើចម្លើយរបស់ ហេង សំរិន ខ្លួនគាត់ផ្ទាល់ ចំពោះការជំទាស់ <ឬការអង្កេត> របស់សហព្រះរាជអាជ្ញានេះ គឺថាលោកអាចរកឃើញចម្លើយរបស់ ហេង សំរិន ផ្ទាល់នៅក្នុងឯកសារ <E3/1568> និង E3/1539។ <ប៉ុន្តែ> ខ្ញុំក៏បានដកស្រង់សម្តីរបស់កូនប្រុស កែ ពក ដែលនិយាយថា "ពេលនោះពូ ហេង សំរិន ជាប្រធានតំបន់២០ និងជាប្រធានកងពល។" បាទ ឃ្លានេះគឺបង្ហាញច្បាស់ហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំក៏រៀបនឹងអានឯកសារដដែល កថាខណ្ឌដដែលនេះ<អំពីលោក ហេង សំរិន> ដើម្បីសួរថាតើលោកមានយោបល់ថាដូចម្តេចដែរ។ គេបានសួរទៅកូនប្រុស កែ ពក ដូចតទៅ៖ "នៅពេលលោកធ្វើការជាមួយនឹងឪពុករបស់លោក តើលោកបានឃើញព្រឹត្តិការណ៍អ្វីគួរឲ្យគត់សម្គាល់

ដែរទេ?" ហើយកូនប្រុស កែ ពក បានឆ្លើយដូចតទៅ៖ "ខ្ញុំចាំបានថាមានព្រឹត្តការណ៍បោសសម្អាតកម្មាភិបាលភូមិភាគបូព៌ា ការបោសសម្អាតនោះមានពីរដំណាក់កាល។ ដំណាក់កាលទី១ គឺមានការបញ្ជាពីមជ្ឈិមឱ្យឃាត់ខ្លួន ហេង សំរិន ក្រោយពីទទួលបានព័ត៌មានហើយ ឪពុកខ្ញុំបានទៅជួបជាមួយ សោ ភឹម។ ឪពុកខ្ញុំប្រាប់ សោ ភឹម ថា "បងថ្នាក់លើឱ្យឃាត់ខ្លួនមិត្តហេង" សោ ភឹម ឆ្លើយថា "បើអ៊ីចឹងពួកឯងឱ្យអាហេងមកផ្ទះខ្ញុំ" ក្រោយពីឪពុកខ្ញុំជូនដំណឹងដល់ពូហេង ក្រោយមកទៀត គឺបាត់ពូហេងរហូត។ ពេលនោះ ពូ ហេង សំរិន គាត់ជាប្រធានតំបន់២០ និងជាប្រធានកងពល។" ឥឡូវនេះ ខ្ញុំសូមសួរលោកទៅនឹងសម្រង់នេះសិន។ តើលោកដឹងព្រឹត្តិការណ៍ដែលខ្ញុំទើបតែអានឱ្យលោកស្ដាប់តាមរយៈការរៀបរាប់របស់កូនប្រុស កែ ពក និយាយថាមានការបញ្ជា<ពីមជ្ឈិម>ឱ្យចាប់ខ្លួន ហេង សំរិន នោះ លោកដឹងពីព្រឹត្តិការណ៍នេះទេ?

**លោក បាន សៀក៖**

**ឆ៖** បាទលោក ខ្ញុំបាទអត់ដឹងទេ ព្រោះកូន កែ ពក នេះ អាវណ្ណៈនេះ គាត់នៅនីរសារជាមួយ កែ ពក ផ្ទាល់ បានគាត់ដឹង។

**ស៖** សំណួរខ្ញុំចុងក្រោយចំពោះ ហេង សំរិន ហើយខ្ញុំជាបន្តសួរដល់ ជា ស៊ីម។ លោកក៏បាននិយាយដែរពីម្សិលមិញ លោកថា សោ ភឹម គឺជាមេដឹកនាំបក្សពលករ។ តើលោកដឹងថា ហេង សំរិន ជាសមាជិកបក្សពលករដែរឬក៏អត់ទេ?

**ឆ៖** បាទ លោក ខ្ញុំបាទអត់ដឹងទេ។

**ស៖** បាទ ឥឡូវនេះខ្ញុំបន្តទៅនិយាយអំពី ជា ស៊ីម លោកបានលើកអំពីឈ្មោះគាត់ពីរបីដងដែរម្សិលមិញ ហើយលោកក៏បានលើកឡើងខ្លះៗដែរនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក។ លោកបានឆ្លើយថា ជា ស៊ីម ជាប្រធានតំបន់២២ នៃភូមិភាគបូព៌ា។ តើលោកបានដឹងមកពីណា?

**ឆ៖** បាទ លោក ពេលគេរៀបចំឱ្យខ្ញុំទៅធ្វើការនៅក្រូចឆ្មារនេះ គេប្រាប់ថា ជា ស៊ីម ក្បត់ហើយ ជា ស៊ីម ជាលេខាតំបន់២២។ ឥឡូវ ជា ស៊ីម រត់ទៅយួនបាត់ហើយ។ ដូច្នេះ យើងត្រូវរៀបចំទៅជួយធ្វើការរៀបចំមូលដ្ឋាន បានអ៊ីចឹងហើយថាភូមិភាគបូព៌ាក្បត់ គេថាអ៊ីចឹងហ្នឹង។

[០៩:៥២:៥៧]

**ស៖** តើវាអាចទេថាលោកកំពុងតែនិយាយខុសហើយ នៅពេលដែលលោកនិយាយថាគាត់ជាសមាជិកតំបន់២២ ពីព្រោះថាអ៊ីចេះការពិត គឺគាត់ជាប្រធានតំបន់២០ អាចអ៊ីចឹងទេ?

**ប្រធានអង្គជំនុំ៖**

អ៊ីចេះលោកមេធាវី លោកសួរនាំមុខ ឬលោកកែតម្រូវលើចម្លើយរបស់សាក្សីដែលឆ្លើយ? ហើយលោកមកនាំមុខបដិសេធនូវការចម្លើយរបស់សាក្សី ហើយសួរនាំមុខដូច្នេះ? សាក្សីមិនបាច់ឆ្លើយនឹងសំណួរបែបនេះទេ។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក ឌេល លីសាក់៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំយល់ស្របហើយ បើសិនណាជាគាត់ចង់សួរតទល់តផ្ទាល់ជាមួយនឹងសាក្សី គាត់<គួរតែ>យកភស្តុតាង<មួយចំនួន>មក<បង្ហាញ។> អ្វីដែលគាត់បង្ហាញទៅសាក្សី គឺថាជាការលើកឡើងមិនត្រឹមត្រូវ<។ មានកំណត់ហេតុជាច្រើនដែលបង្ហាញពី>តួនាទីរបស់បុគ្គលនេះ< គឺថាមិនមែនជាប្រធានតំបន់ទេ។>

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំ<មិនច្បាស់ទេ លោកប្រធាន> សហព្រះរាជអាជ្ញាក៏ដឹងអំពីភស្តុតាងនេះដែរ គឺនៅក្នុង<ចម្លើយរបស់ ជា ស៊ីម ផ្ទាល់ គឺ>ឯកសារ <E3/1568 ERN 00651>--

**ប្រធានអង្គជំនុំ៖**

តែលោកត្រូវគិតថា ភាគីដេញដោលភាគីដទៃទៀតរួមទាំងអង្គជំនុំជម្រះផង គឺមិនចាត់ទុកថាដឹងទេ បើដឹងមិនបាច់ទៅដេញដោលទេ។ លោកត្រូវបង្ហាញភស្តុតាងដែលមានមានលក្ខណៈផ្ទុយដើម្បីដេញដោល មិនមែនរឿងមកសួរសាក្សី នាំមុខសាក្សីឲ្យផ្តល់សក្ខីកម្មឲ្យសាក្សីឆ្លើយតាមទេ មិនមែនមកនាំមុខសាក្សីទេ! លោកសើចហ្នឹងយ៉ាងម៉េចទៅ? មានន័យថាម៉េច? ចង់ចំអកឲ្យយើង ឬយ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

អត់ទេលោកប្រធាន អត់មានចង់ចំអកអីទេ។ <ដោយសារ>ខ្ញុំ<រៀបនឹង>និយាយអំពី<ចម្លើយរបស់គាត់ផ្ទាល់ គឺ>ឯកសារ E3/1568 ឆ្លើយថា៖ “ខ្ញុំជាលេខាស្រុកពញា<> ហើយនិងជា<សមាជិកគណៈ>តំបន់២០” <គឺមិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ទេ>។ <ការលើកឡើងនេះត្រូវបានបញ្ជាក់ដោយ>អ្នកជំនាញ អេតធេសាន់ ក៏ឆ្លើយផងដែរ នៅក្នុងឯកសារ E3/494 <ដែលថា លោក ជា ស៊ីម គឺជាលេខាតំបន់២០។ ខ្ញុំមិនបានប្រឌិតរឿងនេះឡើងទេ> ខ្ញុំ<គ្រាន់តែចង់>សួរមើលថាតើសាក្សីខ្លួនឯងគាត់យល់ច្រឡំទេដឹង។ ហើយបើសិនណាជាគាត់មិនយល់ច្រឡំទេ នោះក៏វាមិនជាអ្វីដែរ។

**លោក ឌេល លីសាក់៖**

អ៊ីចឹងហើយ<បាន>គាត់ត្រូវបង្ហាញភស្តុតាង<នោះ។> ពីព្រោះសម្រង់<ដែលគាត់ទើបតែអានមុននេះសរសេរ>ថា<គាត់>ជា<លេខាស្រុក ហើយជាសមាជិកតូចមួយនៅក្នុងគណៈតំបន់ ហើយថែមទាំង>មិនមែនជាសមាជិកម្នាក់ក្នុងចំណោមសមាជិកបីនាក់នៃគណៈអចិន្ត្រៃយ៍ទេ។ <ការបង្ហាញបែបនេះនៅចំពោះមុខតុលាការ គឺមានន័យថា គាត់>ជាលេខាតំបន់ <នៅពេលដែលខ្លួនគាត់ផ្ទាល់ឆ្លើយថាគាត់>ជាលេខាស្រុក<។ ការធ្វើបែបនេះវាមិនត្រឹមត្រូវទេ។ នេះជាមូលហេតុដែល>គាត់<>ត្រូវ<តែប្រើប្រាស់>ភស្តុតាង<ជាក់ស្តែងមក>បង្ហាញឲ្យចំតែម្តង <ហើយមិនមែនកំណត់យកដោយខ្លួនគាត់នោះទេ>។

[០៩:៥៦:៤៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំដឹងហើយថា គេមិនចង់និយាយអំពី ហេង សំរិន, ជា ស៊ីម ទេ។ ប៉ុន្តែខ្លួនគាត់ផ្ទាល់ទេ និយាយថាអ៊ីចឹង ថាគាត់ជា<សមាជិកគណៈ>តំបន់ មិនមែនជាសមាជិក<គណៈ>អចិន្ត្រៃយ៍ទេ <ដូច្នេះខ្លួនគាត់ផ្ទាល់ដែលនិយាយថាគាត់នៅក្នុងតំបន់២០>ទេ។ <ខ្ញុំសួរម្តងទៀត> លោកសាក្សី <លោកនិយាយ>ថា <ជា ស៊ីម> ជាប្រធានតំបន់២២ ប៉ុន្តែតើ<គាត់>អាចជាប្រធានតំបន់២០ ដែរឬទេ?

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ ព្រោះថាខ្ញុំទៅធ្វើការក៏ សុន សេន ថា ជា ស៊ីម ជាលេខាតំបន់២២ បាទ ប៉ុន្តែយ៉ាងម៉េចខ្ញុំបាទអត់ដឹងទេទាន។

**ស៖** មិនជាថ្វីទេលោកសាក្សី។ ឥឡូវនោះខ្ញុំ<មានសំណួរមួយទៀតអំពីតំបន់ផ្សេងៗនៅក្នុងភូមិភាគបូព៌ា។> លោកថាស្រុកក្រូចឆ្មារ ស្ថិតនៅក្នុងតំបន់២២។ <តើលោកប្រាកដដែរឬទេ?> ច្បាស់ទេលោកថាស្រុកក្រូចឆ្មារ ចំណុះឲ្យតំបន់២២?

**ឆ៖** បាទ គេប្រាប់អ៊ីចឹង។ គេថាស្រុកក្រូចឆ្មារ ចំណុះឲ្យតំបន់២២។ ហើយ រិន នេះមកទទួលតំបន់២២ ធ្វើការ។ បាទ ចំណុះឲ្យតំបន់២២ លោក កាលនោះគេប្រាប់អ៊ីចឹង។

**ស៖** ជាថ្មីម្តងទៀត មានភស្តុតាងសំខាន់ៗបង្ហាញថា ស្រុកក្រូចឆ្មារស្ថិតនៅក្នុងតំបន់២១ទេ <ហើយលោក>អាច<យល់>ខុស<ហើយមើលទៅ>។ ប៉ុន្តែលោកនេះដឹងទេថា អ្នកណាទទួលបន្ទុកតំបន់២១?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ។

**ស៖** លោកដែលឮសួរឈ្មោះមនុស្សម្នាក់ អ៊ុក ប៊ុនឈឿន?

**ឆ៖** អត់ដែលឮទេ។

**ស៖** បាទ ឥឡូវខ្ញុំត្រឡប់មកនិយាយពី ជា ស៊ឹម។ លោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកថា ជា ស៊ឹម បានរត់ចូលទៅវៀតណាម ហើយក៏បាក់បែកពីភូមិភាគបូព៌ាហ្នឹង ក៏រត់ចូលទៅវៀតណាម។ តើខ្លួនលោកផ្ទាល់នេះ តើធ្វើម៉េចបានលោកដឹងយ៉ាងដូច្នេះ?

[១០:០០:០០]

**ឆ៖** បាទ ពេលគេរៀបចំឱ្យទៅស្រុកក្រូចឆ្មារហ្នឹង គេនិយាយប្រាប់រឿងទាំងអស់ រឿង សោ ភឹម ហ្នឹងក្បត់។ ហេង សំរិន រត់ចូលព្រៃ។ ជា ស៊ឹម រត់ចូលព្រៃ។ អ៊ីចឹងបានដឹង ហើយ ជា ស៊ឹម នេះជាប្រធានតំបន់២២។

**ស៖** លោកដឹងថាតើ ជា ស៊ឹម ក៏ជាសមាជិកបក្សពលករដូច សោ ភឹម ដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ខេល លីសាក់៖**

នេះគ្រាន់តែជាការកត់សម្គាល់ ខ្ញុំយល់ឃើញថាមេធាវីការពារក្តីត្រូវបញ្ជាក់សំណួរនេះឱ្យបានច្បាស់លាស់។ ជាការពិតហើយ <>បក្សពលករកម្ពុជា <គឺជាឈ្មោះ>បក្សកុម្មុយនីស្តកម្ពុជា<>តាំងពីឆ្នាំ១៩៦០ ដល់៦២<។> វាជាឈ្មោះមុនរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយតាមចម្លើយសារភាពនៅ ស-២១ ក៏បញ្ជាក់អ៊ីចឹង។ ដូច្នេះមេធាវីការពារក្តីត្រូវ<មានភាព>ច្បាស់លាស់ <នៅពេល>ប្រើពាក្យថា “បក្សពលករកម្ពុជា” <តើមេធាវីចង់សំដៅទៅ>ស្ថាប័នអ្វី <ហើយ>សាក្សីគាត់មានចំណេះដឹង<ជាមូលដ្ឋានដែល>អាចនឹងឆ្លើយទៅបាន<ទេ>។

[១០:០១:៤៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនដឹង<ច្បាស់>ថា<តើ>នេះវាជារឿងប្រឌិត<>នៅក្នុងមន្ទីរសន្តិសុខស-២១ <ឬយ៉ាងណា>នោះទេ<។> ប៉ុន្តែខ្ញុំនឹងអាចរៀបសំណួរខ្ញុំឡើងវិញ ដើម្បីឱ្យគាត់បានយល់ច្បាស់<ថាខ្ញុំកំពុងនិយាយ>អំពីអំឡុងឆ្នាំ១៩៧៨នោះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកបានឆ្លើយថា សោ ភឹម ជាមេដឹកនាំបក្សពលករ <នៅពេលដែលគាត់រត់គេចខ្លួន> តើ<វាកើត>ឡើង<>ក្នុងឆ្នាំ១៩៧៨ហ្នឹង <មែនទេ>?

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទដឹងតែពេលទៅ គេប្រាប់ថា ជា ស៊ីម ជាពួក សេ.អ៊ី.អា ក្បត់ចូលទៅជួយ។ ឯបក្សពលករហ្នឹង គេនិយាយរឿងរ៉ាវអំពីប្រវត្តិសហព័ន្ធឥណ្ឌូចិន ទាន។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយអំពីអ្វីដែលលោកបានឃើញ <ឬ>បានដឹង នៅពេលដែលលោកបានទៅដល់ភូមិភាគបូព៌ា នៅម៉្តុខែឧសភា មិថុនា ឬក៏ក្រោយនេះបន្តិច។ លោកបានឆ្លើយថា ពេលលោកទៅដល់ភូមិបូព៌ា គឺលោកដឹងថាស្ថានភាពមានភាពច្របូកច្របល់ហើយ ដោយសារថាមានក្រុមផ្សេងៗគ្នានៅក្នុងតំបន់នោះ។ ខ្ញុំនឹងឲ្យសម្រង់ចំៗ<>តែម្តង។ លោកប្រធានឯកសារនេះ គឺ E319/28.3.1 ជាសំណួរចម្លើយលេខ៣ ថា៖ "ភូមិភាគបូព៌ាស្ថិតនៅក្នុងភាពចលាចល ហើយមានច្របូកច្របល់ ដោយមានក្រុមខុសៗគ្នាច្រើនក្នុងតំបន់នោះ" តើលោកចង់មានន័យថាម៉េច <នៅ>ពេលលោក<ថា>ទៅដល់ភូមិភាគបូព៌ាមានភាពច្របូកច្របល់ ហើយមានក្រុមមនុស្សផ្សេងៗគ្នាជាច្រើនក្រុម?

[១០:០៤:២១]

**ឆ៖** បាទ ពេលនោះ ទៅដល់មានសភាពការណ៍តឹងតែងហើយ ព្រោះខាង ជា ស៊ីម, លោក ហេង សំរិន ហ្នឹងបានរៀបចំរណសិរ្សសាមគ្គីសង្គ្រោះជាតិហើយ។ ដូច្នេះ ដឹងតាំងពីបងខ្ញុំប្រាប់ថា "ប្អូន គេរៀបចំតាំងពីទង់ជ័យ ស្អីអស់ហើយណា ហើយកងពលល្អបមកក្បែរៗយើង ប្រយ័ត្នខ្លួនបន្តិចណា" បាទ គាត់ប្រាប់អ៊ីចឹង បានខ្ញុំដឹង។

**ស៖** ហ្នឹងគឺជាក្រុមមួយដែលលោកបានឆ្លើយថា លោកបានឃើញនៅពេលលោកទៅដល់ភូមិភាគបូព៌ា ហើយលោកក៏ឆ្លើយថាមានក្រុមផ្សេងៗ គ្នាជាច្រើនក្រុម លោកចង់មានន័យថាម៉េច ពេលលោកឆ្លើយថា មានក្រុមផ្សេងៗគ្នាជាច្រើនក្រុមនុ៎ង?

**ឆ៖** ខ្ញុំគ្រាន់តែនិយាយថា អ៊ីចេះ ខ្ញុំថា ដល់ទៅដល់ហ្នឹង មានក្រុមចល័តហ្នឹង បះបោរ។ ទៅដល់ហ្នឹង ធ្វើការច្របូកច្របល់ហ្នឹង ទៅដល់ក្រុមចល័តបោះបោរ ប្រហែលជាបួនដប់ថ្ងៃ កងចល័តបះបោរ ដល់បះបោរទៅ បានវារឿងការបោសសម្អាតណ៎ាទាន។

**ស៖** ខ្ញុំបាននិយាយ -- ខ្ញុំនឹងនិយាយច្រើនទៅទៀត ក្រោយពេលសម្រាក<ពាក់ព័ន្ធនឹងការបះបោរនេះ>។ លោកនិយាយថា ក្រុមបះបោរជាក្រុមផ្សេងៗគ្នា ថាជារណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាក្រោមការដឹកនាំរបស់ ហេង សំរិន និង ជា ស៊ីម អ៊ីចឹងឬ?

[១០:០៦:១៦]

**ឆ៖** បាទ ទាន អ៊ីចឹងមែន។

**ស៖** តើមានក្រុមណាផ្សេងទៀត មានសកម្មភាពនៅក្នុងភូមិភាគបូព៌ាដែរទេ ក្រៅពី<ពីរ>ក្រុមដែលលោកកំពុងនិយាយនេះ នៅពេលដែលលោកទៅដល់នោះ?

**ឆ៖** បាទ អត់មានទេ។

**ស៖** តើលោកធ្លាប់ដឹងថា មានការជាប់ទាក់ទងនឹងរវាងក្រុមមួយនេះ ដែលរៀបចំការបោះបោរនិងជាមួយ និងក្រុមរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ ក្រុមពីរនេះ មានទំនាក់ទំនងនឹងគ្នា ឬក៏យ៉ាងណា?

**ឆ៖** បាទលោក គេថាពួកបះបោរ ជាពួក កា.ហ្សៀ.បេ ពួកខាងខ្សែរបស់ ជា ស៊ីម និង ហេង សំរិន បាទ។

**ស៖** តើលោកដឹងថាក្រុមទាំងពីរនេះ ធ្វើការយ៉ាងសកម្មរួមគ្នាដែរឬទេ?

**ឆ៖** ខ្ញុំយល់ថា សកម្មហើយ ព្រោះប្រជាជន ដូចជាអាដែងនេះអ៊ីចឹង វាភ្លឹបភ្លែតៗ ដូចថានៅដូចគាត់ ចង់និយាយ ចង់តែប្រឆាំង ដូចតែអ៊ីចឹងគាត់ ដូចថាមិនពេញចិត្តនឹងពួកដឹកនាំរបស់កុម្មុយនីស្តកម្ពុជា បាទ។

**ស៖** មុនខ្ញុំចូលទៅនិយាយអំពីការបះបោរ<ដែលលោកបានរៀបរាប់យ៉ាងច្រើនមក>នោះ តើលោកដឹងថា<ក្នុងពេលជាមួយគ្នានោះ>ការប្រយុទ្ធគ្នា<នៅតែ>បន្ត<>រវាងកងកម្លាំង<>កម្ពុជា និងកងទ័ពវៀតណាមប្រយុទ្ធគ្នាយ៉ាងសកម្មនៅតាមព្រំដែនដែរទេ លោកដឹងទេ?

[១០:០៨:៤២]

**ឆ៖** បាទ ដឹងមែនទែន ដឹងៗ ឃើញទ័ពងាប់មួយថ្ងៃៗ ដឹក។ ដឹងច្បាស់តែម្តងបាទ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះឲ្យបានលម្អិតបន្តិចបានទេ អំពីការវាយប្រយុទ្ធគ្នានៅតាមព្រំដែន ក្រៅពីរឿងថា<បានឃើញសាកសព>កងទ័ព<បញ្ជូនត្រឡប់>មក<វិញ>នោះ គឺថាសូមនិយាយឲ្យលម្អិតអំពីការប្រយុទ្ធតាមព្រំដែនជូនអង្គជំនុំជម្រះបន្តិចបានទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំបាទអត់ចេះនិយាយបរិយាយទេ លោក សូមមេត្តា។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់កូនប្រុស កែ ពក គាត់បាននិយាយ គឺថា កងទ័ពខ្មែរក្រហម ៣០.០០០ នាក់ បានស្លាប់ ដោយសារតែការប្រយុទ្ធគ្នាជាមួយកងទ័ពវៀតណាមនៅតាមព្រំដែន។ តើលោកអាចបញ្ជាក់អំពីចំណុចនេះបានទេ?

[១០:១០:០២]

**ឆ៖** បាទ ឃើញថាស្លាប់ និងរបួស ដឹកមកក្រោយមួយថ្ងៃៗរាប់ឡានបាទ។ ប៉ុនមិនដឹងថាមុខយ៉ាងម៉េច ថាអ៊ូដល់ហើយ រថក្រោះ ខ្លះរបួសទៅ ខ្លះស្លាប់ទៅ។ អ្នករបួសដែលប្រាប់យើងថា បូកដល់ពេលៗរៀបចំរណសិរ្សសង្គ្រោះជាតិ បូកទៅជាទី២ទៀតហើយ។ ដល់បូកទៅមួយភ្លែតហ្នឹង មកដល់បាត់ មកដល់យើងហ្នឹងបាទ។

**ស៖** ប៉ុន្តែគាត់បានបញ្ជាក់តួលេខច្បាស់ថាកងទ័ពខ្មែរក្រហមនេះស្លាប់ដល់ទៅ៣០.០០០នាក់ ឯនោះ។ តើលោកចាំយ៉ាងម៉េចដែរ ចំពោះតួលេខ<នៃការស្លាប់និងរបួស "ខាងខ្មែរក្រហម">នេះ<?> នៅពេលដែលលោកស្ថិតនៅក្នុងភូមិ<ភាគ>បូព៌ា តើលោកបានឮអ្វីខ្លះដែរអំពីចំនួនអ្នកស្លាប់ ឬក៏អំពីព័ត៌មាននេះ?

**ឆ៖** បាទ ខ្ញុំបាទអត់ឮទេទាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវី ការពារក្តីលោក នួន ជាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីឥឡូវនេះ ខ្ញុំចង់ត្រឡប់មកនិយាយអំពីអ្វីដែលយើងបានពិភាក្សាគ្នា មុនពេលឈប់សម្រាក នៅពេលនោះខ្ញុំបានសួរលោក អំពីកូនប្រុសរបស់ កែ ពក ដែលគាត់និយាយថា ទាហានខ្មែរក្រហម ៣០.០០០នាក់ ត្រូវបានសម្លាប់ចោលនៅក្នុងការប្រយុទ្ធគ្នា។ ខ្ញុំនឹងអានន្ទូវចម្លើយលម្អិតរបស់គាត់ ហើយខ្ញុំនឹងសុំប្រតិកម្មតបរបស់លោក គឺឯកសារ E3/35, ខ្មែរគឺ 00340571, អង់គ្លេស 00346156, បារាំង 00367728។ នៅពេលនោះគេសួរកូន កែ ពក ថា “តើ<វាពិតទេដែលថា>ការជម្លៀស<ប្រជាជនមកពី>ភូមិភាគបូព៌ា<? ចម្លើយ៖> គេជម្លៀសអ្នកនៅភូមិភាគបូព៌ាទៅ<តំបន់>ផ្សេង ហើយនៅពេលនោះនៅតាមព្រំដែនមានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំង។ នៅពាក់កណ្តាលឆ្នាំ៧៨ មានទាហានខ្មែរក្រហមជាង ៣០.០០០នាក់ត្រូវបានសម្លាប់នៅក្នុងសមរភូមិ សាកសពត្រូវបានយកមក<ដុត>នៅ<ក្នុងឡបឹងស្នាយ នៅ>ខេត្តកំពង់ចាម<។> តាភោគ ជាអ្នកទទួលខុសត្រូវក្នុងការ<ឡនោះ> ខ្ញុំដឹងអំពីរឿងនេះ នៅពេលដែលខ្ញុំទៅសួរឈ្មោះ<>បងប្អូនជីដូនមួយពីរនាក់របស់ខ្ញុំដែលបានស្លាប់ហើយត្រូវបានគេបញ្ជូនទៅទីនោះដែរ។” តើលោកដឹងអំពីរឿងដែលថា សាកសពទាំងអស់របស់<ទាហាន>ខ្មែរក្រហម<រាប់ពាន់នាក់>ដែលត្រូវបានសម្លាប់នៅតាមព្រំដែននោះ ត្រូវបាន<>យកមកដុតនៅឡបឹងស្នាយនៅខេត្តកំពង់ចាម។ តើលោកដឹងអំពីរឿងនេះទេ?

[១០:៣៤:៥៧]

**លោក បាន សៀក៖**

**ឆ៖** បាទលោក ខ្ញុំបាទអត់ដឹងទេ។

**ស៖** សំណួរបន្តមួយទៀតពាក់ព័ន្ធនឹងប្រធានបទដែលខ្ញុំបានពិភាក្សាជាមួយលោកមុនពេលឈប់សម្រាក ខ្ញុំបានសួរសំណួរលោកពាក់ព័ន្ធនឹងបក្សពលករ ឬក៏ហៅថា កា.ហ្វេ.បេ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ E3/375 គឺខ្មែរ គឺ00348798, អង់គ្លេស 00360757, បារាំង 00369919។ លោកបាននិយាយអំពីបក្សសេរីកា។ តើលោកចង់មានន័យថាម៉េចនៅពេលដែលលោកនិយាយអំពីបក្សសេរីកា ឬ សេ.អ៊ី.អា នេះ?

**ឆ៖** បាទ កាលនោះ អឿន ប្រាប់ខ្ញុំថាពួកសេរីកា ពួក សេ.អ៊ី.អា វាជាមួយគ្នា។ អាហ្នឹងដល់ពេលនេះទៅ គេហៅដល់ខ្មែរសទៀតលោក អាហ្នឹងបាទ គឺថាពួក សេ.អ៊ី.អា នេះហើយ។

**ស៖** នេះវាពាក់ព័ន្ធទៅនឹងសំណួរបន្ទាប់របស់ខ្ញុំ ក៏ប៉ុន្តែលោកឆ្លើយទៅហើយ អ៊ីចឹងសូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយអំពីអ្វីដែលលោកបានលើកឡើងនៅក្នុងចម្លើយថ្មីៗរបស់លោក គឺឯកសារ 319/28.3.1។ គឺសំណួរចម្លើយទី៨ ពេលនោះគេសួរលោកអំពីការបះបោរពេលដែលលោកទៅដល់ស្រុកក្រូចឆ្មារ ហើយមានការឃុំខ្លួនមនុស្សនៅកោះនោះ។ ខ្ញុំនឹងត្រឡប់មកនិយាយអំពីបញ្ហានេះនៅពេលបន្តិចទៀតនេះ។ លោកបាននិយាយថាក្រោយមកមានការបះបោរមួយទៀត គឺការបះបោរមួយទៀតនៅក្នុងស្រុកក្រូចឆ្មារ។ នៅក្នុងចម្លើយ<ដដែល>នោះលោកនិយាយថាប្រហែលមួយអាទិត្យក្រោយមកគឺវៀតណាមក៏ចូលមកដល់។ ខ្ញុំចង់ដឹងឲ្យច្បាស់ថាតើលោករៀបរាប់អំពីការបះបោរពីរផ្សេងគ្នានៅក្រូចឆ្មារនៅក្នុងឆ្នាំ១៩៧៨ ឬក៏លោកសំដៅទៅលើការបះបោរតែមួយទេ?

[១០:៣៨:១៥]

**ឆ៖** បាទលោក ពេលខ្ញុំទៅដល់បានបួន ប្រាំ ប្រាំមួយថ្ងៃ ប្រហែលមួយអាទិត្យមានការបះបោរមួយអំពីកងចល័ត។ បាទ ដល់ពេលក្រោយមកដែលខ្ញុំគេឲ្យមកនៅតំបន់៤២វិញ គឺមានការបះបោរដោយការផ្ទុះអាវុធតាមដងទន្លេទាំងអស់ហ្នឹង គឺគេឲ្យជម្លៀសប្រជាជនទាំងនោះមកតំបន់៤២ បាទ។

**ស៖** ខ្ញុំមានភាសាអង់គ្លេសពាក់ព័ន្ធនឹងកំណត់ហេតុ<ស្តាប់ចម្លើយ>របស់លោក។ ក៏ប៉ុន្តែ<វាហាក់ដូចជាបានបង្ហាញថា> ក្រោយពី<ការ>បះបោរ<ដែលលោកបានរៀបរាប់មុននេះ និងកាលពីម្សិលមិញយ៉ាងច្រើន> គឺមាន<>ការបះបោរមួយទៀតនៅស្រុកក្រូចឆ្មារ អ៊ីចឹងខ្ញុំចង់ដឹងថាចំណុចនេះត្រឹមត្រូវ ឬក៏អត់?

**ឆ៖** មានតែម្តងទេ ប៉ុនម្តងទៀតគឺថាគ្រាន់តែប្រជាជនវាកងទ័ពគេមកដល់ហើយ ផ្ទុះទៀតប្រទូសរ៉ាយហើយគេជម្លៀសប្រជាជន។ បាទ ខ្ញុំចង់និយាយអ៊ីចឹងបាទ ជម្លៀសប្រជាជនចេញបាទ។

**ស៖** សូមអរគុណលោកសាក្សី។ មុនពេលចូលទៅសួរលោកពាក់ព័ន្ធទៅនឹងការបះបោរនេះ ខ្ញុំមានសំណួរមួយពាក់ព័ន្ធនឹង តាអាន និងប្រធានតំបន់<>៤៣ ឈ្មោះ ស៊ីម។ លោកបាននិយាយថា លោកមិនដែលជួបអាន ឬក៏ ស៊ីម ទេ នៅមុនឆ្នាំ១៩៧៩ <ទេ>។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។ ដល់ថ្នាក់យួនចូលហើយបានស្គាល់គាត់បាទ។

**ស៖** <ឥឡូវនេះ គឺហាក់បីដូចជា>តាអាន នេះក៏ជាអនុរបស់ កែ ពក ដែរ គឺជាអនុភូមិភាគ។ តើមានមូលហេតុជាក់លាក់អ្វីដែលលោកមិនដែលបានជួប តាអាន នោះ ឬក៏ តាស៊ីម នោះ? ហេតុអីបានជាលោកមិនដែលជួបពួកគាត់?

**ឆ៖** បាទ មិនដែលប្រជុំរៀនសូត្រ ឬក៏ប្រជុំអីសម្ងាត់ចំហអីជាមួយគ្នាបាទ។

[១០:៤១:២៧]

**ស៖** ប៉ុន្តែ បើយើងនិយាយអំពីឋានានុក្រម និយាយអំពីរចនាសម្ព័ន្ធ តើខ្ញុំយល់ត្រឹមត្រូវទេដូចជាចម្លែកណាស់ដែលលោកមិនដែលជួប តាអាន, តាស៊ីម នោះ? ព្រោះថាបើតាមឋានានុក្រមហ្នឹងគឺលោកនៅក្រោមគាត់។ អ៊ីចឹង ខ្ញុំដូចជាពិបាកយល់ណាស់ដែលថាលោកមិនដែលជួបពួកគាត់។

**ឆ៖** បាទ ដូចខ្ញុំនិយាយខាងដើម ខ្ញុំបានមកធ្វើការធំ តែមិនដល់ ប្រហែលមួយឆ្នាំចុះ។ បាទ ដូច្នេះ ខ្ញុំមិនដែលបានមកធ្វើការតំបន់៤២ហ្នឹង មិនដែលបានប្រជុំនៅភូមិភាគ ក៏មិនដែលបានប្រជុំទាល់តែទៅស្រុកក្រូចឆ្មារហ្នឹង បានពីរបីខែត្រឡប់មកវិញ។ ដូច្នេះ អត់ដែលបានជួបគ្នាទេបាទ។

**ស៖** មិនអីទេលោកសាក្សី។ ចុះ សុន សេន លោកដែលជួបគាត់ផ្ទាល់ទេ ធ្លាប់ជួបប្រជុំទល់មុខជាមួយគាត់ទេ?

**ឆ៖** បាទ កាលនៅធ្វើស្រុក ប្រជុំជាមួយគាត់ពីរដង។ម្តងប្រជុំដាក់ផែនការឲ្យមករៀបចំរដ្ឋអំណាចចូលការដ្ឋានធ្វើកងទ័ព ម្តងទៀត ទៅប្រជុំម្តងទៀត រៀនសូត្រ ធ្វើប្រវត្តិរូប ហើយគាត់ប្រាប់ថា មិត្តកុហក ប្អូនមួយគេសម្លាប់ហើយ អត់ភ្ជាប់ប្រវត្តិរូប ឥឡូវប្អូនមួយទៀត គេកម្ទេចទៀតហើយ។ ខ្ញុំឮអ៊ីចឹងខ្ញុំបះដើងមកក្រោយ។ គាត់ថាកុំភ័យ មិត្តទៅនៅជាមួយ មិត្តអឿន និង មិត្តពក វិញទៅ។ ហើយមុនមិត្តទៅ មិត្តប្រាប់ប្រជាជនថា គេអត់សម្លាប់មិត្តទេ។ ប៉ុណ្ណឹងទេបាទ។

**ស៖** កាលពីម្សិលមិញ លោកក៏បាននិយាយផងដែរថា សុន សេន បានក្លាយជាលេខាភូមិភាគបន្ទាប់ សោ ភឹម ស្លាប់។ តើលោកដឹងទេថា ក្រោយពី សោ ភឹម ស្លាប់<នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៧៨>ហ្នឹងប៉ុន្មានខែដែរ ដែល សុន សេន បានឡើងធ្វើជាប្រធានភូមិភាគ<>ឬពាំ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ ព្រោះ សុន សេន គាត់ជាមេបញ្ជាការទ័ព ដល់ទៅ សោ ភឹម គាត់យូរហើយ មុនៗ ប្រហែលពីរបីប្អូនប្រាំខែយ៉ាងមើលទៅ ខ្ញុំមិនសូវចាំដែរ ប៉ុនដល់ក្រោយមក បានខ្ញុំទៅជួបថា – រិន គាត់ប្រាប់ថា៖ “អ៊ំ ជាប្រធានភូមិភាគផង ជាអគ្គបញ្ជាការផង”។ បាទ គាត់ប្រាប់អ៊ីចឹងបាទ។

[១០:៤៤:៤៨]

**ស៖** នៅក្នុងកំណត់ហេតុមួយរបស់លោក លោកបាននិយាយថា សាច់ថ្លៃរបស់លោកគឺថា កែ ពក និង សុន សេន ហ្នឹងមិនចូលចិត្តគ្នាទេ។ លោកដឹងទេថា ហេតុអីបានជាពួកគេ មិនចូលចិត្តគ្នា?

**ឆ៖** តាមខ្ញុំដឹង កាលពីនៅភូមិភាគ កាលច្បាំងអត់ទាន់ប៉ុន្មានទេ។ ដល់មកចូលព្រៃហើយ គឺប៉ះពាល់គ្នា ដល់ថាមិនមែនពផែនដីតែម្នាក់ឯងបាន។ ឮសូរគាត់ថាអ៊ីចឹង។ អ៊ំពក គាត់ថាគ្មាននរណាពផែនដីម្នាក់ឯងរួចទេ ធ្វើម្នាក់ធ្វើទៅ។ ប៉ុណ្ណឹងទេ។

**ស៖** លោកចាំទេ ពេលចុងក្រោយបំផុតនោះ ពេលណាដែលលោកឃើញ សុន សេន មានវត្តមាននៅក្នុងភូមិភាគបូព៌ានោះ?

**ឆ៖** បាទ ពេលខ្ញុំ គាត់ហៅទៅរៀន បានឃើញគាត់ម្ដង បាទ។ ពីដើមខ្ញុំអត់ដែលស្គាល់ផងបាទ។

**ស៖** តើលោកចាំថា អឿន ហ្នឹង បានប្រាប់អ្វីខ្លះអំពី សុន សេន? លោកមានចាំថា អឿន ធ្លាប់និយាយអំពីអត្តចរិតរបស់ សុន សេន ប្រាប់ទេ?

**ឆ៖** បាទ អឿន អត់ប្រាប់ទេ ប៉ុន ពក គាត់ប្រាប់ កាលគាត់នៅគណៈសមរភូមិ បែកចេញហើយ ប្រាប់ថា “គេធ្វើបាបយើងហើយ គេបញ្ឈរជើងលែងឲ្យធ្វើអីហើយ”។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយអំពីការបះបោរដែលលោកបានរៀបរាប់។ លោកបាននិយាយថាមានយុវជនក្មេងៗនៅក្នុងកងចល័តទាំងខ្មែរ ទាំងចាម បានបះបោរ។ លោកក៏បានផ្ដល់តួលេខមួយចំនួនពាក់ព័ន្ធទៅនឹងកម្លាំងនេះ។ ខ្ញុំចង់ដឹងថា តើក្រុមបះបោរហ្នឹងមានចំនួនច្រើនទេ ដែលក្រោយមកត្រូវបានគេចាប់យកទៅឃុំ<>នៅលើកោះហ្នឹង? <តើលោកចាំបានទេពេលនេះ?>

**ឆ៖** បាទ កាលនោះគេគ្រាន់តែប្រាប់ថាមានការបះបោរ។ អ៊ីចឹងហើយសំបុត្រពីលើមក ដល់ការបះបោរ គឺពួក កា.ហ្សេ.បេ. បាទ។ ប៉ុន្តែចំនួនខ្ញុំអត់ដឹងប៉ុន្មានទេ បាទ។

[១០:៤៨:៣៨]

**ស៖** នៅក្នុងកំណត់ហេតុមួយរបស់លោកៗនិយាយអំពីមនុស្ស ៨០នាក់។ តើលោកអាចបញ្ជាក់បានទេថា តិចជាង១០០ ឬ<ក៏ច្រើនជាង១០០នាក់> ដែលបានចូលរួមក្នុងការបះបោរនេះ? ខ្ញុំគ្រាន់ដឹងថា រឿងនេះវាយូរមកហើយ តើលោកអាចនឹកគិតប៉ាន់ប្រមាណមើលបន្តិចទៅមើល៍ តើអាចតិចជាងមួយរយ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនចាំបានទេ ក៏ប៉ុន្តែប្រហែលជាខ្ញុំទៅហ្នឹងឃើញតែគ្នាប្រហែលជាបួនដប់ម្ភៃនាក់។ កន្លែងហ្នឹង ខ្ញុំមើលពីចម្ងាយទៅ គ្រាន់តែឃើញខ្ញុំត្រឡប់មកវិញ បាទ។

**ស៖** ចុះកាលបះបោរហ្នឹង លោកចាំទេថាមានការប្រើកាំភ្លើងទេ ឬក៏មានកាំភ្លើងធំ? វាជាការបះបោរប្រភេទណាដែរ លោកមាននៅចាំទេ?

**ឆ៖** បាទ ខ្ញុំអត់ចាំទេ ទាន។ គ្រាន់ថាការបះបោរហ្នឹងគ្រាន់តែទាហានខាងមជ្ឈិម ហើយនិងកងទ័ពដែលទៅហ្នឹងថា មានការបះបោរប្រឆាំងហើយ។ ឥឡូវហ្នឹងសភាពការណ៍កាន់តែតឹងតែងមែនទែនហើយ។ ដល់អ៊ីចឹងយើងខាងទ័ពក៏មិនទាន់ប៉ានធ្វើអីដែរ គ្រាន់តែព័ទ្ធទុកហើយបញ្ជូនរបាយការណ៍ទៅលើ ហើយទៅលើ បានទៅលើឲ្យ តាឲ្យសំបុត្រមក បានឲ្យទៅកងទ័ពវិញបាទ។

**ស៖** សាក្សីមួយរូបដែលបានមកផ្តល់សក្ខីមុននេះនៅក្នុងសវនាការនេះ គឺ<គាត់ជាស្ត្រីម្នាក់> ឈ្មោះ នោ សាទះ គាត់បាននិយាយថា គាត់ឮសំឡេងកាំភ្លើង។ លោកចាំថា មានឮសំឡេងកាំភ្លើងតូច ឬក៏កាំភ្លើងធំធន់ធ្ងន់អីទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ឮទេ ប៉ុន្តែពេលនោះ អនុស្រុកខ្ញុំហ្នឹងត្រូវគេបាញ់នៅមាត់ទន្លេរបួសធ្ងន់ហើយ ដូច្នេះយើងចល័តកន្លែង បាទលោកពេលនោះមិនដឹងទេ ព្រោះចល័ត។

[១០:៥១:១៨]

**ស៖** នៅពេលនោះ<តើ>លោកដឹងថាមានសម្ភារៈ <ឬ>អាវុធប្រភេទណា<ដែលកម្លាំងរបស់មជ្ឈិម>យកទៅបង្ក្រាបការបះបោរនោះ<?> លោកដឹងថាមានប្រើកាំភ្លើងធំ ឬក៏មានប្រើរថក្រោះអីទេ?

**ឆ៖** តាមខ្ញុំឃើញកងទ័ព មានតែបេ ឬក៏ ដេ អាកា ប៉ុណ្ណឹងឯង ព្រោះកងទ័ពរបស់ -- កងទ័ពរបស់មជ្ឈិម ហៅថាកងការពារសន្តិសុខសណ្តាប់ធ្នាប់របស់ភូមិភាគ។ អាហ្នឹងកងទ័ពរបស់តា សុនសេន តែមួយហ្នុងបាទ។

**ស៖** តើលោកដឹងថា មជ្ឈិមប្រើទាហានប៉ុន្មាននាក់ ដើម្បីមកបង្ក្រាបវាយប្រហារការបះបោរ

នេះ<?> ឧទាហរណ៍ <តើពួកគេដាក់ទាហានមក រាប់រយនាក់> ឬក៏<រាប់ពាន់នាក់> លោកអាចប៉ាន់ប្រមាណមើលបានទេ ចំនួនទ័ពពីមជ្ឈិមមកហ្នឹង ប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ៣០០នាក់។

**ស៖** មានន័យថាទាហាន៣០០នាក់ មកពីមជ្ឈិមត្រូវបានប្រើប្រាស់សម្រាប់បង្ក្រាបការបះបោរនេះ មានន័យថាអ៊ីចឹងមែនទេ?

**ឆ៖** បាទ មកការពារសន្តិសុខសណ្តាប់ធ្នាប់នៅតំបន់ទាំងអស់ហ្នឹង មិនមែនតែក្រុចឆ្មារទេ តាំងពីពាមជីលាំងរហូត គេការពារទាំងអស់ បាទ។

[១០:៥៣:៣០]

**ស៖** លោកបាននិយាយអំពីមនុស្សដែលលោកស្គាល់ ហើយដែលមានរបួសនៅពេលវាយប្រយុទ្ធគ្នា។ តើលោកអាចជម្រាបជាទូទៅបានទេថា ថាទាហានមជ្ឈិមប៉ុន្មាននាក់ដែររងរបួស និងស្លាប់នៅក្នុងវាយប្រយុទ្ធគ្នាបង្ក្រាបការបះបោរហ្នឹង?

**ឆ៖** បាទ អត់មានទេ អត់មានរបួសទេ ប៉ុន្តែបើរបួស របួសគេលបបាញ់ កងឈ្លបគេបាញ់តាមមាត់ទន្លេទេបាទ។

**ស៖** លោកបានឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា លោកបានធ្វើរបាយការណ៍មួយពាក់ព័ន្ធនឹងមនុស្សដែលត្រូវបានចាប់ ហើយនិងឃុំនៅលើកោះ គឺលោកវាយ-ការណ៍ទៅ អឿន។ លោកចាំថា លោកបានសរសេរអ្វីខ្លះនៅក្នុងរបាយការណ៍នោះ ដែលលោកផ្ញើទៅ អឿន ហ្នឹងទេ?

**ឆ៖** បាទ ពេលនោះផ្ញើទៅពីរកន្លែង ផ្ញើទៅ អឿន ផង, ផ្ញើទៅ រិន ផងខាងភូមិភាគហ្នឹងឲ្យដឹងអំពីសភាពការណ៍បះបោរ បាទ។

**ស៖** ខ្ញុំយល់ ប៉ុន្តែខ្ញុំសួរថាលោកចាំអំពីខ្លឹមសារដែលលោកសរសេរនៅក្នុងរបាយការណ៍ហ្នឹងទេ លោកសរសេរលម្អិតអ្វីខ្លះ ផ្ញើទៅ អឿន ហ្នឹង?

**ឆ៖** ខ្ញុំអត់ចាំទេ ចាំតិចតួច គ្រាន់ថាសភាពការណ៍មិនល្អ មានការបះបោរហើយ។ ដូច្នេះ ខាងយើងខ្ញុំមិនប៉ានៅមួយកន្លែងបានទេ បាទ។ នេះចាំតែប៉ុណ្ណឹងឯង។ លម្អិតទៀត ខ្ញុំមិនចាំទេ។

[១០:៥៥:៥១]

**ស៖** ឥឡូវនេះលោកនិយាយថា អ្នកបះបោរហ្នឹង មានទាំងចាម ទាំងខ្មែរ។ តើលោកអាចជម្រាប

បានទេ ក្នុងនុំងមានប៉ុន្មានភាគរយជាខ្មែរ ប៉ុន្មានភាគរយជាចាម លោកអាចបែងចែកបានទេ?

**ឆ៖** អត់ទេ បាទ អត់បែងបានទេ ព្រោះមិនបានចូលទៅរាប់ផង។

**ស៖** អ៊ីចឹងម៉េចជាលោកដឹងថា អ្នកបះបោរហ្នឹង មានទាំងខ្មែរ មានទាំងចាមនោះ។ លោកបានប្រភពមកពីណា ដែលធ្វើឲ្យលោកដឹងអំពីព័ត៌មាននេះនោះ?

**ឆ៖** បាទ ប្រភពកងទ័ពប្រាប់ថា មានការបះបោរ មានលាយទាំងបងប្អូនចាមផង ខ្មែរផង។ ដូច្នេះ សភាពការណ៍មិនល្អទេ នៅក្នុងតំបន់ហ្នឹង។

**ស៖** នៅក្នុងកំណត់ស្តាប់ចម្លើយរបស់លោក គឺ E319/19.3.86 នៅក្នុងចម្លើយ៥៣ គេសួរលោកដូចតទៅ "តើលោកធ្លាប់បានទទួល<បញ្ជា>ពីថ្នាក់លើ ឲ្យធ្វើការជ្រើសរើស និងសម្លាប់ជនជាតិចាមទាំងអស់នៅក្នុងស្រុកក្រូចឆ្មារដែរឬទេ?" លោកឆ្លើយនៅពេលនោះថា "ទេ, ខ្ញុំមិនដែលទទួលបញ្ជាបែបនេះទេ"។ តើលោកនៅរក្សាចម្លើយនេះទេ?

**ឆ៖** ទៅក៏ខាងលើអត់ប្រាប់ថា បងប្អូនអ៊ីស្លាមត្រូវបោសសម្អាត ឬក៏ប្រមូលអី អត់ទេ។ ហើយខាងខ្មែរ ក៏គេអត់ប្រាប់ថា ពួកបះបោរ គឺពួកកា.ហ្សេ.បេ គឺអ៊ីចឹង ជាឆ្អែបម្រើយួនតែប៉ុណ្ណឹង បាទ។

[១០:៥៨:៤២]

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយដដែល គឺនៅក្នុងសំណួរចម្លើយ៥៧ គេបានសួរសំណួរប្រហាក់ប្រហែលដែរ <ហើយគេសួរដេញដោលលោកនឹងភស្តុតាងពីមុនរបស់លោក។> អ្នកស៊ើបអង្កេតសួរលោកដូចតទៅ លោកបាននិយាយថា <ខ្ញុំ>សូមដកស្រង់៖ "បញ្ជាឲ្យធ្វើការបោសសម្អាតប្រជាជននៅក្នុងស្រុកក្រូចឆ្មារ គឺចេញមកពី សុន សេន។ ហើយអ្នកចូលរួមបះបោរទាំងអស់ត្រូវតែសម្លាប់ ហើយការចាប់និងសម្លាប់នៅនោះ គឺមិនសំដៅទៅលើជនជាតិចាមទេ គឺសំដៅទៅលើប្រជាជនទាំងអស់ដែលចូលរួមក្នុងចលនាបះបោរ។ តើសម្តីរបស់លោកនេះ ត្រឹមត្រូវដែរឬទេ? លោកពេលនោះឆ្លើយថា៖ "បាទ ត្រឹមត្រូវហើយ"។ លោកនៅតែរក្សាចម្លើយនេះដដែល នៅពេលដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេត ឬក៏យ៉ាងណា?

**ឆ៖** បាទ រឿងហ្នឹងពិតអ៊ីចឹងមែនបាទ ព្រោះខាងលើអត់មានជ្រើសរើសទេ។ ដូចខ្ញុំបានជម្រាបថា ទោះជាប្អូនខ្ញុំក៏ដោយ ក៏ឲ្យតែមានការបះបោរ គឺគេកម្ទេច ឬក៏ប្រវត្តិរូបមិនស្អាត ក៏គេកម្ទេចដែរលោក។

**ស៖** នៅក្នុងចម្លើយរបស់លោកជូនសហចៅក្រមស៊ើបអង្កេត គឺ E3/375 គឺភាសាអង់គ្លេស

00360759, ខ្មែរគឺ 00348800, បារាំងគឺ 00369922។ គេសួរសំណួរទូទៅពាក់ព័ន្ធទៅនឹងចាម "សំណួរ៖ តើជនជាតិចាម ត្រូវបានគេចាត់ទុកជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? ពេលនោះលោកឆ្លើយថា ខ្ញុំគិតថាមិនមែនជាសត្រូវរបស់បក្សកុម្មុយនីស្តទេ ប៉ុន្តែកាលនោះជនជាតិចាម គេមិនអនុញ្ញាតឲ្យមានការ<ប្អូងសួងថ្វាយបង្គំ>នោះទេ សូម្បីតែព្រះសង្ឃក៏គេមិនឲ្យ<សូត្រធម៌>ដែរ។ ពេលនោះ គ្រប់សាសនាទាំងអស់ត្រូវបានបំបាត់ចោល"។ នៅថ្ងៃនេះ តើលោកនៅតែរក្សាចម្លើយនេះដដែលឬ?

**ឆ៖** បាទ ខ្ញុំនៅរក្សាដំហរដដែលបាទ។

**ស៖** ឥឡូវនេះខ្ញុំសូមចូលទៅប្រធានបទប្រហែលជាចុងក្រោយរបស់ខ្ញុំហើយលោកសាក្សី ប៉ុន្តែមុនចូលទៅ ខ្ញុំសូមសួរសំណួរតូចមួយសិន។ លោកនិយាយអំពីឈ្មោះ ជឹម ដែលជាប្រធានចម្ការកៅស៊ូនៅតំបន់៤២។ ជឹម ហ្នឹងគឺប្រហែលជាឈ្មោះ ពេជ្រ ជឹម ហ្នឹងមែនទេ?

[១១:០២:២៥]

**ឆ៖** ខ្ញុំមិនស្គាល់ឈ្មោះត្រកូលទេ ដឹងថាឈ្មោះ បងជឹម។ គាត់ជាប្រធានចម្ការកៅស៊ូ ចម្ការអណ្តូងរបស់ភូមិភាគបាទ។ ហើយក្រោយមក គាត់ត្រូវទៅទទួលចម្ការកៅស៊ូនៅជប់។ ក្រោយប្រទូស្តប្រទាំង គាត់ទៅធ្វើការចម្ការកៅស៊ូនៅជប់បាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំចូលទៅប្រធានបទចុងក្រោយរបស់ខ្ញុំលោកសាក្សី។ <>គឺពាក់ព័ន្ធនឹងកូនក្តីរបស់ខ្ញុំ នួន ជា។ ត្រឹមត្រូវទេថា លោកមិនដែលជួប នួន ជា ផ្ទាល់មុខដូចដែលលោកបានធ្លាប់ជួប សុន សេន ទេ? គឺខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ ខ្ញុំសូម្បីតែជិតក៏មិនដែល ផ្ទាល់ក៏មិនដែលបានឃើញ រូបថតដែលបានឃើញរូបថត ឬពីដើមគ្រាន់តែឮសូរតែឈ្មោះបាទ។ ទើបឃើញៗឥឡូវទេបាទ។

**ស៖** នៅពេលនោះ លោកដឹងអំពីតួនាទីរបស់លោក នួន ជា ទេ គឺចន្លោះពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩ នោះ លោកដឹងថាគាត់ធ្វើអ្វីខ្លះទេ?

**ឆ៖** បាទ ខ្ញុំដឹងថា អ៊ំនួន ជា ទទួលប្រធានសភា បាទ ហើយកម្មាភិបាលជាន់ខ្ពស់ថា គាត់អប់រំកម្មាភិបាលខ្ពស់ៗថ្នាក់ស្រុកឡើងទៅ គឺគាត់អប់រំកម្មាភិបាលជាន់ខ្ពស់ហ្នឹង។

**ស៖** លោកដឹងអ្វីផ្សេងទៀតក្រៅពីហ្នឹងទេ ពាក់ព័ន្ធនឹងតួនាទីរបស់លោក នួន ជា ហ្នឹង?

**ឆ៖** បាទ លោក ខ្ញុំអត់ដឹងទេទាន។

**ស៖** ដូចជាប្រធានរដ្ឋសភានេះ លោកដឹងថាតួនាទីគាត់ហ្នឹងអ្វីខ្លះទេ? គាត់មានភារកិច្ចអ្វីខ្លះទេនៅពេលដែល<>គាត់ជាប្រធានសភានោះ? <តើលោកដឹងដែរឬទេ?>

**ឆ៖** បាទ ដឹងតាមកម្មាភិបាលតំបន់ថា ប្រធានសភាហើយទទួលនយោបាយបាទ។ នយោបាយមិននយោបាយខាងលើទេ ទទួលនយោបាយក្រោមពី ប៉ុល ពត មកគឺអ៊ំ នួន ជា នេះឯង។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ ក៏ប៉ុន្តែខ្ញុំចង់ដឹងណាស់ លោកដឹងថាភារកិច្ចគាត់អ្វីទេ ក្នុងនាមជាប្រធានរដ្ឋសភានេះ ឬក៏ភារកិច្ចពាក់ព័ន្ធនឹងការបង្រៀន នយោបាយនេះ លោកដឹងថាគាត់ធ្វើអ្វីជាក់ស្តែងទេ? <តើគាត់បានធ្វើអ្វីខ្លះតាមដែលអ្នកផ្សេងប្រាប់លោកនោះ?>

**ឆ៖** បាទ លោកខ្ញុំបាទ អត់ដឹងទេទាន។

**ស៖** ខ្ញុំដឹងថាលោកមិនដឹងលម្អិតអំពីការងាររបស់គាត់ទេ ក៏ប៉ុន្តែ<តើមានអ្នកណានិយាយប្រាប់លោកពី នួន ជា ដែរឬទេ? តើ>មានអ្នកណាប្រាប់លោក ពន្យល់ប្រាប់លោកអំពីបញ្ជាដែល នួន ជា ធ្លាប់ចេញនៅពេលនោះទេ?

**ឆ៖** បាទ អត់ទេទាន អត់ដែលបានទៅទេ ព្រោះពេលនោះគេដាក់ប៉ុន្មាន ៨៧។ គេអត់ដាក់ៗឈ្មោះទេ គេដាក់តែលេខទេកាលណោះ គេបញ្ជាទៅតាមលេខទេ ដែលឃើញថាលេខ គ្រាន់តែឃើញម៉ូតូនីរសារគេថាអានេះនីរសារលេខនេះៗ យើងក្រោមខ្លាចហើយបាទ អត់មានដាក់ឈ្មោះថាអ៊ំនេះ អ៊ំនោះទេ។

**ស៖** ខ្ញុំសួរលោកតាមរបៀបផ្សេងវិញអ៊ីចឹង។ តើលោកចាំថាលោកធ្លាប់ស្តាប់ឮពីអ្នកដែលនិយាយអំពី នួន ជា <ដែរឬទេ?> ប្រាប់លោកនោះ គេនិយាយប្រាប់លោកអំពីសកម្មភាពជាក់ស្តែងរបស់គាត់ ឧទាហរណ៍ដូចថា អ្នកនេះត្រូវបានចាប់ខ្លួន ដោយសារតែទទួលបញ្ជាពីនួន ជា។ លោកធ្លាប់ឮអំពី<>ហេតុការណ៍បែបហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ ព្រោះយកទៅបាត់ៗ អត់ដឹងបញ្ជាពីណាផងបាទ។

[១១:០៧:៣៧]

**ស៖** ខ្ញុំយល់ លោកសាក្សី ក៏ប៉ុន្តែខ្ញុំចង់ឲ្យប្រាកដ អ៊ីចឹង ខ្ញុំសូមអានចម្លើយពីមុនរបស់លោកនៅក្នុងកំណត់ហេតុរបស់លោកគឺ E319/19.3.86 សំណួរចម្លើយ64 ខ្ញុំនឹងអានសំណួរចម្លើយនៅពេលនោះ៖ “តើលោកគិតថា កែ ពក ដែលជាលេខាភូមិភាគ បានអនុញ្ញាតឲ្យលេខាតំបន់ផ្សេងៗទៀតធ្វើសេចក្តីសម្រេចសម្លាប់មនុស្ស ឬក៏ធ្វើការបោសសម្អាតដោយមិនមានបញ្ជាពីគាត់ ឬក៏ដោយគ្មានការ

បញ្ជូនដំណឹងទៅគាត់ដែរឬទេ?" ពេលនោះលោកឆ្លើយដូចតទៅ៖ តាមខ្ញុំដឹងសេចក្តីសម្រេច ឬបញ្ជាឲ្យធ្វើការបោសសម្អាត ឬការសម្លាប់មនុស្សគឺចេញពីមន្ទីរ៨៧០ មិនមែន កែ ពក ឬតំបន់ជាអ្នកសម្រេចទេ។ ខ្ញុំឮថា នួន ជា ជាប្រធានសភា និងជាអ្នកអប់រំនយោបាយដល់កម្មាភិបាលទាំងអស់។ ដូច្នេះសេចក្តីសម្រេចឲ្យបោសសម្អាត ឬសម្លាប់មនុស្សអាចចេញមកពីគាត់ដែរ"។ ដូច្នេះ បើតាមខ្ញុំយល់ តាមរយៈចម្លើយនេះ គឺលោកឆ្លើយស្មានទេ មែនទេ ពាក់ព័ន្ធនឹងតួនាទីរបស់លោក នួន ជា នៅចន្លោះពីឆ្នាំ៧៥ ដល់ ឆ្នាំ៧៩ នោះ?

**ឆ៖** បាទ ឆ្លើយហ្នឹងមិនមែនដឹងពិត ឃើញពិតខ្លួនឯងព្រោះតាមកម្មាភិបាលជាន់ខ្ពស់ថា លើការអប់រំ ទាំងនយោបាយយោធា សេដ្ឋកិច្ចអ្វីទាំងអស់ ឲ្យកម្មាភិបាលជាន់ខ្ពស់ គឺ អ៊ំនួន ជា នេះឯងជាអ្នកអប់រំ។ ដូច្នេះ ខ្ញុំកំណត់ថាអាចមានការប្រព្រឹត្តអ្វីៗ គឺអាច ព្រោះកម្មាភិបាលទៅរៀនអាចលើកអំពីការបោសសម្អាត ឬការខ្មាំងយ៉ាងម៉េចៗ អាចជម្រាបទៅលោកពេលរៀនសូត្រទៅបាទ។

[១១:១០:00]

**ស៖** ឥឡូវនេះខ្ញុំយល់ថាលោកមិនដែលឃើញ នួន ជា ដោយផ្ទាល់ភ្នែកទេ ក៏ប៉ុន្តែលោកបាននិយាយថាលោកបានចូលរួមក្នុងវគ្គរៀនសូត្រ។ វគ្គរៀនសូត្រដែលដឹកនាំដោយលោក នួន ជា គឺភាគច្រើនត្រូវបានចូលរួមដោយកម្មាភិបាលជាច្រើន គឺអាចរហូតដល់រាប់រយ <ហើយពេលខ្លះ>រាប់ពាន់នាក់ឯណោះ<។> តាមបទពិសោធន៍របស់លោកផ្ទាល់ តើ នួន ជា អាចនិយាយ<នៅចំពោះមុខកម្មាភិបាលរាប់រយ ឬរាប់ពាន់នាក់នេះ>អំពីការបោសសម្អាតទៅលើក្រុមជាក់លាក់ណាមួយដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ សាក្សីគាត់បាននិយាយហើយថាគឺកម្មាភិបាលដែលចូលរួមវគ្គរៀនសូត្រហ្នឹងមកនិយាយប្រាប់គាត់ទេ អ៊ីចឹងនៅពេលដែលមេធាវីគាត់សួរបែបនេះ សួរឲ្យសាក្សីឆ្លើយស្មានៗហើយ <ដូច្នេះសំណួរនេះគឺធ្វើឲ្យមានការប៉ាន់ស្មាន ដែលមិនមែនជាព័ត៌មានពិតចេញពីសាក្សីទេ>។

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំសូមរៀបចំសំណួរខ្ញុំឡើងវិញ។

[១១:១១:១៦]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបានចូលរួមដោយផ្ទាល់ក្នុងវគ្គរៀនសូត្រ នេះជាចម្លើយរបស់លោក។ ពេលដែលរៀននោះ តើលោកធ្លាប់ឮអ្នកណាម្នាក់និយាយអំពីបញ្ហាឲ្យបោសសម្អាត ឬក៏ចាប់កម្មាភិបាលណាទេ? <តើ>លោកធ្លាប់ឮទេ <>គេមាន<និយាយពី>ឈ្មោះ<>កម្មាភិបាល<ណាមួយដែល>ត្រូវ<ចាប់ខ្លួន>ទេ?

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទ អត់ដែលរៀនជាមួយអ៊ំ នួន ជា ទេ ប៉ុន្តែខ្ញុំបានរៀនជាមួយ សុន សេន បាទ។ ក៏ប៉ុន្តែការរៀននោះ ការអប់រំដើម្បីនិយាយអំពីខ្មាំងស៊ីរូងផ្ទៃក្នុង កា.ហ្សេ.បេ និង សេ.អ៊ី.អា ក៏ប៉ុន្តែពេលនេះ កម្លាំង កា.ហ្សេ.បេ វាអត់ដូចកម្លាំង សេ.អ៊ី.អា ទេ កម្លាំង កា.ហ្សេ.បេ នេះខ្លាំងណាស់ ដូច្នេះត្រូវពេលនេះ មានពួកក្បត់មួយចំនួនបានទៅចូលរួមទៀត ដូច្នេះតើយើងត្រូវតែខំប្រឹងប្រមូលកងទ័ពដើម្បីរៀបចំប្រយុទ្ធ ហើយអប់រំប្រជាជនឲ្យយល់អំពីការ -- បងប្អូនឲ្យយល់អំពីការពួកទៅហ្នឹង គឺពួកខ្ញុំយួនពួក កា.ហ្សេ.បេ។ បាទ ប៉ុណ្ណឹងឯង។

**ស៖** ខ្ញុំយល់ច្បាស់ថា សុន សេន ឬអ្នកផ្សេងទៀត និយាយជាទូទៅអំពី<ភ្នាក់ងារ> សេ.អ៊ី.អា ឬ កា.ហ្សេ.បេ ឬក៏ “ខ្មាំងស៊ីរូងផ្ទៃក្នុង” <ប៉ុន្តែ>វាជារឿង<តែមួយទូទៅ>ដែលលោកអាច<អាន>នៅក្នុង “ទស្សនាវដ្តីទង់បដិវត្ត” ដែរ។ អ៊ីចឹងខ្ញុំចង់ដឹងថា លោកធ្លាប់ឮ សុន សេន ឬក៏អ្នកផ្សេងណាទៀតនោះ និយាយថាកម្មាភិបាលឈ្មោះនេះ ឈ្មោះនោះ ត្រូវតែចាប់ខ្លួនទេ?

[១១:១៣:៣០]

**ឆ៖** បាទ គេអត់ប្រាប់ទេ ដូចខ្ញុំបានជម្រាបតាមខ្ញុំចម្លើយថា អ្នកហៅទៅហ្នឹង ឡើងមួយធ្វើធំទៅ ពីរបីខែយកទៅបាត់ បន្តិចឡើងមួយទៀតទៅធ្វើប្រធានទៅ ពីរបីខែយកទៅបាត់។ ហើយតែកម្មាភិបាលជនបង្គោល យុវកក និងបក្ខជនគេ បក្ខជនពេញសិទ្ធិ។ តាមខ្ញុំបាទមើលទៅ គឺអស់ភូមិភាគកណ្តាលបាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ លោកសាក្សីដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី បាន សៀក។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមគោរពភាគីទាំងអស់។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក បាន សៀក! ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ខ្ញុំនឹងសួរសំណួរ<មួយចំនួនទៅ>លោកក្នុងនាមជាមេធាវីរបស់គាត់។ សំណួរទី១ របស់ខ្ញុំ គឺចង់ឱ្យលោកឆ្លើយបញ្ជាក់។ លោកបាននិយាយថា លោកមកពីភូមិភាគកណ្តាល តើលោកអាចជម្រាបបានទេ ថានៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិភាគកណ្តាលមានតំបន់ប៉ុន្មាន? បើសិនជាលោកចាំ សូមលោកឱ្យលេខ ឈ្មោះលេខតំបន់ទាំងអស់នោះ។

[១១:១៥:០៩]

**លោក បាន សៀក៖**

**ឆ៖** បាទ ទាន ភូមិភាគកណ្តាលមានតំបន់បីគឺ តំបន់៤១ តំបន់៤២ និងតំបន់៤៣ បាទ។

**ស៖** ហើយលោកផ្ទាល់នេះ បើតាមចម្លើយរបស់លោក គឺនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យលោកកាន់មុខងារតែនៅក្នុងតំបន់៤២ទេ។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទលោក ត្រឹមត្រូវហើយ។

**ស៖** នៅពេលដែលលោកនៅកងនេសាទនៃតំបន់៤២ តើលោកនៅចាំថានៅក្នុងឃុំណាស្រុកណាទេ?

**ឆ៖** បាទ នៅក្នុងស្រុកព្រែកប្រសប់ ឃុំខ្ពបតាងួន តំបន់៤២បាទ។

**ស៖** បន្ទាប់មកទៀត នៅពេលដែលគេតែងតាំងលោកជាអនុលេខាស្រុកចំការលើ គឺនៅក្នុងតំបន់៤២។ ដូច្នេះ តាមរយៈចម្លើយរបស់លោក គឺ<>អ្នកដែលទទួលខុសត្រូវផ្ទាល់លើលោកហ្នឹងគឺ ស៊ូ សឿន មែនទេ?

**ឆ៖** បាទ លោក ស៊ូ សឿន ជាបងស្រីថ្លៃរបស់ខ្ញុំបាទ។

**ស៖** តាមរយៈភាសាបារាំងខ្ញុំឮថាជាបង<ស្រី>ថ្លៃ ក៏ប៉ុន្តែកាល់ពីម្សិញមិញខ្ញុំស្ដាប់ឮថា គាត់ជាបងប្អូនជីដូនមួយជាមួយនឹងប្រពន្ធរបស់លោក។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គាត់បងប្អូនជីដូនរបស់គ្រួសារខ្ញុំ។ អ៊ីចឹង បានខ្ញុំហៅគាត់ថាបងថ្លៃ ព្រោះគាត់បងបាទ។

**ស៖** លោកបាននិយាយអំពីការប្រើឈ្មោះផ្សេងៗនៅមុន ក្នុងអំឡុងពេល និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យគឺលោកមានឈ្មោះបដិវត្តផ្សេងៗគ្នា។ អ៊ីចឹង ខ្ញុំចង់ដឹងថា នៅពេលដែលលោកនៅស្រុកចំការលើនោះ លោកប្រើឈ្មោះអី? ហើយចុះឈ្មោះ ស៊ូ សឿន នោះ ពេលនុ៎ងលោកស្គាល់ឈ្មោះគាត់ថាជា ស៊ូ សឿន អ៊ីចឹង ឬក៏មានឈ្មោះផ្សេង?

**ឆ៖** បាទ កាលឈ្មោះកំណើតគាត់ គឺឈ្មោះ ឃី ដល់ក្រោយមកគាត់ចូលទៅ ប្រាប់ថាឈ្មោះ សឿន ចេញឈ្មោះ សឿន មក។ ដូច កែ ពក ពីដើមឈ្មោះ កែ វិន ដល់ក្រោយបានឈ្មោះ កែ ពក បាទ ដូរឈ្មោះ។

[១១:១៨:៣២]

**ស៖** ខ្ញុំសួរប្រហែលជាមិនសូវច្បាស់។ ខ្ញុំសួរដំបូងគឺសួរលោក ចង់ពាក់ព័ន្ធឈ្មោះលោកផ្ទាល់នេះ ចង់ដឹងថាពេលដែលលោកនៅចំការលើហ្នឹង លោកប្រើឈ្មោះអី? ហើយពេលនុ៎ង ស៊ូ សឿនហ្នឹងហៅលោកឈ្មោះមួយណា?

**ឆ៖** បាទ កាលនៅស្រុកចំការលើ ដាក់ឈ្មោះ ហ៊ូ បាទ។

**ស៖** លោកច្បាស់ទេថានៅចំការលើហ្នឹងលោកមិនបានប្រើឈ្មោះថា តាផុស ទេ?

**ឆ៖** បាទ អត់ប្រើឈ្មោះ ផុស ទេ។

**ស៖** បន្ទាប់មកទៀតពេលលោកទៅដល់ស្រុកក្រូចឆ្មារ លោកនៅតែប្រើឈ្មោះ ហ៊ូ នេះដដែល ឬក៏លោកប្រើឈ្មោះ ផុស?

**ឆ៖** បាទ អត់ប្រើឈ្មោះ ហ៊ូ ទេបាទ កាលនោះ មានឈ្មោះមួយទៀត។ អ៊ីចឹង បានបងប្អូនថាឈ្មោះ ហ៊ូ នៅធ្នស់ ហើយនិងចំការលើ ឯឈ្មោះដែលនៅស្រុកក្រូចឆ្មារឈ្មោះ ហែម បាទ មិនមែនឈ្មោះ ហ៊ូ ទេបាទ។ ខ្ញុំមិនដែលប្រាប់ទេ ព្រោះថាសួរអ៊ីចឹងហើយ ទាល់តែខ្ញុំប្រាប់ថា ខ្ញុំមិនមែនឈ្មោះ ហ៊ូ ទេ។ ឈ្មោះ ហ៊ូ តែនៅធ្នស់ ហើយនៅចំការលើ។ ដល់ណោះប្រើឈ្មោះមួយទៀត។

[១១:២០:២៣]

**ស៖** លោកអាចបាន -- លោកអាចឆ្លើយបានទេ ហេតុអ្វីបានជាលោកប្តូរពេលដែលលោកទៅដល់ក្រូចឆ្មារនោះ?

**ឆ៖** បាទ មិនមែនដូរខ្លួនឯងបានទេ ព្រោះខាងលើឲ្យប្តូរហ្នឹង បាទ។

**ស៖** អ្នកណាជាអ្នកឲ្យលោកប្តូរឈ្មោះបដិវត្តនេះ? ហើយពេលគេឲ្យប្តូរនេះ គេមានប្រាប់ទេ ហេតុអ្វីបានជាត្រូវប្តូរឈ្មោះបែបនេះ?

**ឆ៖** បាទ គេប្រាប់ថា មិនបាច់ដាក់លេខទេ ដាក់ឈ្មោះ ប្រែឈ្មោះទៅ។ ដាក់លេខពិបាក។ ដាក់ឈ្មោះ ប្តូរទៅ។

**ស៖** ពេលដែលលោកឆ្លើយថា "គេប្រាប់ឲ្យលោកប្តូរឈ្មោះ" ហ្នឹង "គេ"ហ្នឹងជាអ្នកណា?

**ឆ៖** បាទ ប្អូនអឿន បាទ លេខាតំបន់ បាទ។

**ស៖** ខ្ញុំសួរសំណួរពាក់ព័ន្ធនឹងឈ្មោះរបស់លោកនេះ ពីព្រោះថានៅពេលបន្តិចទៀតនេះ ខ្ញុំនឹងនិយាយអំពីសាក្សីមួយចំនួនដែលនិយាយអំពីវត្តមានរបស់ប្រធានស្រុកឈ្មោះ ហ៊ូ នៅក្រូចឆ្មារ។ ខ្ញុំនឹងនិយាយនៅពេលបន្តិចទៀត ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំចង់និយាយអំពីចំណុចនេះ ពីព្រោះថាកាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ គឺមុនម៉ោងប្រាំបួន ហាក់សិបពីរនាទី គឺ ស៊ូ សឿន បាននិយាយអំពីលោក។ គាត់ចាំឈ្មោះលោកហ្នឹងគឺថាឈ្មោះ តាផុស។ ដូច្នេះសំណួរខ្ញុំៗចង់សួរលោកម្តងទៀតថា លោកច្បាស់ទេថា ស៊ូ សឿន ហ្នឹងមិនបាន<ស្គាល់លោកថា>ឈ្មោះ<> តាផុស ទេនៅពេលដែលលោកធ្វើការជាមួយគាត់នោះ?

**ឆ៖** បាទ ពេលនៅធ្វើការនៅស្រុក មិនមែនឈ្មោះ ផុស ទេ។ បាទ ឈ្មោះ ផុស ពេលខ្ញុំចូលព្រៃ ៧៩ បាន បងពក ឲ្យប្រែឈ្មោះមួយទៀត បាទ។

[១១:២២:៤២]

**ស៖** ខ្ញុំសួរលោកឲ្យបានច្បាស់ថា ក្រោយ៧៩នោះ <តើ>លោកបានជួប ស៊ូ សឿន <ទេ?>។ អ៊ីចឹង ពេលដែលជួបក្រោយឆ្នាំ៧៩ហ្នឹង គាត់ហៅឈ្មោះលោកហ្នឹងដដែលហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** គាត់អត់ហៅឈ្មោះ ហ៊ូ ទេ ហៅថា ផុសៗ តាមប្តីគាត់ បាទ។

**ស៖** ប្រហែលជាខ្ញុំអានឈ្មោះទៅ អាចនឹងធ្វើឲ្យលោកភាន់ច្រឡំខ្លះ។ <លោកបាននិយាយថា> នៅពេលដែលលោក<នៅភូមិភាគកណ្តាល [redacted]

[redacted] ហើយនៅពេលហ្នឹងគាត់បានសុំឲ្យលោកផ្តល់យោបល់។ អ៊ីចឹងខ្ញុំចង់សួរលោកថា នៅពេលណាមួយនោះ តើលោកធ្លាប់សហការគ្នាជា<មួយ>អ្នកមកពីតំបន់៤១ ក្នុងក្របខ័ណ្ឌនៃមុខងាររបស់លោក<ដែរទេ មិនថា>នៅក្នុងកងនេសាទ ឬក៏នៅពេលដែលលោកធ្វើជាអនុលេខាស្រុកចំការលើ? ឬក៏ពេលដែលលោកធ្វើជាលេខាស្រុកក្រូចឆ្មារនោះ?

**ឆ៖** បាទ អត់ដែលសហការទេ។ អត់បានធ្វើការជាមួយគ្នាទេ បាទ។

**ស៖** អ៊ីចឹង<នៅក្នុងលក្ខខណ្ឌនេះ តើត្រឹមត្រូវទេដែល>ខ្ញុំ<>និយាយ<>ថា ក្នុងនាមលោកដែលជាអ្នកធ្វើការនៅតំបន់៤២ នៅភូមិភាគកណ្តាល ហើយបន្ទាប់មកទៀត ធ្វើនៅក្រូចឆ្មារនោះ គឺលោកមិនដឹងអំពីរឿងរ៉ាវដែលបានកើតឡើងនៅតំបន់៤១ទេ។ <និយាយ>ជាទូទៅ <គឺថា>លោកមិនធ្លាប់ចូលរួមការប្រជុំអី<ពាក់ព័ន្ធ>នឹងតំបន់៤១ដែរ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ លោកត្រឹមត្រូវហើយ អត់ដែលធ្វើការជាមួយ -- អត់ដែលប្រជុំជាមួយ អត់ដែលប៉ានធ្វើជាមួយអីទេ បាទ។

**ស៖** <នៅពេលមួយនោះ> លោកបាននិយាយអំពីគណៈអចិន្ត្រៃយ៍<ភូមិ>ភាគ <តើ>លោកអាចជម្រាបបានទេថា អ្នកណាខ្លះជាសមាជិកគណៈអចិន្ត្រៃយ៍ភូមិភាគកណ្តាលនេះ<?> ហើយអ្នកណាជាអ្នកចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ភូមិភាគកណ្តាលនេះ?

**ឆ៖** បាទ គណៈភូមិភាគកណ្តាល មានគណៈតំបន់ គ្រប់តំបន់ ហើយនិងមានកម្មាភិបាលខ្លះដែលពេញសិទ្ធិថ្នាក់ខ្ពស់ចូលរួមក្នុងការប្រជុំនៅក្នុងថ្នាក់ភូមិភាគ។ ដូច្នេះមិនបានចូលរួមទេ ប៉ុន្តែគ្រាន់តែដឹងថា កាលភូមិភាគហ្នឹង គឺមានបងអាន ទេ ដែលចូលព្រៃហើយ បានដឹងថា បងអាន នេះជាគណៈអចិន្ត្រៃយ៍របស់ភូមិភាគ។ គាត់ទទួលតំបន់៤១ បាទ។

[១១:២៦:៣៩]

**ស៖** លោកដឹងទេថា អ្នកណាជាសមាជិកគណៈអចិន្ត្រៃយ៍ទទួលបន្ទុកតំបន់៤២?

**ឆ៖** បាទ ខ្ញុំបាទដឹងតែថា លេខាតំបន់មានតែ សំខាន់ជាងគេ គឺបងប៉ូច ហើយទៀត ដូចជាមិនដឹងជាអ្នកណាទេ ព្រោះមាន -- គាត់ទទួលស្រុកបារាយណ៍ ឯស្រុកព្រៃកប្រសប់ ក៏ខ្ញុំមិនស្គាល់ ស្រុកស្ទឹងត្រង់ ក៏ខ្ញុំអត់ស្គាល់ ស្គាល់តែស្រុកបារាយណ៍។ បងប៉ូច ហ្នឹង ស្គាល់ដែលទៅដល់ក្នុងព្រៃហើយបានតែការរៀបចំបងនេះជាអនុ ដូចថាសមរភូមិ ធ្វើអនុសមរភូមិ។

**ស៖** អ៊ីចឹងខ្ញុំយល់ត្រឹមត្រូវទេ គឺ<លោកកំពុងតែនិយាយពី>ឈ្មោះ<> ប៉ូច <ដែលលោក

និយាយ>កាលពីម្សិលមិញ គឺមុនម៉ោង -- ក្រោយម៉ោង ១០:១២នាទី <បន្តិច ហើយ>លោកបាននិយាយថា ប៉ូច មកពីនិរតី។ គឺគាត់មកក្រោយពេលដែលកម្មាភិបាលភូមិភាគកណ្តាល <និង>ភូមិភាគឧត្តរ<បានចេញផុតទៅ> អ៊ីចឹង<គាត់ប្រាកដ>ជា<ដឹងពីការចាប់ខ្លួន>កម្មាភិបាល<ទាំងនោះ> <ឬក៏គាត់>អាចដឹង<ថា>មន្ទីរសន្តិសុខនៅពេលនោះ<ស្ថិតនៅទីកន្លែងណាដែរ។> ហើយសហព្រះរាជអាជ្ញាសួរលោកថា ប៉ូច ហ្នឹងជាលេខាស្រុកបារាយណ៍ហ្នឹងមែនទេ ពេលនោះលោកឆ្លើយថា លោកមិនដឹងថា គាត់កាន់មុខងារហ្នឹង<នៅពេលណា>ទេ ក៏ប៉ុន្តែតើលោកអាចបញ្ជាក់បានទេថា ប៉ូច ហ្នឹងហើយមែនទេ ដែលជាលេខាស្រុកបារាយណ៍នោះ?

**ឆ៖** បាទ បងប៉ូច នេះជាលេខាស្រុកបារាយណ៍ ព្រោះតាមច្បាស់ ព្រោះថាសូម្បីតែកម្មាភិបាលខ្លះអ្នកស្រុកបារាយណ៍ គេស្គាល់គាត់ច្បាស់។ ដូចខ្ញុំស្គាល់គាត់ដែលចូលព្រៃហើយទេបានស្គាល់គាត់ពីដើមខ្ញុំមិនដែលបានស្គាល់ទេ ហើយមិនដែលបានប្រជុំជាមួយគាត់ទេ បាទ។

[១១:២៩:១១]

**ស៖** ដូច្នេះ បើខ្ញុំស្តាប់មិនច្រឡំទេ គឺលោកមិនដែលធ្លាប់ជួប ប៉ូច នេះទេ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះមែនទេ?

**ឆ៖** ក្នុងរបបហ្នឹង ជួបពេលចូលព្រៃ របបហ្នឹងដូចបញ្ចប់ ដូចចប់ទាល់តែឆ្នាំ៩៨ របបហ្នឹងធ្វើរហូតបាទ ជួបគ្នារហូតនៅក្នុងព្រៃ។

**ស៖** លោកបាននិយាយអំពីកម្មាភិបាលដែលស្គាល់គាត់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដែលនិយាយអំពីគាត់ប្រាប់លោក តើលោកដឹងទេថាកម្មាភិបាលហ្នឹងមានបានចូលរួមប្រជុំជាមួយនឹងគាត់ទេ។

**ឆ៖** លោក ខ្ញុំស្តាប់អត់ច្បាស់ តើសួរអំពីយ៉ាងម៉េច ខ្ញុំស្តាប់អត់ច្បាស់។

**ស៖** លោកបានឆ្លើយថា កម្មាភិបាលហ្នឹងនិយាយអំពីឈ្មោះ <ទេព ប៉ូច>។ អ៊ីចឹង ខ្ញុំចង់ដឹងថាកម្មាភិបាលទាំងអស់ហ្នឹង មានធ្លាប់បានចូលរួមប្រជុំជាមួយនឹងគាត់ទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំ<គ្រាន់តែ>ចង់<បញ្ជាក់>ឲ្យច្បាស់<។ តាមការបកប្រែ> សំណួរហ្នឹង គឺសំណួរសួរពី<>កែ ពក <ហើយខ្ញុំគិតថា សំណួរដែលសួរនោះ គឺសួរពីអ្នកផ្សេងដែល> ឈ្មោះ ប៉ូច ទេ ឥឡូវ មកចេញ កែ ពក។ តាមរយៈការបកប្រែជាអង់គ្លេសហ្នឹង ខ្ញុំឮ<ថា> កែ ពក ទៅវិញ។

[១១:៣១:០២]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមទោស ខ្ញុំ<នៅតែមានបញ្ហាចំពោះការបញ្ចេញសំឡេង គឺ>ហៅមិនសូវច្បាស់។ <ខ្ញុំនឹងប្រកបឈ្មោះហ្នឹងឲ្យច្បាស់សម្រាប់អ្នកបកប្រែ។ សូមអភ័យទោស> ខ្ញុំអានឈ្មោះហ្នឹង គឺខ្ញុំនិយាយអំពីឈ្មោះ ប៉ូច ទេ ដែលគាត់ជាលេខាស្រុកបារាយណ៍។

**ស៖** លោកសាក្សី លោកទើបតែបាននិយាយថា មានកម្មាភិបាលមួយចំនួនបាននិយាយអំពី ប៉ូច ហ្នឹង ប្រាប់លោក។ អ៊ីចឹងខ្ញុំចង់ដឹងថា កម្មាភិបាលដែលនិយាយប្រាប់លោកអំពី ប៉ូច ហ្នឹង គាត់ធ្លាប់ចូលរួមប្រជុំអ្វីជាមួយ ប៉ូច ហ្នឹងទេ?

**លោក បាន សៀក៖**

**ឆ៖** បាទ អ្នកធ្លាប់ចូលរួមប្រជុំ កម្មាភិបាលខ្លះដែលជាថ្នាក់ឃុំដែរ ដែលចូលព្រៃហើយ បាននិយាយពី ប៉ូច។ ការងាររបស់ ប៉ូច នេះ បាទ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំឃើញថា ដល់ម៉ោងសម្រាកហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សី មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និង

បង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:២២]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន អង្គជំនុំជម្រះសូមជម្រាបជូនក្រុមមេធាវីការពារក្តី រួមទាំងភាគីពាក់ព័ន្ធជ្រាបថា ដោយសារមានបញ្ហាធនធានអ្នកបកប្រែភាសាផ្ទាល់មាត់នៅរសៀលនេះមានកម្រិត ដូច្នេះសូមនិយាយឲ្យបានយឺតៗដើម្បីឲ្យដំណើរការប្រព្រឹត្តទៅនៃការបកប្រែភាសា ប្រព្រឹត្តទៅបានល្អ។

បាទ បន្តទៅនេះផ្តល់វេទិកាជូនក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរជាថ្មីម្តងទៀតលោក បាន សៀក។ ខ្ញុំបន្តសួរលោកទៀតនូវអ្វីដែលយើងបានសួរកាលពីពេលមុនពេលឈប់សម្រាក។ លោកបានឆ្លើយបញ្ជាក់ថា <ទេព> ប៉ូច ជាលេខាស្រុកបារាយណ៍ គឺ<>អ្នកដែល<ជា>កម្មាភិបាលផ្សេងទៀតនិយាយប្រាប់លោក។ តើលោកដឹងទេថា អឿនដែលជាបង<ប្អូនប្រុស>របស់ ស៊ូ សឿន ហើយនិងជាប្រធានតំបន់៤២ មានបានរៀបចំកិច្ចប្រជុំអីមួយ

ដែលនៅក្នុងពេលនោះ ប៉ូច ហ្នឹងដែលជាលេខាស្រុកបារាយណ៍ហ្នឹងមានវត្តមាន? លោកដឹងពីរឿងហ្នឹងទេ?

[១៣:៣៥:៤៤]

**លោក បាន សៀក៖**

**ឆ៖** ពេលប្រជុំតំបន់ម្តងៗ គឺមានលេខាស្រុកហ្នឹងមកចូលរួមជាប់បាទ។

**ស៖** នៅពេលដែលលោកធ្វើជាអនុលេខាស្រុកចំការលើ តើលោកធ្លាប់ចូលរួមក្នុងកិច្ចប្រជុំណាមួយដែលដឹកនាំដោយឈ្មោះ អឿន ជាប្រធានតំបន់៤២ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ចូលរួមប្រជុំ ក៏ប៉ុន្តែមិនដែលចូលរួមជាមួយ បងប៉ូច ទេ។ ចូលប្រជុំ គាត់ធ្វើប្រជុំធ្វើផែនការប្រាប់ ធ្វើផែនការអី ធ្វើអីក្រែងខុសក្រែងត្រូវនៅចំការលើ។ ការពិតការប្រជុំគណៈតំបន់អចិន្ត្រៃយ៍ តែលេខាស្រុកទេបាន។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ទំព័រទី១នៃចម្លើយរបស់សាក្សី 2-TCW-850 គឺឯកសារលេខ E3/5293។ ខ្ញុំនឹងលើកឡើងអំពីខ្លឹមសារនៃចម្លើយនេះ ដោយមិនបញ្ចេញឈ្មោះសាក្សីនោះជាសាធារណៈនោះទេ។ ដូច្នេះសូមលោកប្រធានមេត្តាអនុញ្ញាតឲ្យមន្ត្រីតុលាការប្រគល់ទំព័រទី១នៃឯកសារនេះជូនទៅសាក្សី។ ខ្ញុំចង់សួរសំណួរក្រោយពេលដែលគាត់អាននូវខ្លឹមសារហើយ ហើយសូមឲ្យលោកសាក្សីកុំបញ្ចេញឈ្មោះឲ្យសោះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៣:៣៨:១០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី ខ្ញុំប្រគល់ជូនទំព័រទី១ នៃកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយរូបដែលខ្ញុំចង់សួរសំណួរទៅលោក។ សាក្សីនេះគឺ<បាន>មកផ្តល់សក្ខីកម្ម<នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ>។ អ៊ីចឹងសូមលោកកុំបញ្ចេញឈ្មោះគាត់<នៅពេលដែលលោកឆ្លើយសំណួររបស់ខ្ញុំ>។

តើលោកស្គាល់ឈ្មោះសាក្សីហ្នឹងទេ ខ្ញុំបានគូសពណ៌ហ្នឹង? លោកឃើញឈ្មោះទេ ឈ្មោះដែលខ្ញុំគូសពណ៌ពីខាងក្រោមហ្នឹង ហើយសូមកុំអានឈ្មោះនេះឲ្យឮ<ជាសាធារណៈ>ឲ្យសោះ។ សូមឲ្យ

មេធាវីប្រឹក្សាជួយប្រាប់គាត់ផង។

**លោក បាន សៀក៖**

**ឆ៖** បាទ នេះហើយជាលេខាស្រុកបាទ។

**ស៖** ខ្ញុំសូមផ្តល់លេខ ERN ជាភាសាបារាំងគឺ <00367749>, ជាភាសាខ្មែរគឺ 00348842, និងបន្ត<ទៅ>ទំព័របន្ទាប់មកទៀត ERN ជាភាសាអង់គ្លេសគឺ 00351703។ នេះជាចម្លើយរបស់សាក្សីរូបនោះ "គេបានកោះខ្ញុំឲ្យទៅប្រជុំម្តងនៅចំការលើនៅខេត្តកំពង់ចាម។ គឺអឿន មកពីថ្នាក់តំបន់ជាអ្នកដឹកនាំកិច្ចប្រជុំនេះ។ ក្នុងពេលប្រជុំ ថ្នាក់លើបានដាក់ផែនការឲ្យធ្វើស្រែ ប៉ុន្តែមិនមានការដាក់ផែនការក្នុងការបោសសម្អាតខ្មាំងនោះទេ។ នៅពេលដែលខ្ញុំមកកាន់ស្រុកបារាយណ៍ មានការចេញឯក-សារមួយណែនាំក្នុងការការពារព្រំដែន ការពារបដិវត្តន៍។ ម្យ៉ាងវិញទៀតក៏មានការចេញឯកសារមួយ<ទៀត បញ្ជាឲ្យប្រព្រឹត្តដោយក្តីគោរព>ចំពោះអ្នក១៧មេសា <និងមិនត្រូវធ្វើការបែងចែករវាង>អ្នកថ្មីនិងអ្នកចាស់ទេ។" សូមបញ្ចប់ការដកស្រង់។ លោកសាក្សី សំណួរទី១របស់ខ្ញុំពាក់ព័ន្ធទៅនឹងចំណុចនេះ ខ្ញុំចង់ដឹងថា លោកនៅចាំទេ នៅពេលដែលលោកធ្វើការនៅចំការលើ ទោះបីជាលោកមិនបានចូលរួមក្នុងកិច្ចប្រជុំហ្នឹងក៏ដោយ លោកធ្លាប់ស្តាប់ឮគេនិយាយអំពីកិច្ចប្រជុំមួយដែល អឿន ជាអ្នកដឹកនាំ ហើយនៅក្នុងពេលប្រជុំនោះគេបានលើកផែនការធ្វើស្រែ ហើយគេមានបង្ហាញឯកសារមួយពេលប្រជុំនោះ គឺឯកសារហ្នឹងគឺថាហាមមិនឲ្យរើសអើងចំពោះអ្នក១៧មេសា មិនឲ្យមានអ្នកចាស់អ្នកថ្មីទេ។ លោកធ្លាប់ឮពីកិច្ចប្រជុំមួយនេះទេ? ឬក៏លោកធ្លាប់ចូលរួមកិច្ចប្រជុំណាមួយដែលលើកនិយាយអំពីប្រធានបទស្រដៀងគ្នានេះទេ?

**ឆ៖** បាទមានលោក កាលពីខ្ញុំមកពីក្រូចឆ្មារមក ចេញឯកសារនេះ ហៅឯកសារសង្គ្រោះ ពេលហ្នឹងឯកសារហ្នឹងថា ឈប់មានការកាប់សម្លាប់ទៀតហើយ បាទ។ ហើយខំបង្កបង្កើនផលឲ្យបានហូបបាយហូបបបរអីហ្នឹង មានឯកសារហ្នឹង ខ្ញុំធ្វើក៏ខាងលើនិយាយអីចឹងដែរ អត់មានការ -- ប៉ុន្តែខ្ញុំមកមកវិញហើយ មកពីក្រូចឆ្មារហើយ បានឃើញឯកសារនោះ។

[១៣:៤៣:០២]

**ស៖** ក្នុងការបកប្រែជាភាសាបារាំង ខ្ញុំស្តាប់ឮថា ឯកសារហ្នឹងគឺណែនាំឲ្យ<លោក>ធ្វើការសម្លាប់មនុស្ស។ ខ្ញុំស្តាប់អីចឹងត្រឹមត្រូវទេ ឬក៏ជាបញ្ហានៃការបកប្រែ?

**ឆ៖** អត់មានការសម្លាប់មនុស្សទេពេលហ្នឹង ឯកសារសង្គ្រោះ លែងសម្លាប់ហើយ បាទ។

**ស៖** ដូច្នេះឯកសារនុ៎ង គឺគេហាមលែងឲ្យសម្លាប់មនុស្សទៀតហើយ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ លោក។

**ស៖** លោកបានឃើញឯកសារហ្នឹងដោយផ្ទាល់ភ្នែកទេ?

**ឆ៖** បាទ ខ្ញុំអត់បានឃើញឯកសារទេ ប៉ុន្តែ អឿនប្រជុំ – អឿន ប្រជុំមួយ ខ្ញុំបានចូលទៅស្តាប់ដែរ ដោយមាន កាលនោះ ដូចមានគ្រូបង្រៀនខ្លះ ចូលទៅ បានចូលទៅស្តាប់ដែរ ថាឥឡូវឈប់សម្លាប់ហើយ គ្រូមានសល់ប៉ុន្មាន សល់ទាំងអស់វិញហើយ។ បាន ប៉ុណ្ណឹងលោក។ អត់បានមើលឯកសារទេ ប៉ុន្តែគេសរសេរឲ្យយើងកត់ ប៉ុន្តែភ្លេចអស់ហើយលោក។

**ស៖** សំណួរដែលត្រូវបានសួរទៅកាន់សាក្សីនៅក្នុងឯកសារ E3/5293 គឺនៅទំព័រដដែលថា៖ "តើលោកបានឃើញឯកសារសារាចរហ្នឹងដែរឬទេ? នៅពេលហ្នឹងគាត់ឆ្លើយថា៖ ខ្ញុំបានឃើញឯកសារសារាចរនេះ ហើយខ្ញុំបានរៀនទៀតផង។ ខ្ញុំមិនដឹងថាចេញពីថ្នាក់ណានោះទេ។ គឺឯកសារនោះជាសៀវភៅតែម្តង។" សូមបញ្ចប់ការដកស្រង់។ តើ អឿន ហ្នឹងមានបានប្រាប់លោកថា ឯកសារសារាចរហ្នឹងចេញមកពីខាងណាទេ? នេះជាសំណួរដំបូងពាក់ព័ន្ធនឹងចំណុចនេះ។ ពេលដែលគាត់និយាយអំពីឯកសារសារាចរហ្នឹង គាត់មានប្រាប់លោកថាឯកសារហ្នឹងចេញមកពីថ្នាក់ណាទេ?

**ឆ៖** តាមគាត់ប្រាប់ ថាចេញមកពីលើ ថ្នាក់ផ្សេងលើពីថ្នាក់ដឹកនាំ ដូចជាលេខ៨៧០ អ៊ីចេះមិនដឹង ខ្ញុំមិនចាំលេខទេលោកស្រី។ ចេញមកពីលើមក ឯកសារសង្គ្រោះហ្នឹង។

**ស៖** នៅពេលដែលលោកនិយាយថាប្រហែលជាមកពីមន្ទីរ ៨៧០ហ្នឹង មានន័យថាលោកមិនដឹងច្បាស់ទេ<ឬ?> អ៊ីចឹងលោកគិតមើលឲ្យបានច្បាស់ទៅមើល លោកចាំថាពេលនោះ អឿន គាត់បាននិយាយ<ប្រាប់លោក>អ្វីខ្លះ<ឲ្យប្រាកដ>? <បើសិនជាលោកមិនចាំបានទេ សូមកុំប្រឌិតរឿង។ ខ្ញុំគ្រាន់តែចង់ដឹងថាតើ អឿន បានប្រើ>ពាក្យសម្តី<អ្វីខ្លះ>ពេលនុ៎ង? <តើលោកចាំបានទេ?>

**ឆ៖** ខ្ញុំមិនបានចាំទេ។

[១៣:៤៦:៣៧]

**ស៖** លោកបាននិយាយអំពីមុខងារ <និងទំនួលខុសត្រូវ>របស់លោកជាអនុលេខាស្រុកចំការលើ។ តើនៅក្នុងមុខងាររបស់លោកជាអនុលេខាស្រុកនេះ លោកកាន់ខាងការរៀបអាពាហ៍ពិពាហ៍ទេ?

**ឆ៖** បាទ អត់ទេ ទាន។

**ស៖** តើលោកធ្លាប់ចូលរួមក្នុងការរៀបអាពាហ៍ពិពាហ៍ទេ ទោះបីជានៅក្នុងក្របខ័ណ្ឌមុខងារ ឬ

ក៏ក្រៅមុខងាររបស់លោកក៏ដោយហ្នឹង?

**ឆ៖** បាទ ធ្លាប់។

**ស៖** លោកដឹងទេថា អ្នកណាជាអ្នកទទួលបន្ទុក ឬក៏ទទួលខុសត្រូវខាងរៀបអាពាហ៍ពិពាហ៍នេះ?

**ឆ៖** តាមការពិត នៅក្នុងអង្គភាពមួយៗ ដែលស្នើរៀបអាពាហ៍ពិពាហ៍ គឺថាអត់មានរៀបម្នាក់ទេ ដូចថារៀបច្រើន គេប្រមូលច្រើនគូ ១០គូ ២០គូ អ៊ីចឹងទៅ ស្នើទៅលើទៅរៀបដោយអង្គភាពទទួលខុសត្រូវដោយខ្លួនឯង។

**ស៖** សាក្សីដែលនៅក្នុងឯកសារ E3/5293 គឺនៅ ERN 00367751 ជាភាសាបារាំង, ជាភាសាខ្មែរគឺ 00348844, ERN ជាភាសាអង់គ្លេស 00351705។ គេសួរសាក្សីរូបនោះនៅពេលនោះថា៖ "អ្នកណាជាអ្នកអនុញ្ញាតឲ្យរៀបការ?" គាត់បានឆ្លើយថា៖ "នៅពេលមានការប្រជុំថ្នាក់ស្រុក ថ្នាក់ឃុំ រួមគ្នា គឺគេនឹងធ្វើការសម្រេចអំពីការរៀបការនេះ<ដោយផ្អែកទៅលើលក្ខខណ្ឌមួយចំនួន>។ ការធ្វើ -- ការរៀបការគឺធ្វើឡើងដោយយោងទៅលើទី១ អាយុ ចំពោះស្ត្រីគឺត្រូវមានអាយុ១៨ឆ្នាំឡើង។ ទី២ គឺអ្នកទាំងពីរស្រឡាញ់គ្នាស្មោះស្ម័គ្រ។ និងទី៣ មានការយល់ព្រមពីឪពុកម្ដាយ។" សូមបញ្ចប់ការដកស្រង់។ តើ<ក្រៅពីការរៀបចំការរៀបការនៅតាម>ស្រុក ឬ<>ឃុំដែលលោកធ្លាប់ចូលរួមនោះ<តើ>លោកមានចាំថាមាន<បានចូលរួមប្រជុំណាមួយ ដែល>ពិភាក្សាគ្នាបែបនេះដែរឬទេ ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍នោះ? គឺប្រសិនបើលោកចាំ សូមប្រាប់ថាលោកចាំ។ បើមិនចាំ គឺមិនចាំ។ សូមលោកកុំឆ្លើយព្រាវ។

**ឆ៖** ខ្ញុំបាទ មិនចាំទេ កាលនិយាយបកស្រាយ បាទ។

[១៣:៥០:០៩]

**ស៖** ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពី<>ពាក្យពេចន៍មួយចំនួនដែលលោកបានប្រើប្រាស់ហើយ<វា>ជា<ឯកសារ>ភាសាបារាំង<ដែលខ្ញុំមានចំពោះមុខ។ ខ្ញុំមិនច្បាស់ថា មានការបកប្រែត្រឹមត្រូវដែរឬទេ>។ នៅក្នុងឯកសារ E319/19.3.73, ERNជាភាសាបារាំង 00841972, ERN ជាភាសាខ្មែរ 00800956, ជាភាសាអង់គ្លេស គឺ 00841967។ នៅក្នុងកំណត់ហេតុនោះលោកបាននិយាយអំពីការចាប់ខ្លួនដែលបានកើតឡើងនៅក្នុងស្រុកក្រូចឆ្មារ នេះជាចម្លើយរបស់លោកនៅពេលនោះ "នៅពេលនោះឃុំជាអ្នកចាប់បញ្ជូនមនុស្សមកឲ្យស្រុក ហើយស្រុកបញ្ជូនសំណុំរឿងទៅឲ្យ<កម្មាភិបាលនៅថ្នាក់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

>តំបន់ <បន្ទាប់មកតំបន់>ក៏បញ្ជូនទៅ<កម្មាភិបាលនៅ>ភូមិភាគ រួចភូមិភាគបញ្ជូនទៅ" -- <ការបកប្រែជាភាសាបារាំងគឺ> "គណៈមជ្ឈិម" ក៏ប៉ុន្តែជាភាសាខ្មែរហ្នឹងគឺ "មជ្ឈិម" ទេ <គឺលោកបានប្រើពាក្យនេះដែលមានន័យថា "*សិទធ័រ*">។ តើលោកអាចបញ្ជាក់បានទេ <តើពាក្យថា> "មជ្ឈិម" <ពិតជាមានន័យថា "*សិទធ័រ*" មែនដែរឬទេ?> ហើយ<ដើម្បីឲ្យច្បាស់ជាងនេះ> តើពាក្យ "<*សិទធ័រ*>" នេះ មានន័យថាយ៉ាងម៉េចដែរចំពោះលោក?

**ឆ៖** មជ្ឈិម គឺថ្នាក់ខ្ពស់បំផុតថ្នាក់ខាងលើ ថ្នាក់ដឹកនាំខាងលើខ្ពស់បំផុត។

**ស៖** ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ លោកដឹងទេថា <តើ>មជ្ឈិម<ជាអ្វីទេ? តើនរណាខ្លះជាសមាជិកមជ្ឈិមនេះ> ឬក៏គ្រាន់តែជាពាក្យទូទៅ<ដែល>គេ<ប្រើនៅពេលនោះ>?

**ឆ៖** បាទ ឲ្យតែខាងលើដូចជាអ៊ំប៉ុល ពត, អ៊ំនួន ជា អី, អ៊ំអៀង សារី អី គាត់ថ្នាក់មជ្ឈិមហើយបាទ។

**ស៖** នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ លោកធ្លាប់ជួបអ្នកណាម្នាក់នៅពេលណាមួយទេនៅក្នុងចំណោមអ្នកទាំងបីដែលលោករៀបរាប់អម្បាញ់ហ្នឹង?

**ឆ៖** បាទ លោក អត់ដែលបានជួបសោះ។

[១៣:៥៣:៣៥]

**ស៖** តើលោកដឹងទេថាមជ្ឈិម<ឬក៏ថ្នាក់កំពូល>ចេញសេចក្តីសម្រេចយ៉ាងម៉េច<ដែរឬទេ> គេសម្រេចយ៉ាងម៉េចនៅថ្នាក់មជ្ឈិមហ្នឹង?

**ឆ៖** ខ្ញុំភ្លេចអស់ហើយនិយាយមិនកើត ដូចថាសរសេរឯកសារឡើងវិញ ការសម្រេចគឺថាខ្ញុំនិយាយមិនកើត មិនចេះនិយាយ ពាក្យពីដើមសរសេរ ខ្ញុំមិនចេះនិយាយទេ និយាយមិនកើតលោក។

**ស៖** ខ្ញុំមិនសុំឲ្យលោកផ្តល់យោបល់អ្វីទេ <>ខ្ញុំសួរលោក<ឲ្យលោកប្រាប់>ពីអ្វីដែលលោកដឹង។ អម្បាញ់មិញនេះ ខ្ញុំសួរលោកធ្លាប់ចូលរួមក្នុងកិច្ច<ប្រជុំនៅគណៈ>អចិន្ត្រៃយ៍<នៅភូមិ>ភាគទេ លោកថាអត់ទេ ហើយលោកបានឆ្លើយជាច្រើនជូនទៅលោកមេធាវី កូប៉េ លោកថាមានព័ត៌មានមួយចំនួនលោកមិនដឹងទេ។ អ៊ីចឹងខ្ញុំគ្រាន់តែសុំឲ្យលោក<ឆ្លើយទៅនឹងសំណួររបស់ខ្ញុំ>តាមការដែលលោកដឹង បើលោកដឹង លោកឆ្លើយថាដឹង បើមិនដឹង ឆ្លើយថាមិនដឹងទៅមិនអីទេ។ ដូច្នេះអម្បាញ់មិញនេះសំណួររបស់ខ្ញុំៗចង់ដឹងថា លោកដឹងទេថា ៨៧០ ឬមន្ទីរ៨៧០ ហ្នឹងជាអ្វី<ទេ ដោយសារលោកបាននិយាយអំពីវានៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក>?

**ឆ៖** បាទ មន្ទីរ៨៧០ ហ្នឹង គឺថ្នាក់មជ្ឈិមហើយ ហៅ ថ្នាក់មជ្ឈិម៨៧០ ខាងលើបាទ។

**ស៖** ដូច្នេះ តើត្រឹមត្រូវទេ បើខ្ញុំនិយាយថាលោកមិនដឹងថា មន្ទីរ៨៧០ហ្នឹងមាន<សមាជិក> ប៉ុន្មាននាក់ទេ? ហើយក៏លោកមិនដឹងថា តើ<មន្ទីរ>៨៧០ហ្នឹងជាអ្វី<ឲ្យប្រាកដ>ដែរ<នៅពេលដែល> លោក<>ឮគេនិយាយ៨៧០អ៊ីចឹង តែមិនដឹងថា ជាអីទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ លោក។

**ស៖** ប្រសិនបើខ្ញុំនិយាយថា មេផ្ទាល់របស់លោកនៅពេលដែលលោកនៅស្រុកចំការលើនោះ គឺលេខាស្រុក។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ មេផ្ទាល់របស់លោកហ្នឹង គឺលេខាស្រុក?

**ឆ៖** បាទ មេផ្ទាល់របស់ខ្ញុំ គឺបង ស៊ូ សឿន ជាលេខាស្រុក។

[១៣:៥៦:៤៣]

**ស៖** ដូច្នេះ ខ្ញុំអាចនិយាយបានទេថា ក្រៅពីការសន្ទនាគ្នាជាមួយ សុន សេន ទៅលើប្រធានបទនៃការតែងតាំងលោកឲ្យធ្វើ<ការជាមួយ កែ ពក> គឺថាលោកអត់មានបាននិយាយអីទៀតទេ ជាមួយនឹង សុន សេន<?> ខ្ញុំស្ដាប់អ៊ីចឹងត្រឹមត្រូវទេ ឬក៏ខ្ញុំច្រឡំ?

**ឆ៖** អត់ទេលោក។ អត់បាននិយាយជាមួយ សុន សេន ទេ គឺការចាត់តាំងពីភូមិភាគឧត្ដរតំបន់៤២ គឺ អឿន អ្នករៀបចំឲ្យទៅទទួលស្រុកក្រូចឆ្មារ ដល់ទៅនៅឯហ្នឹង គឺយើងទៅទទួលតាមខ្សែបណ្ដោយ គឺទៅតាមរយៈ រិន និង សុន សេន បាទ។

**ស៖** តាមរយៈសក្ខីកម្មរបស់លោក ខ្ញុំយល់ថា លោកបានជជែកគ្នាផ្ទាល់ជាមួយ សុន សេន ហើយក្នុងពេលនិយាយគ្នានុ៎ង គាត់បាននិយាយអំពីជោគវាសនារបស់បង<ប្អូនប្រុស>លោក ហើយ <គាត់>បាននិយាយថា លោកអត់បាន<បញ្ជាក់ការពិតទាំងអស់>នៅក្នុងប្រវត្តិរូប<របស់លោកទេ ហើយគ្មានអ្វីដែលត្រូវ>ភ័យ<នោះទេ ហើយ>ឲ្យ<លោក>ទៅធ្វើការជាមួយ កែ ពក <វិញ>។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ ព្រោះពេលនោះ ឲ្យធ្វើប្រវត្តិរូបពីស្ដាពីរដង។ ទៅរៀនម្ដងធ្វើម្ដងៗទៀត ដល់ធ្វើលើកនេះ ប្រវត្តិរូបហ្នឹងប្អូនសម្លាប់ហើយ ប្អូនធ្វើប្រវត្តិរូបដាក់មកខ្ញុំ ដាក់មកប្អូនមួយដែលសម្លាប់ថា បក្សសម្លាប់ ហើយខ្ញុំធ្វើថាអត់សម្លាប់ ថាបាត់ខ្លួន។ ដល់ទៅគាត់ថា មិត្តឯងកុហក ប្អូនគេសម្លាប់ថានៅ -- ថាបាត់ខ្លួន។ ខ្ញុំថាបែកតាំងពីអាយុ១៧ឆ្នាំ ខ្ញុំមានប្រពន្ធទៅ ១៧-១៨នោះ ខ្ញុំមិនដឹងដែរ។ ដូច្នេះដល់គាត់ថា ឥឡូវប្អូនមិត្តឯងខាងមុខគេកម្ទេចហើយ ដល់អ៊ីចឹងខ្ញុំបះជើងតែម្ដងបាទ គាត់សម្លឹងមុខថា

មិត្តកុំភ័យ មិត្តឯងទៅនៅជាមួយមិត្ត ពក មិត្ត អឿន វិញទៅ។ ប៉ុណ្ណឹងឯងលោក។

[១៣:៥៩:១២]

**ស៖** ដូច្នេះ ខ្ញុំសួរចង់ដឹងថា តើការនិយាយគ្នាជាមួយ សុន សេន ហ្នឹង គឺមានតែម្តងហ្នឹង<គត់តើ>មែនទេ?

**ឆ៖** ពីរដង។ ម្តងប្រជុំធ្វើផែនការ មកធ្វើប្រមូលប្រជាជនទៅការដ្ឋាន និងរើសកងទ័ពម្តង។ ម្តងទៀតបានប្រហែលជាមួយខែមិនដល់ផង ហៅទៅម្តងទៀត ដល់ធ្វើប្រវត្តិរូបរៀនសូត្រជាមួយគេទាំងអស់គ្នាហ្នឹង ធ្វើរួច គាត់ហៅចូលបន្ទប់ហើយនិយាយប្រាប់ ចង្អុលមុខថា "មិត្តឯងធ្វើប្រវត្តិរូបកុហក"។ បាទ ខ្ញុំភ័យដែរ ដល់តែពេលនេះ បានគាត់ប្រាប់ថា ប្អូនមិត្តឯងគេកម្ទេចហើយ។ ហើយខ្ញុំបះជើងកៅអីទៅ គាត់មើលមុខ ភ័យពេក ហើយគាត់ថា "កុំភ័យមិត្តឯងទៅនៅជាមួយ មិត្តពក មិត្តអឿនវិញទៅ"។

**ស៖** ដូច្នេះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺលោកបាននិយាយគ្នាជាមួយ សុន សេន តែពីរដងគត់ អ៊ីចឹងមែនទេ?

**ឆ៖** បាទ លោក។

**ស៖** ឥឡូវនេះ ខ្ញុំនឹងចូលទៅនិយាយអំពីពេលវេលា ដែលលោកត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅស្រុកក្រូចឆ្មារ បើសិនជាខ្ញុំស្តាប់ចម្លើយរបស់លោកមិនច្រឡំទេ គឺលោកឆ្លើយថា ការចាត់តាំងនេះ គឺអឿន ជាអ្នកចាត់តាំងលោក។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយលោក។

**ស៖** ហើយ អឿន នេះហើយ ជាអ្នកប្រាប់ឱ្យប្តូរឈ្មោះបដិវត្តន៍ ពេលដែលលោកទៅដល់ភូមិភាគបូព៌ា។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពេលនោះ អឿន ថាឱ្យដូរឈ្មោះទៅ ទៅដល់នោះ។ ទៅគាត់ប្រាប់គួរធ្វើអ៊ីចេះៗទៅ។

**ស៖** អម្បាញ់មិញនេះ លោកបានប្រាប់ឈ្មោះ ប៉ុន្តែខ្ញុំភ្លេចទៅហើយ។ សូមលោកប្រាប់ឈ្មោះម្តងទៀតមើល លោកប្រើឈ្មោះអី ពេលដែលលោកទៅដល់ភូមិភាគបូព៌ានោះ?

[១៤:០១:៤៤]

**ឆ៖** បាទ ពីដើមខ្ញុំឈ្មោះ ហូ។ ដល់ពេលភូមិភាគបូព៌ា ខ្ញុំឈ្មោះ ហែម – ហង្ស ហែម។

**ស៖** អ៊ីចឹងលោកណែនាំអ្នកនៅក្រោមបង្គាប់លោកហ្នឹង ប្រាប់ពួកគេថាលោកឈ្មោះ ហែម

អ៊ីចឹងមែនទេ?

**ឆ៖** ប្រជុំ វាឲ្យទៅពីរបីនាក់ហ្នឹង ប្រាប់ថា អើ មិត្តហែម ទៅទទួលស្រុកក្រូចឆ្មារវើយ នរណាទៅ ខ្លះមិត្តខិ មិត្តអួន មកប្រជុំគ្នាឲ្យទៅបាទ។

**សះ** ពេលដែលលោកថា លោកមានគ្នាច្រើនហ្នឹង តើអ្នកខ្លះទៀត ត្រូវបានចាត់តាំងក្នុងពេលជាមួយគ្នានឹងលោកនោះ?

**ឆ៖** ដូចឈ្មោះខិ ឈ្មោះអួន ដែលចាត់តាំងពីភូមិភាគកណ្តាលទៅ ពីតំបន់៤២ បីនាក់ទៅហ្នឹង ហើយកងទ័ពបីនាក់ នីរសារម្នាក់មួយៗ។

**សះ** យើងបានស្តាប់សាក្សីមួយចំនួននៅក្នុងតុលាការនេះ ដែលបានលើកឡើងអំពីការចាប់ខ្លួនមនុស្សជាច្រើន និងក៏បាននិយាយអំពីការឃុំខ្លួនជនជាតិចាម នៅភូមិទ្រា។ ចុះលោកផ្ទាល់ លោកធ្លាប់ឮគេនិយាយអំពីការចាប់ខ្លួនជនជាតិចាមជាច្រើននៅភូមិទ្រាដែរឬទេ? ហើយខ្លួនលោកផ្ទាល់នោះ លោកមានធ្លាប់បានបញ្ជាឲ្យចាប់ឃុំខ្លួនជនជាតិចាមនៅភូមិទ្រាទេ?

**ឆ៖** បាទ ខ្ញុំបាទបានឆ្លើយហើយថា កាលនោះគ្រាន់តែរៀបចំអំពីការបះបោររួច ខ្ញុំបាទបានឡើងទៅរៀនសូត្រ រៀនសូត្រហើយ សុន សេន បានធ្វើផែនការឲ្យមកសមរភូមិ ឲ្យបង្កបង្កើនផលដើម្បីរៀបចំប្រមូលប្រជាជនឲ្យបង្កបង្កើនផល និងប្រមូលកងទ័ពដើម្បីបញ្ជូនទៅមុខ ព្រោះសភាពការណ៍ដុនដាប ពេលនោះ ខ្ញុំបាទមិនបានគិតអំពីការសម្លាប់អីនោះទេ ព្រោះខ្ញុំបាទមិនបានដឹងទេបាទ។

[១៤:០៤:៥៧]

**សះ** នៅក្នុងកំណត់ហេតុមួយ<ដែលគាត់បានផ្តល់នៅក្នុងសវនាការថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥> លោក អ៊ីត សេន គឺឯកសារ E1/343.1 គឺក្រោយម៉ោង <១១:១៩:០៦> នាទីបន្តិច<នៅពេលព្រឹក> គាត់បានបញ្ជាក់អំពីចម្លើយមុនៗរបស់គាត់ គឺគាត់ឆ្លើយនៅពេលនោះថា មានឈ្មោះ សេង ដែលជាមេឃុំ និងជាប្រធានឃោធាឃុំ។ តើលោកចាំឈ្មោះ សេង នៅក្នុងឃុំណាមួយនៃស្រុកក្រូចឆ្មារដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទមិនចាំ ហើយក៏មិនស្គាល់ទេ បាទ។

**សះ** មុននឹងនិយាយអំពី<សាក្សី>ជនជាតិចាម<ផ្សេងទៀត> ដែលបានផ្តល់សក្ខីកម្មនៅក្នុងតុលាការនេះ ខ្ញុំចង់បានការបញ្ជាក់ពីលោក ពាក់ព័ន្ធនឹងរយៈពេលដែលលោកទៅដល់ស្រុកក្រូចឆ្មារ។ លោកបាននិយាយជាច្រើនដងថា ស្ថានភាពវាច្របូកច្របល់។ ជាដំបូងនោះ គឺលោកនិយាយ<រឿង

នេះ>ជាមួយសហព្រះរាជអាជ្ញា បន្ទាប់មក លោកនិយាយជាមួយនឹងលោកមេធាវី កូប៉េ។ លោកថា មានហេតុការណ៍មួយដែលឈ្លបម្នាក់បានលបបាញ់ជំនួយការរបស់លោក។ <ដូច្នេះសំណួរទី១ របស់ខ្ញុំ គឺ តើ>លោកអាចជម្រាបបានទេ ជំនួយការរបស់លោកដែលត្រូវ<>របួសនោះ ឈ្មោះអី? ហើយគេបាញ់ឲ្យរបួសនោះនៅពេលណាឲ្យប្រាកដនោះ?

[១៤:០៧:២៣]

**ឆ៖** បាទ អ្នកដែលបាញ់នោះ ឈ្មោះ ឱ អនុស្រុក។ គេបាញ់តាមមាត់ទន្លេ។ ខ្ញុំមិនដឹងខែ មិនដឹងថ្ងៃទេ គឺបាញ់នៅពេលល្ងាច។

**ស៖** ក្នុងឋានៈជាលេខាស្រុក ពេលដែលលោកទៅដល់នោះ លោកមានកាន់ខាងឈ្លប ឬកាន់ខាងយោធាស្រុកទេ?

**ឆ៖** បាទ ពេលនោះ អត់មានកាន់ទេ។ ព្រោះទៅដល់ហ្នឹង ការរៀបចំហ្នឹង កងទ័ពយកទៅវាតិច ឯកងទ័ពរបស់មជ្ឈិមមកជួយធ្វើការ បាទ ជួយធ្វើការ គឺសហការជាមួយគ្នា ដើម្បីរៀបចំពង្រឹងរដ្ឋអំណាច។ គ្រាន់តែមានការបះបោររួច មួយរយៈហ្នឹង គឺខាងលើហៅទៅជួបហើយ ហៅទៅធ្វើការដើម្បីរៀនសូត្រ រៀនសូត្រហើយ ដាក់ផែនការមកថា សភាពការណ៍វិវត្តន៍តឹងតែងហើយ កាលនោះ ខ្ញុំចង់និយាយថា គាត់សួរថា៖ “មិត្តហែម បើយើងចាញ់គេ យើងទៅណា?” ខ្ញុំថា៖ “ទៅថៃ”។ គាត់ថា៖ “ថៃណា បើយើងវៃថៃដែរ?” “មិនដឹងទៅណាអ៊ីចឹង”។ បាទ ប៉ុណ្ណឹងឯង។

**ស៖** ដូច្នេះ ប្រសិនបើខ្ញុំស្ដាប់មិនច្រឡំទេ នៅពេលដែលលោកនិយាយអំពីស្ថានភាពច្របូកច្របល់នោះ លោកមិនត្រឹមតែនិយាយអំពីការរត់គេចរបស់ សោ ភឹម <ឬ>ជា ស៊ីម ចូលទៅខាងវៀត-ណាមទេ គឺលោកសំដៅផងដែរ ទៅលើការវាយប្រយុទ្ធគ្នា មែនទេ នៅពេលដែលលោកនិយាយថា មានការច្របូកច្របល់នោះ?

[១៤:០៩:៣១]

**ឆ៖** បាទ ពេលនោះ បងខ្ញុំ ត្រូវជីទូតមួយខាងប្រពន្ធ បានប្រាប់ថា ប្អូនសភាពការណ៍អត់ស្គាល់ទេ។ ប្អូនឯងអត់ស្ដាប់វិទ្យុទេ គេរៀបចំរណសិរ្សសាមគ្គីសង្គ្រោះហើយ ឥឡូវកងទ័ពឈ្មោះ អា០៩ ហ្នឹង បានចូលមកដល់ស្រុកយើងហើយ។ ច្រៀកជាកម្លាំងតូចៗចូលស៊ើបការណ៍តាមព្រៃរនាម។ ដើរអីប្រយ័ត្នប្រយែងមែនទែន ហើយយប់ឡើងត្រូវចល័តកន្លែងដេក។

**ស៖** ខ្ញុំយល់ថាក្នុងចំណោមភារកិច្ចរបស់លោកនៅក្រូចឆ្មារនោះ គឺលោកត្រូវជ្រើសរើស

ទាហាន ដើម្បីប្រយុទ្ធនៅព្រំដែនវៀតណាម។ តើយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយលោក។

**ស៖** តើលោកមានបានធ្វើការជ្រើសរើសទាហានទេ នៅពេលនោះ? បើតាមលោកចាំ តើនៅពេលណាក្នុងឆ្នាំ១៩៧៨នោះ ដែលលោកធ្វើការជ្រើសរើសទាហានហ្នឹង?

**ឆ៖** ខ្ញុំបាទអត់ដឹងខែថ្ងៃទេទាន ដឹងថាទៅរៀនហើយមករើស ដល់រើសៗយូរណាស់ ដល់រើសខាងលើឲ្យរៀបរកតែ១០០នាក់ទេក្នុងកងទ័ពបញ្ជូនទៅមុខ។ ដល់ខ្ញុំខ្លាចរៀប២០០នាក់ រើសនៅក្នុងស្រុកក្រូចឆ្មារហ្នឹង គ្រាន់តែមិនទាន់បានរើសទ័ពបានគ្រប់ផង កងមជ្ឈិមហ្នឹងគឺស្ដាប់ឮអ៊ីចឹង គេរាយការណ៍ទៅលើ ខាងលើហៅទៅរឿងហ្នឹង ហៅទៅរឿងហ្នឹងផង ហៅទៅរឿងគេសម្លាប់ប្អូនផងបាទ។

[១៤:១១:៤២]

**ស៖** ខ្ញុំនឹងអានឃ្លាមួយនៃចម្លើយរបស់លោក គឺឯកសារ E3/375 ហើយខ្ញុំនឹងសូមឲ្យលោកឆ្លើយបញ្ជាក់ គឺឯកសារ E3/375, ERN ជាភាសាបារាំង 00369916, ERN ជាភាសាអង់គ្លេស 00360754, ERN ជាភាសាខ្មែរ 00348793 តទៅដល់ 94។ នេះជាចម្លើយរបស់លោក៖ "យើងបានកំណត់ផែនការមួយសម្រាប់ឃុំ<>នីមួយៗឲ្យជ្រើសរើស<ទាហានជាច្រើន>តាមតម្រូវការដែលថ្នាក់លើចង់បាន។ ដូចជាមួយឃុំប្រាំនាក់ ឬ១០នាក់ជាដើម។ ក្រោយមកឃុំនីមួយៗបានបញ្ជូនយុទ្ធជនមកឲ្យខ្ញុំ ហើយខ្ញុំក៏បានធ្វើការហ្វឹកហាត់អ្នកទាំងនោះ បន្ទាប់មកបំពាក់អាវុធ។ ខ្ញុំចាំថានៅពេលនោះ ខ្ញុំបានជ្រើសរើសទ័ព២០០នាក់ ប៉ុន្តែថ្នាក់លើតម្រូវតែ១០០នាក់ទេ។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះ<តើលោកសំដៅទៅដល់ព្រឹត្តិការណ៍នេះមែនទេ?> តើត្រឹមត្រូវ<ដែរឬ>ទេ<ដែលថា>ពេលហ្នឹងគឺថាលោកបានជ្រើសរើសទ័ព២០០នាក់មកពីឃុំផ្សេងៗនៃស្រុកក្រូចឆ្មារនោះ?

**ឆ៖** បាទ ពេលនោះរើសកងទ័ពបាន១០០នាក់ជាងហើយ ហាត់ ក៏ហាត់ ហើយរៀបផែនការ២០០នាក់។ ដូចខ្ញុំរាយការណ៍ពីមុនបន្តិចហ្នឹង គឺថាកងទ័ពមជ្ឈិមគេធ្វើការមានកងសម្ងាត់ធ្វើការ ឮសួរថារៀបចំ២០០នាក់ ក្រែងលោខ្ញុំមានផែនការក្បត់ ខាងលើហៅទៅជួប ទៅសួរថា៖ "មិត្តណាឲ្យមិត្តឯងរើសកងទ័ព២០០?" ខ្ញុំបាទឆ្លើយថា៖ "ខ្ញុំរៀបសម្រាប់ស្រុក១០០ សម្រាប់បញ្ជូនទៅបក្សខាងសមរភូមិ១០០" ហើយគាត់អត់មាត់ បានគាត់បែរមកនិយាយអំពីប្រវត្តិរូបដែលធ្វើនៅពេលហ្នឹងបាទ។

[១៤:១៤:០៦]

**ស៖** នៅក្នុងឯកសារដដែលនោះ លោកបន្តទៅទៀតថា "ទ័ពទាំងនេះគឺ ដើម្បីប្រគល់ទៅឲ្យមិត្ត

រ៉ន ហៅ សាន គង់ ជាប្រធានកងពិសេស--"<។ នៅត្រង់នេះ>ជាភាសាបារាំង <បានបកប្រែថា "គណៈមជ្ឈិម"> ក៏ប៉ុន្តែជាភាសាខ្មែរគឺ "មជ្ឈិម" ទេ មិនមែនគណៈមជ្ឈិមទេ។ ហើយលោកបញ្ជាក់ថា សាន គង់ ហ្នឹងបច្ចុប្បន្នជាទីប្រឹក្សារបស់រាជរដ្ឋាភិបាលនៅអន្លង់វែង។ លោកបានបន្តទៀតថា៖ "ខណៈនោះ គាត់មានទ័ពពិសេស៤០០នាក់ដើម្បីរៀបចំការពារ។" សូមបញ្ចប់ការដកស្រង់។ តើការរើសទ័ពហើយនិងការរៀបចំការពារនេះ ដោយសារតែមានការវាយប្រយុទ្ធគ្នាជាមួយនឹងវៀតណាម ឬក៏ដោយសារតែមានហេតុការណ៍ផ្សេងពីនេះ?

**ឆ៖** បាទ តាមខ្ញុំយល់ថា មុខពីរ។ ទី១ គឺសំដៅទៅវ៉ៃទៅសមរភូមិទល់នឹងវៀតណាម ហើយនិងវ៉ៃជាមួយពួកបះបោះដែលចូលទៅ, ប៉ុន្តែទី២ វ៉ៃជាមួយនឹងកងសម្ងាត់ដែលមក ចូលមកដល់ភូមិស្រុកហើយបាទ។

**ស៖** នៅក្នុងឯកសារដដែលនៅចម្លើយដដែលនោះ លោកបានបន្តទៀតថា៖ "សុន សេន បានសួរខ្ញុំថា តើមិត្តឯងបង្កើតទ័ពដើម្បីអី? ឬអ្នកឯងចង់ក្បត់ឬ? ខ្ញុំឆ្លើយថា អត់ទេ ខ្ញុំទុកឲ្យបក្ស ១០០នាក់ ហើយទុកការពារស្រុក ១០០នាក់។ ក្រោយមក ទើបខ្ញុំបញ្ជូនទ័ព ១០០នាក់ទៅឲ្យ សាន គង់ តែម្តង។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់សួរលោកថា ប្រសិនបើខ្ញុំយល់មិនច្រឡំទេគឺថា លោកខ្លួនឯងផ្ទាល់ទេជាអ្នករើសទ័ពលើសពីតម្រូវការ<របស់ថ្នាក់លើ>នោះ <>ហើយលោករើសបន្ថែម១០០ទៀតគឺលោកទុកសម្រាប់ការពារស្រុក។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយទាន។

[១៤:១៦:៥៦]

**ស៖** តើលោកដឹងទេថានៅក្នុងស្រុកផ្សេងៗទៀតនៅក្នុងភូមិភាគបូព៌ានេះ មានលេខាស្រុកណាខ្លះដែលបានផ្តួចផ្តើមគំនិតរើសទាហានទ័ពដោយខ្លួនឯងដោយមិនមានការស្នើសុំពីថ្នាក់លើនោះ? លោកដឹងរឿងនេះទេ?

**ឆ៖** បាទ ទាន ខ្ញុំអត់បានដឹងទេ។

**ស៖** អម្បាញ់មិញនេះ លោកបាននិយាយអំពីការប្រយុទ្ធគ្នានៅតាមព្រំដែនវៀតណាម។ ហើយនៅពេលដែលលោកឆ្លើយទៅនឹងលោកមេធាវី កូប៉េ ពេលហ្នឹងគាត់បានដកស្រង់ឃ្លាមួយនៃចម្លើយរបស់ កែ ពេជ្រវណ្ណៈ ដែលជាកូនប្រុសរបស់ កែ ពក។ តើលោកចាំទេថានៅពេលណាដែលគេចាប់ផ្តើមប្រយុទ្ធគ្នានៅព្រំដែនវៀតណាមនោះ?

**ឆ៖** តាមខ្ញុំដឹងខ្លះៗនោះ មិនច្បាស់ទេ ប៉ុន្តែការប្រយុទ្ធនោះគឺរយៈពេលខ្លីតែម្តង សូម្បីតែកើតមុនដំបូង ការចាប់ខ្លួនកម្មាភិបាល, ដល់ចាប់អស់ហើយ កម្មាភិបាលខ្លះ ដូចគាត់មានស្មារតីរំដោះខ្លួនគាត់ គាត់រត់ចូលទៅវៀតណាមទៅ។ ដូច្នេះ ទៅការប្រយុទ្ធពីរពួកហើយ។ មួយពួកជាមួយវៀតណាម, មួយពួកជាមួយអ្នកចូលទៅផ្តាច់ខ្លួនទៅ បាទ។

**ស៖** តើលោកទទួលបានព័ត៌មាននេះមកពីណា?

[១៤:១៩:០១]

**ឆ៖** ព័ត៌មាននេះៗជាក់ស្តែងតែម្តង ព្រោះខ្ញុំបាទនៅហ្នឹង អាដែងកំពុងតែហាត់ទ័ពហ្នឹងក៏កាំភ្លើងវានៅជិតៗដែរ ព្រោះពេលនោះកងសម្ងាត់ហ្នឹងគេកៀរប្រជាជននៅភូមិច្រវាក់ដែក ភូមិក្របីក្រៀកទៅចូលព្រៃអាងុយអស់ ទៅវៀតណាមអស់។ ដូច្នេះ ខាងនេះក៏ហៅថា វាប្រជាជនក៏វាមិនសុខមិនស្ងប់ ហៅថាព្រឹបៗដូចត្រីចង្វាអ៊ីចឹង ដូចទៅយើងអ្នកទៅដឹកនាំខ្លាចប្រជាជនផង ណាខ្លាចនៅហ្នឹងផង ព្រោះរៀបទ័ព ទ័ពសុទ្ធតែអ្នកស្រុកក្រូចឆ្មារ រួចយកមកធ្វើទ័ព បាទ។

**ស៖** តើលោកខ្លួនឯងផ្ទាល់ហ្នឹង ឃើញទាហានផ្តាច់ខ្លួនរត់<ទៅចូលរួមជាមួយកម្លាំងនៅ>វៀតណាមនុ៎ង លោកមានបានឃើញផ្ទាល់ភ្នែកទេ?

**ឆ៖** បាទ ខ្ញុំអត់បានឃើញទេលោក។

**ស៖** ខ្ញុំនឹងរកមើលលេខឯកសារយោងរបស់លោក<នៅពេលបន្តិចទៀត> ក៏ប៉ុន្តែមានចម្លើយមួយដែលលោកបានឆ្លើយថា ក្នុងចំណោមទ័ពទាំង២០០នាក់ដែលលោកបានបង្វឹកនោះ ១០០នាក់ បានរត់គេច ហើយ<>វាយប្រយុទ្ធ<ប្រឆាំង>នឹងកងកម្លាំងនៃកម្ពុជាប្រជាធិបតេយ្យ។ តើលោកចាំពីចម្លើយរបស់លោកនេះទេ?

**ឆ៖** បាទ ខ្ញុំចង់និយាយថា ការរៀបចំទ័ពជូនទៅខាងលើហើយ ដល់ពេលទ័ពមួយចំនួនត្រូវរៀបចំនៅស្រុកក្រូចឆ្មារ រៀបចំហើយដល់ពេលខ្ញុំត្រឡប់មកវិញ បងសុន សេន ថាមិត្តឯងត្រឡប់ទៅវិញទៅប្រាប់មេៗនៅហ្នឹងសិនថា មិត្តឯងគេមិនសម្លាប់ទេ។ ដូច្នេះ កុំឲ្យបងប្អូនភិតភ័យ គ្រាន់តែខ្ញុំថា ខ្ញុំហ្នឹងគេឲ្យមកតែម្នាក់ឯងទេ ហើយនីរសារអ្នកនៅជាមួយម្នាក់ទេ។ អ្នកដទៃទៀតឲ្យនៅហ្នឹងហើយ។ ការពិតអ្នកនៅកណ្តាលប៉ុន្មាននាក់ហ្នឹង អត់មានទូកឆ្លងក៏ហែលទន្លេឆ្លងដែរ។ ឯកងទ័ពនៅហ្នឹងឯងក៏បះបោរកើតទៅជារឿងមួយទៀត។ ខ្ញុំមិនដឹងទេ ដូច្នេះសភាពការណ៍នៅហ្នឹងបានជាមានរឿងជម្លៀសកង -- ជម្លៀសប្រជាជនស្រុកក្រូចឆ្មារហ្នឹងមកចំការលើទៀតបាទ។

[១៤:២២:១១]

**ស៖** នៅពេលដែលខ្ញុំរកឃើញលេខយោង<នៃសម្រង់នេះ> ខ្ញុំនឹងផ្ដល់ជូន<តាមក្រោយ> ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំចង់ត្រឡប់មកនិយាយអំពីឃ្លាមួយនៃចម្លើយរបស់ កែ ពេជ្រវណ្ណៈ គឺឯកសារ E3/35 សហព្រះរាជអាជ្ញាបានអានឃ្លាជូនលោកស្ដាប់រួចមកហើយ ខ្ញុំមិនដឹងថាលោកនៅចាំឬក៏អត់ទេ។ គឺឃ្លាមួយនេះ គឺមានបញ្ជាក់ថា ពេលនុ៎ង កែ ពេជ្រវណ្ណៈ គាត់បាននិយាយអំពីការស្រាវជ្រាវមួយដែល ប៉ុល ពត ចេញបញ្ជាមកទៅឪពុករបស់គាត់ គឺ កែ ពក។ ក្រោយពីមានឃើញសាកសពអណ្ដែតនៅតាមទន្លេមេគង្គមក ប៉ុល ពត បញ្ជាទៅឪពុកគាត់ហ្នឹងឲ្យធ្វើការស៊ើបអង្កេតមើលថា មានរឿងអីកើតឡើង ហេតុអីបានជាមានសាកសពបែបនេះ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកដឹងអំពីរឿង ប៉ុល ពត បញ្ជាឲ្យមានការស៊ើបអង្កេតហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំបាទ អត់ទេលោក។

**ស៖** លោកចាំទេថា ពេលដែលលោកឃើញថា មានសាកសពអណ្ដែតនៅលើ -- នៅក្នុងទន្លេមេគង្គហ្នឹងលោកដឹងថា ពេលនុ៎ង កែ ពក គាត់មានមុខតំណែងជាអ្វីទេ?

**ឆ៖** គាត់មានមុខតំណែងជាប្រធានភូមិភាគកណ្ដាលផង ហើយគាត់ជាបញ្ជាការសមរភូមិជាមួយអ៊ំ សុន សេន ផងបាទ។

**ស៖** ពេលដែលគេចាត់តាំងឲ្យលោកទៅធ្វើការនៅស្រុកក្រូចឆ្មារ លោកប្រាកដទេថា លោកមិនធ្លាប់ឮគេនិយាយអំពីការស៊ើបអង្កេតបែបនេះនោះ?

**ឆ៖** បាទ លោកអត់ទេ បាទ។

[១៤:២៤:៣៨]

**ស៖** លោកបានឆ្លើយថា លោកបានឃើញសាកសពអណ្ដែតនៅក្នុងទន្លេមេគង្គ។ ដូច្នេះ ខ្ញុំយល់តាមរយៈសក្ខីកម្មរបស់លោកហ្នឹង គឺថា<លោកបានដឹងថា> សាកសពហ្នឹងជាទាហាន។ លោកដឹងថាជាទាហានខាងណាទេ?

**ឆ៖** ខ្ញុំបាទ អត់ដឹងទេ។

**ស៖** តើ<មានពេលណាមួយដែល>លោកបាននិយាយបញ្ហាហ្នឹងជាមួយ អឿន ឬជាមួយអ្នកទទួលខុសត្រូវណាមួយផ្សេងទៀតទេ?

**ឆ៖** ខ្ញុំស្ដាប់អត់ទាន់ទេលោក។

**ស៖** ខ្ញុំបានសួរលោកថា <ប្រសិនបើ>លោកបាននិយាយរឿងឃើញសាកសពអណ្តែតនៅទន្លេមេគង្គនេះ <ប្រសិនបើ>បាននិយាយរឿងហ្នឹងជាមួយ<មេណាម្នាក់ ថាតើគាត់ជា>ប្រធានតំបន់ ឬក៏ប្រធានភូមិភាគ<>?

**ឆ៖** បាទ កាលណោះឃើញអ៊ីចឹងក៏ទៅនិយាយបាននិយាយពួកខាង និយាយប្រជុំនៅក្នុងប្រជុំគណៈភាគហ្នឹងក៏បាននិយាយថា "អេ៎ ខ្មោចឃើញអណ្តែតទឹកឡើងពីរ បី បួននាក់ ឯណោះ ឡើងចង់បង្កងស៊ីទៅហើយ"។ គ្រាន់តែអ៊ីចឹង មិនមែនតែខាងលើៗ ដឹងពីខាងលើទេ គឺដឹងឃើញខ្លួនឯងហើយប្រាប់ ហើយមានខ្លះគេថា "មិត្តឯងមិនបាច់ចង់ដឹងទេ រឿងទូទាំងប្រទេសហើយចាំបាច់សួរអ៊ីចឹងធ្វើអី?"

**ស៖** នៅពេលដែលលោកនិយាយថា គេប្រាប់លោកនោះ លោកសំដៅលើអ្នកណា "គេ"ហ្នឹង?

**ឆ៖** ប្រាប់ មើល៍នៅក្នុងតំបន់ ដែល រិន កាន់កាប់ទាំងអស់គ្នាហ្នឹងគណៈតំបន់ទាំងអស់ តាំងពីតំបន់ឈ្មោះអីចូលមកទាំងអស់ ប៉ុន្តែខ្ញុំបាទមិនចាំឈ្មោះទេ ពួកខាងនិរតី។ គ្រាន់តែខ្ញុំនិយាយអ៊ីចឹងគេថាគេចង់និយាយថាខ្ញុំពន្យុះឲ្យគេហ្នឹងពីរឿងសពអីហ្នឹង ដូច្នេះគេថា "មិត្តឯងមិនបាច់ចង់ដឹងទេ រឿងផ្ទុះទូទាំងប្រទេសហ្នឹង ទឹកដល់ច្រមុះហើយចាំបាច់សួរអ៊ីចឹងធ្វើអ្វីទៀត?" ខ្ញុំក៏អត់ហ៊ានសួរទេ ឈប់ទៅ។

[១៤:២៧:៣១]

**ស៖** ដោយមានជំនួយពីសមាជិកក្រុមរបស់ខ្ញុំៗបានរកឃើញលេខយោងនៃឃ្លា ដែលខ្ញុំចង់និយាយជាមួយលោកហើយ អម្បាញ់មិញនេះពេលដែលខ្ញុំនិយាយអំពីទ័ព ១០០នាក់ ដែលបានបំបែកខ្លួននោះគឺនៅក្នុងឯកសារ E3/375, ERN ជាភាសាបារាំង គឺ 00369920, ERN ជាភាសាខ្មែរគឺ 00348798 ERN ជាភាសាអង់គ្លេស គឺ 00360758។ នេះជាចម្លើយរបស់លោក៖ "ថ្ងៃមួយក្រោយពីខ្ញុំទៅដល់ផ្ទះនៅតំបន់៤២ ស្រុកក្រូចឆ្មារមានបញ្ហាមួយកើតឡើង គឺទ័ព១០០នាក់ ដែលខ្ញុំបានបង្ហាត់ហើយទុកនៅប្រចាំការក្នុងស្រុកក្រូចឆ្មារនោះបានរត់ចូលព្រៃធ្វើការបះបោរ ប្រឆាំងនឹងពួកយើងវិញ។ ក្រោយមកមានការជម្លៀសប្រជាជនពីស្រុកក្រូចឆ្មារមកកាន់តំបន់៤២ ក្នុងភូមិភាគកណ្តាល។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំចង់សួរលោកថា តើលោកដឹង ឬមិនដឹងថាទ័ព ១០០នាក់ ដែលលោកបានបង្ហាត់ទុកប្រើការនៅក្នុងស្រុកហ្នឹងគឺបានរត់ចូលព្រៃបះបោរប្រឆាំងនឹងពួកលោកវិញ?

**ឆ៖** បាទ ដឹងច្បាស់ ព្រោះទ័ពដែលមកប្រាប់ថា ទ័ពដែលរៀបហ្នឹង តាំងពីមិត្តឯងមកហ្នឹងរត់ចូលព្រៃអស់រលីងហើយ ហើយទ័ពហ្នឹងហើយដែលមានកាំភ្លើងដែលយើងឲ្យគ្រាប់បួន ដប់គ្រាប់គាត់ហ្នឹង មកធ្វើឲ្យពួកនេះ ទ័ពនេះយើងនេះឃើញថាអ៊ីចឹងហើយ ជម្លៀសប្រជាជនតែម្តង។ ជម្លៀសប្រជា

ជនឲ្យឆ្លងមកខាងស្ទឹងត្រង់នេះ ឲ្យមក បញ្ជូនមកចំការលើ។ ពេលនោះសុន សេន បានបញ្ជាមក កែ ពក មកអឿន ហ្នឹងប្រាប់ថាឲ្យខ្ញុំនឹងត្រឡប់ទៅជួបប្រជាជននោះវិញថា មើលខ្ញុំអត់ស្គាល់ទេ ខ្ញុំនៅតែបងប្អូនកុំភិតភ័យ ការយកមកនេះ គេជម្លៀសផុតពីសមរភូមិ ប្រយុទ្ធគ្នាទេ។ ដល់អ៊ីចឹងបងប្អូនមិនជឿទេ អត់ជឿយើងនិយាយទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំចូលទៅដល់ប្រធានបទថ្មី។ អ៊ីចឹងតើលោកប្រធានចង់សម្រាកនៅពេលនេះ ឬក៏យ៉ាងណាលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវដល់ពេលសមស្របនឹងសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី ខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបីខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣១ នាទី ដល់ម៉ោង ១៤:៥២ នាទី)*

[១៤:៥៣:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក បាន សៀក ឥឡូវនេះយើងបន្តទៅទៀត។ នៅតំបន់៤២ ហ្នឹងលោកមានធ្វើជា

ប្រធានយោធាទេ?

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទអត់ទេទាន អត់បានធ្វើទេ។

**ស៖** ខ្ញុំនិយាយបែបនេះ ពីព្រោះថានៅក្នុងចម្លើយរបស់ កែ ពេជ្រវណ្ណៈ គឺឯកសារ E3/35 ERN ជាភាសាបារាំងគឺ 00367724, ERN ជាភាសាខ្មែរគឺ 00340566, ERN ជាភាសាអង់គ្លេស 00346152។ គាត់បានឆ្លើយពាក់ព័ន្ធនឹងលោក "ចំពោះ តាផុស គាត់ជាប្រធានយោធាតំបន់៤២ ក្រោយមកទៀត គេបញ្ជូនគាត់ទៅស្រុកក្រូចឆ្មារ ដើម្បីជួយរៀបចំស្រុក។ ឈ្មោះដើមរបស់គាត់គឺ ហួ។" សូមបញ្ចប់ការដកស្រង់។ លោកដឹងទេ ហេតុអ្វីបានជា កែ ពេជ្រវណ្ណៈ នេះគាត់ឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថាលោកជាប្រធានយោធាតំបន់៤២?

**ឆ៖** បាទ រឿងនេះមិនពិតទេ ព្រោះខ្ញុំបាទចេញមកពីឡូត៍នេសាទមក ទទួលប្រធានហ្កាវ៉ាស ហៅថាប្រធានសាធារណការ បានពីរបីខែ ទៅធ្វើប្រធានពាណិជ្ជកម្ម។ បានប្រហែលពីរបីខែមកធ្វើអនុស្រុក។ អនុស្រុកហ្នឹងអត់មានទទួលយោធាទេ ព្រោះមានយោធាគេហ្នឹងហើយ។ រួចយោធាតំបន់ហ្នឹងឈ្មោះ ភឿង ដែលខ្ញុំទៅឈ្មោះ ភឿង គឺយោធាតំបន់ នៅនឹងថ្នល់បែកហ្នឹង នៅខាងលិចហ្កាវ៉ាស។

**ស៖** នៅពេលណាមួយក្នុងអំឡុង ឬក៏មុនពេលរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង លោកធ្លាប់ធ្វើជាយោធាទេ? ពីព្រោះថាលោកនិយាយថានៅក្នុងមុខងាររបស់លោកនៅស្រុកក្រូចឆ្មារហ្នឹងគឺលោករើសយោធា អ៊ីចឹងមានន័យថាពីមុនមកនោះ លោកមានធ្លាប់ទទួលការបណ្តុះបណ្តាលខាងយោធាទេ?

**ឆ៖** បាទ អត់ដែលទេ ព្រោះការរើសយោធានេះ មិនមែនខ្ញុំអ្នកហាត់ទេ ហើយយើងរើសតាមមេឃុំ ទៅតាមមេឃុំបានហើយ ប្រមូលមកឲ្យកងទ័ពគេបង្ហាត់នៅនឹងទួលស្នួលនេះបាទ។

[១៤:៥៧:១៩]

**ស៖** តាមរយៈសក្ខីកម្មរបស់លោកអម្បាញ់មិញនេះ ខ្ញុំយល់ថាលោកខ្លួនឯងនេះជាអ្នកបង្វឹកទាហាន ២០០នាក់មុននឹងបញ្ជូនទៅតទៅទៀតនុ៎ង។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ អត់ត្រឹមត្រូវទេទាន ព្រោះខ្ញុំបាទមិនមែនអ្នកបង្វឹកទេ គឺអ្នកអប់រំដើម្បីកងទ័ពច្បាំងជាមួយពួកផ្តាច់ខ្លួន ច្បាំងជាមួយនឹងវៀតណាម។ និយាយឲ្យចំថា ដើម្បីការពារទឹកដី ការពារខ្លួនឯង ការពារភូមិស្រុក ព្រោះសម្តេច -- កាលនោះហៅថា ជា ស៊ីម គាត់បានទៅធ្វើខ្ញុំយួនហើយ យើងនិយាយពីកាលនោះ បាទ។ ដូច្នេះ យើងត្រូវៗប្រយ័ត្ន។ ត្រូវការដឹងមុន កុំឲ្យថានេះហើយ ខំហាត់រៀន

វាមិនបានប៉ុន្មានផង ឲ្យតែបានគ្រប់មកគេយកទៅហើយ។ ដូច្នេះ ខ្ញុំអត់បានបង្ហាត់ទេទាន គ្រាន់បានអប់រំ បានអប់រំឲ្យយល់អំពីសភាពការណ៍បាទ។

[១៤:៥៨:៣៥]

**ស៖** ដូចដែលខ្ញុំបានបញ្ជាក់ពីមុននេះ គឺឥឡូវ<នេះ>ខ្ញុំចូលទៅនិយាយអំពីចម្លើយរបស់សាក្សីមួយចំនួនជាជនជាតិចាម ដែលបានលើកឡើងអំពីហេតុការណ៍ដែលបានកើតឡើងនៅភូមិទ្រា ហើយពួកគាត់ក៏បាននិយាយអំពីវត្តមានរបស់លេខាស្រុកឈ្មោះ ហ្វូ។ ខ្ញុំយល់ថាឈ្មោះ ហ្វូ ហ្នឹងលោកមិនបានប្រើប្រាស់ទេនៅពេលដែលលោកធ្វើការនៅក្រូចឆ្មារ ក៏ប៉ុន្តែខ្ញុំចង់ឲ្យលោកមានប្រតិកម្មតបទៅនឹងចម្លើយមួយចំនួនរបស់សាក្សី។ <ចម្លើយមួយចំនួននេះត្រូវបានបង្ហាញដោយសហព្រះរាជាអាជ្ញា ប៉ុន្តែ> ខ្ញុំនឹងដកស្រង់នូវចម្លើយ<ដែលដូចនឹងអ្វីដែល>សាក្សីមួយចំនួន<នោះបាននិយាយ>។ ជាដំបូងខ្ញុំសូមលើកឡើងនូវចម្លើយរបស់លោកស្រី នោ សាទះ ដែលគាត់បានមកផ្តល់សក្ខីកម្មនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ គឺក្រោយម៉ោង១៥:០៤:៤៩ វិនាទី <បន្តិច> គាត់បានឆ្លើយថា គឺគាត់ដំបូងគាត់និយាយអំពីការចាប់ខ្លួនគាត់ ហើយដាក់<ឃុំ>នៅក្នុងផ្ទះមួយនៅភូមិទ្រា។ នៅពេលនោះ គេសួរគាត់ដូចតទៅ៖ “មេធាវីរបស់លោកស្រីបានសួរសំណួរ ទៅកាន់លោកស្រី ហើយលោកស្រីបាននិយាយថា ចៅហ្វាយស្រុកឈ្មោះ ហ្វូ ហ្នឹងមកសួរចម្លើយលោកស្រី តើលោកស្រីស្គាល់គាត់ដោយរបៀបណា? ពេលនោះគាត់ឆ្លើយថា៖ ខ្ញុំដឹងថា គាត់ជាប្រធានស្រុកថ្មី ដែលមកពីត្រើយម្ខាង។ ហ្វូ ជាលេខាស្រុក។ ខ្ញុំមិនចាំឈ្មោះអនុរបស់គាត់ទេ។ ផេង <និងមាន>សមាជិក<ម្នាក់ ឈ្មោះ ឈឹម ហើយ>មានទាហានមកជាមួយផងដែរ ប៉ុន្តែខ្ញុំមិនចាំឈ្មោះទេ។ ហើយមន្ទីររបស់គាត់មិននៅឆ្ងាយប៉ុន្មានពីទន្លេទេ។ សំណួរគេសួរគាត់ថា៖ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំចង់ដឹងថាតើលោកស្រីដឹងថា គាត់ជាលេខាស្រុកយ៉ាងម៉េចបាននៅពេលដែលគាត់មកមើលក្រុមលោកស្រីនោះ? ពេលនោះគាត់ឆ្លើយថា៖ ខ្ញុំដឹងថា គាត់ជាលេខាស្រុក ពីព្រោះពួកទាហានជាអ្នកប្រាប់ខ្ញុំ។ ដូច្នេះខ្ញុំដឹងថាគាត់ជាលេខាស្រុក គាត់ឈ្មោះ ហ្វូ។ ខ្ញុំដឹងអត្តសញ្ញាណរបស់<លេខាស្រុក, អនុរបស់គាត់, និងសមាជិកស្រុក>គឺបែបហ្នឹងហើយ។ ហើយ<>គេប្រាប់ខ្ញុំថា<ពួកគេ>ជាអ្នកកាន់ស្រុកហ្នឹង <ហើយឈ្មោះ ហ្វូ គឺជាប្រធាន>។” សូមបញ្ចប់ការដកស្រង់។

តើលោកចាំទេថា លោកធ្លាប់ទៅផ្ទះមួយដែលមិននៅឆ្ងាយប៉ុន្មានពីទន្លេ <គឺ>ផ្ទះ<មួយដែលមានសសរនៅខាងក្រោម ដែល>គេឃុំស្ត្រីមួយចំនួន ហើយពេលនុំងហើយគឺលោកខ្លួនឯងហ្នឹង ណែនាំ

ប្រាប់គេថាលោកហ្នឹងជាចៅហ្វាយស្រុកឈ្មោះ ហូ មានអ៊ីចឹងទេ?

[១៥:០១:៣៧]

**ឆ៖** បាទ ខ្ញុំបាទមិនបានដឹងទេទាន ព្រោះតាមរយៈកាល ខ្ញុំបានទៅការដ្ឋានច្រើនជាង ព្រោះមន្ទីរ អត់មានមន្ទីរស្រុកទេ។ ព្រោះកាលនោះអត់មានមន្ទីរទេ ព្រោះការរស់នៅតាមចល័តបាទ។ ដូចខ្ញុំបានជម្រាបថា ជួនកាលនៅវត្ត ជួនកាលនៅពាណិជ្ជកម្មទៅ ជួនណាមកនៅតាមភូមិទៅ ជួនណានៅជាមួយកងទ័ពទៅ ដូច្នេះមិនបាននៅមួយកន្លែងទេ។ ព្រោះនៅការដ្ឋាននោះ ជិតកងទ័ព យើងដេកនឹងកន្លែងជាមួយនឹងប្រជាជន។

**ស៖** លោកស្រី នោ សាទះ ដដែល គឺនៅមុនម៉ោង ១៥:០៩ នាទី នៅថ្ងៃសវនាការដដែល គាត់បានឆ្លើយថា គាត់បាននិយាយគ្នាជាមួយ ហូ។ គាត់ថា៖ “ហូ លេខាស្រុកបាននិយាយថាខ្ញុំយួន។ ខ្ញុំតវ៉ាខ្ញុំថាអត់ទេ ខ្ញុំមិនមែនយួនទេ ខ្ញុំជាខ្មែរ។ គាត់សួរខ្ញុំរហូត ហើយខ្ញុំពីរបីដងខ្ញុំប្រកែកថា ខ្ញុំខ្មែរទេ។ ទាល់តែអ៊ីចឹងហើយបានគាត់ទទួលយកចម្លើយខ្ញុំ ហើយគេឲ្យខ្ញុំនៅមួយចំហៀង ហើយក្រោយមកទៀតមានអ្នក មានស្ត្រីមួយចំនួនទៀតមកពីភូមិខ្ញុំដែរ ពេលគេសួរគាត់ថា ខ្មែរ ឬចាម គាត់ថាគាត់ខ្មែរដែរ។ អ៊ីចឹងនៅសល់តែគ្នាយើងប្រហែលជា៣០នាក់ទេ ដែលឆ្លើយថាខ្មែរហ្នឹង គឺគេទុកឲ្យនៅ។” សូមបញ្ចប់ការដកស្រង់។

ដូច្នេះ លោកស្រី នោ សាទះ ហ្នឹងគាត់បានបញ្ជាក់ថា គាត់បានជជែកតវ៉ាជាមួយនឹងចៅហ្វាយស្រុកឈ្មោះ ហូ ហ្នឹង។ គាត់ប្រកែកថា គាត់មិនមែនយួន ឬចាមទេ គាត់ថាគាត់ខ្មែរ ហើយគាត់ប្រាប់ថាអ្នកណាដែលឆ្លើយថា ខ្លួនឯងជាជនជាតិចាមហ្នឹង គេចាប់យកទៅសម្លាប់ចោលទាំងអស់។ ដូច្នេះ ខ្ញុំចង់ដឹងថាលោកមានបានចូលរួមក្នុងការសម្រិតសម្រាំងជ្រើសរើសមើលថា អ្នកណាខ្លះខ្មែរ អ្នកណាខ្លះចាម <ដែរឬទេ?> ហើយ<តើលោកបានបញ្ជាឲ្យសម្លាប់>អ្នកណាដែលចាមហ្នឹង<ដែរឬទេ?>

**ឆ៖** បាទ ខ្ញុំអត់បានមានការជ្រើសរើសទេទាន ព្រោះកាលទៅនៅក្រូចឆ្មារហ្នឹង មិនមែនតែខ្ញុំទេ គឺថាគ្នាច្រើន ព្រោះថា មានកងទ័ព មានស្រុក មានអីធ្វើការទាំងអស់គ្នា។ ដូច្នេះ ខ្ញុំមិនបានស្គាល់លោកស្រី សាទះ ផង ក៏មិនបានស្គាល់អ្នកនៅក្រូចឆ្មារនេះច្បាស់ទេទាន។

[១៥:០៥:០៣]

**ស៖** នៅថ្ងៃដដែលនោះគឺនៅថ្ងៃទី២៨ កញ្ញា ២០១៥ គឺក្រោយម៉ោង ១៥:២៣ នាទី លោកស្រី នោ សាទះ គាត់បានឆ្លើយថា មានបបរសាច់ជ្រូកដើម្បីយកមកធ្វើតេស្តថាតើអ្នកណាចាម ឬមិនចាម

ពីព្រោះថាចាម គឺខាងសាសនាចាម គេហាមមិនឲ្យហូបសាច់ជ្រូកទេ។ គាត់បានឆ្លើយថា៖“មានតែក្រុមខ្ញុំទេមានគ្នា៣០នាក់ដែលគេបញ្ជាឲ្យហូបស៊ុបហ្នឹង -- ហូបសម្លហ្នឹង។ ហូ គាត់មិនហូបសម្លសាច់ជ្រូកជាមួយខ្ញុំទេ មានពួកទាហានមើលពួកយើង ពេលដែលយើងហូបហ្នឹង ហើយគេមើលយើងថាយើងហូបសម្លសាច់ជ្រូក ឬក៏អត់។ លើកទី១ហើយពេលហ្នឹង ដែលខ្ញុំហូបសាច់ជ្រូកនោះ។” ហើយគេសួរគាត់បន្តទៅទៀតថា៖ “ទោះបីជា ហូ ហ្នឹងមិនបានហូបសម្លហ្នឹងក៏ដោយ តែគាត់មានវត្តមានទេ ពេលលោកស្រីហូបសម្លសាច់ជ្រូកហ្នឹង?” គាត់ឆ្លើយនៅពេលនោះថា៖ “ចាស គឺហូ ហ្នឹងនៅទីហ្នឹង គាត់គ្រប់គ្រងទូទៅ គាត់ក្តាប់រួមនៅពេលហ្នឹងៗគឺមាន ហូ លេខាស្រុក ហើយក៏មានកូនទាហាននៅជាមួយគាត់។” សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់សួរលោកថា នៅពេលដែលគេធ្វើការសម្រិតសម្រាំងដើម្បីជ្រើសរើសមើលថាតើអ្នកណាខ្លះជាជនជាតិខ្មែរ ជាជនជាតិចាមនោះ លោកពិតជាបានបញ្ជាឲ្យមានការរៀបចំដាំស្លសាច់ជ្រូកឲ្យអ្នកទាំងអស់ហ្នឹងហូប ដើម្បីដឹងថាអ្នកណាជាចាម អ្នកណាខ្មែរទេ?

**ឆ៖** បាទ អត់ទេទាន អត់បានបញ្ជាទេ។

**ស៖** សាក្សីមួយទៀត ក៏បាននិយាយអំពីឈ្មោះ ហូ នៅស្រុកក្រូចឆ្មារដែរ។ គឺ2-TCW-904 ស្ថិតនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ E3/5196, ERN ជាភាសាបារាំង 00274740, ERNជាភាសាអង់គ្លេស 00223088, ERN ជាភាសាខ្មែរ 00204457។ នេះជាចម្លើយរបស់គាត់ “មន្ទីរសន្តិសុខត្រូវបានសាងសង់នៅក្នុងភូមិនេះក្រោមការគ្រប់គ្រងរបស់មនុស្សម្នាក់ឈ្មោះ ហូ ជាខ្មែរមកពីត្រើយម្ខាងទៀត មកពីភូមិភាគកណ្តាល។ គាត់ជាអ្នកទទួលខុសត្រូវក្នុងការចាប់ជនជាតិចាមជាច្រើន។ គាត់បានចាប់ ស៊ុម, ហាន ហើយបានកោះហៅប្រជាជនមកជុំគ្នានៅក្នុង<វត្ត>ដើម្បីពន្យល់ពីភារកិច្ចដែលត្រូវធ្វើ។ ក្រោយពីប្រជុំ គេបញ្ជាឲ្យអ្នកភូមិយកខោអាវដើម្បីទៅរៀនសូត្រ ក៏ប៉ុន្តែខ្ញុំបដិសេធ ខ្ញុំមិនព្រមទៅទេ ខ្ញុំនៅផ្ទះខ្ញុំ ហើយខ្ញុំមិនដែលបានឃើញអ្នកទាំងអស់ហ្នឹងទៀតទេ។” សូមបញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំចង់សួរលោកថា តើលោកចាប់ខ្លួនជនជាតិចាមជាច្រើននាក់មែនទេ? ហើយលោកពិតជាបានកោះហៅអ្នកភូមិមកប្រជុំនៅក្នុងវត្ត<ដើម្បីពន្យល់ពីភារកិច្ចដែលត្រូវធ្វើ>មែនទេ?

**ឆ៖** បាទ អត់ទេ ខ្ញុំសូមបញ្ជាក់បន្តិច។ ដូចជា វណ្ណៈ អ៊ីចឹង គាត់ជាបងប្អូនជិតផង ថាខ្ញុំជាឃោធាតំបន់។ ដូច្នេះរឿងនេះក៏រឿងមិនច្បាស់ដូចគ្នាដែរ ខ្ញុំមិនមែនបានធ្វើអ៊ីចឹងទេទាន ព្រោះខ្ញុំពេលនោះវារយៈពេលនេះ ខ្ញុំទើបតែនៅសមរភូមិ ចែកគ្នាចល័តពេលធ្វើការអុកឡុកហើយ។

[១៥:០៩:៤៦]

**ស៖** ឥឡូវនេះ ខ្ញុំចង់ដកស្រង់នូវចម្លើយរបស់សាក្សីមួយរូបទៀត គឺសាក្សី 2-TCW-928 គឺជាស្ត្រីជនជាតិចាមមួយរូបដែលគាត់បាននិយាយនៅក្នុងកំណត់ហេតុ E3/5194, ERNជាភាសាបារាំង គឺ 00268839, ជាភាសាអង់គ្លេស 00274708, ERN ជាភាសាខ្មែរ 00204407។ គេសួរគាត់ដូចតទៅពេលនោះគឺគាត់និយាយអំពីការសម្លាប់ជនជាតិចាម។ គេសួរគាត់ថា៖ “តើមេដឹកនាំខ្មែរក្រហមដែលទទួលបន្ទុកខាងសម្លាប់ហ្នឹងជាអ្នកណា? គាត់ឆ្លើយថា៖ ឈ្មោះ ហូ ជាប្រធានស្រុកក្រូចឆ្មា រូបគាត់មកកាន់ទីនោះអស់រយៈពេលប្រមាណប្រាំពីរខែដើម្បីសម្លាប់មនុស្ស។ ខ្ញុំមិនដឹងថាតើគាត់នៅរស់ឬក៏យ៉ាងណាទេ”។ នៅក្នុងកំណត់ហេតុដដែល គាត់បានឆ្លើយនូវ ERN ជាភាសាបារាំង ដដែល គឺ 00268839 ទៅដល់ 40, ERN ជាភាសាអង់គ្លេស ដដែលគឺ 00274708 ហើយបន្តទៅដល់ 09, ជាភាសាខ្មែរគឺទំព័រដដែល 00204407។ គាត់បានពន្យល់អំពីការរត់គេចរបស់គាត់ គាត់ថា៖ “<បន្ទាប់ពីនោះ> គឺខ្ញុំនិងប្ដីខ្ញុំ បាននាំគ្នារត់ចូលព្រៃដើម្បីគេចខ្លួន ពីព្រោះ ហូ បាននិយាយថាគេនឹងសម្លាប់គ្រួសារទាំង៧០គូដែលរូបគេបានរៀបការឲ្យ។ ខ្ញុំមិនដឹងថាហេតុអ្វីបានជាគេចង់ធ្វើដូច្នេះទេ។” សូមបញ្ចប់ការដកស្រង់។ អម្បាញ់មិញនេះ ខ្ញុំបានសួរលោក ថាលោកធ្លាប់បានចូលរួមក្នុងការរៀបចំការរៀបអាពាហ៍ពិពាហ៍នៅចំការលើដែរឬទេ? ហើយឥឡូវនេះខ្ញុំសួរលោក ថាលោកធ្លាប់បានចូលរួមក្នុងការរៀបអាពាហ៍ពិពាហ៍ជនជាតិចាមនៅក្រូចឆ្មាដែរឬទេ? <នេះជា>សំណួរ<ទី១ ហើយសំណួរ>មួយទៀតគឺខ្ញុំចង់សួរលោកថាតើលោកមានបាននិយាយថាលោកនឹងសម្លាប់គ្រួសារដែលគេរៀបការឲ្យទាំងអស់ហ្នឹងដែរឬទេ?

**ផ៖** បាទ ខ្ញុំមិនបានចូលរួមក្នុងការរៀបការទេ។ ហើយខ្ញុំមិនបានធ្វើផែនការការសម្លាប់បងប្អូនជនជាតិចាមដែរបាទ។

[១៥:១៣:០៣]

**ស៖** ការដកស្រង់ចុងក្រោយនូវចម្លើយសាក្សីមួយរូបទៀតដែលខ្ញុំចង់បានប្រតិកម្មតបពីលោក គឺសាក្សី 2-TCW-893 គឺឯកសារ E3/2653, ERN ជាភាសាអង់គ្លេសគឺ 00219179, ជាភាសាខ្មែរ 00904397, ជាភាសាបារាំង គឺមានការបកប្រែតែមួយទំព័រទេ គឺឯកសារ E3/9323។ នេះជាចម្លើយរបស់សាក្សីរូបនោះ គាត់ថា៖ “ចុងឆ្នាំ៧៨ គាត់ជិះម៉ូតូឌុបលេខាស្រុកដែលអត់ចេះជិះម៉ូតូ ដើម្បីនាំគាត់ទៅប្រជុំនៅស្រុកសណ្ដាន់ ខេត្តកំពង់ធំ។” សាក្សីរូបនោះបានបញ្ជាក់ទៀតថាគាត់មិនបានចូលរួមក្នុងការប្រជុំទេ ក៏ប៉ុន្តែគាត់បានស្ដាប់ឮគេនិយាយគ្នាក្នុងពេលប្រជុំនោះ គាត់បាននិយាយដូចតទៅ៖ “ពេលមួយនោះក្នុងពេលប្រជុំ កែ ពក ដែលជាលេខាភូមិភាគកណ្ដាល គឺគាត់បានមកនិយាយពាក់ព័ន្ធទៅនឹងការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដណ្ដើមយកអំណាច<ដោយហិង្សានៅភូមិភាគបូព៌ា> ហើយគាត់បាន<សួរ>លេខាស្រុកក្រូចឆ្មារ ថា <តើ>គេបានៗសម្រេចផែនការបក្សបានប៉ុន្មានភាគរយ។" ហើយសាក្សីរូបនោះក៏បានឆ្លើយទៀតថា៖ "បន្ទាប់មក កែ ពក បានឡើងនិយាយថា ជាដំបូងត្រូវកម្ទេចចាម កម្ទេចកម្លាំងចល័តសិន ព្រោះពួកហ្នឹងសុទ្ធតែជាពួកក្បត់។" សូមបញ្ចប់ការដកស្រង់។ សំណួរទី១ តើលោកបានចូលរួមនៅក្នុងកិច្ចប្រជុំមួយនៅស្រុកសណ្ដាន់ ខេត្តកំពង់ធំ ដែលនៅក្នុងពេលនោះ កែ ពក បានប្រាប់ឲ្យលោកកម្ទេចចាមទាំងអស់ ពីព្រោះថាចាមសុទ្ធតែជាជនក្បត់។ តើមានហេតុការណ៍អ៊ីចឹងកើតឡើងទេ?

**ឆ៖** បាទ លោកអត់ទេ ខ្ញុំមិនបានទៅប្រជុំអីនៅសណ្ដាន់អីណាទេ ខ្ញុំមិនបានទេ។ ខ្ញុំចេះជិះម៉ូតូទាំងពីដើមមកលោក ខ្ញុំមិនមែនរកគេពឹងទេបាទ ដូចថានីរសារនៅតែពីក្រោយខ្ញុំទេ ខ្ញុំមិនដែលបានប្រជុំនៅស្រុកសណ្ដាន់ ហើយដើរប្រជុំជាមួយ បងពក នៅការដ្ឋាន នៅកន្លែងណា ក៏ខ្ញុំមិនដែលបានប្រជុំដែរ។

[១៥:១៦:១៣]

**ស៖** តើមានអ្នកណាម្នាក់ទៀតឈ្មោះ ហ្វូ ដែរឬទេក្នុងស្រុកក្រូចឆ្មារ? ហើយលោកអាចពន្យល់បានទេថា ហេតុអ្វីបានជាសាក្សីជនជាតិចាមជាច្រើនរូបនេះបាននិយាយថាឈ្មោះ ហ្វូ នេះជាលេខាស្រុកក្រូចឆ្មារ ជាអ្នកធ្វើការសម្លាប់ជនជាតិចាមក្នុងទ្រង់ទ្រាយធំនោះ?

**ឆ៖** បាទ ខ្ញុំបាទមិនដឹងទេទាន ព្រោះខ្ញុំបាទរៀនសូត្រមិនដែលខាងលើឲ្យធ្វើការបោសសម្អាតចាមទេ ព្រោះកាលទៅហ្នឹង សភាពការណ៍វាតឹងតែងហើយ។ ដូច្នេះការបោសសម្អាតគ្មានការ ផែនការអីធ្វើអ៊ីចឹងទេទាន។ ហើយ បងពក ក៏មិនដែលធ្វើផែនការថា អ្ហ៊ែ យើងត្រូវបោសសម្អាតចាម។ ឧទាហរណ៍ថា បើថាបោសសម្អាតចាម ខ្ញុំស្គាល់ចាមនៅម៉ុត្រពាំងឈូក មិនស្រួលអស់ហើយ បងប្អូនចាមនៅហ្នឹង ក៏ប៉ុន្តែគេមិនធ្វើផែនការបោសសម្អាតផង ព្រោះអ្នកបះបោរទេ ដែលខ្ញុំដឹង ខ្ញុំទៅគឺមានតែអ្នកបះបោរទេ មិនមែនទៅចាប់តាមៗផ្ទះទេ ខ្ញុំស្មានដឹងដែរ បើថាបះបោរមាន កងទ័ពរៀបចំដើរទៅហៅបងប្អូនតាមផ្ទះ ឬទៅប្រជុំឲ្យស៊ីសាច់ជ្រូក ស៊ីអី ឬប្រជុំធ្វើ មិនដែលប្រជុំអ៊ីចឹងទេ អត់ដែលទេ។ ទៅការដ្ឋាន គេដឹង គេកាប់គោ កាប់អី នៅការដ្ឋាន អត់មានអីទេ។

[១៥:១៨:០៦]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ ក៏ប៉ុន្តែលោកមេធាវី គង់ សំអុន គាត់មានសំណួរបន្ថែមខ្លះទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ និងសូមជម្រាបសួរលោកសាក្សី។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមចង់សួរបញ្ជាក់សំណួរចម្លើយចុងក្រោយរបស់លោកអំមិញ លោកថា លោកស្គាល់ចាមនៅត្រពាំងឈូកហ្នឹង ត្រពាំងឈូកនៅកន្លែងណាដែរ?

**លោក បាន សៀក៖**

**ឆ៖** ត្រពាំងឈូក នៅឃុំបឹង ស្រុកបារាយណ៍ ខេត្តកំពង់ធំ បើជិះឡានតាមផ្លូវទៅ ត្រពាំងឈូកនៅតាមផ្លូវហើយ បងប្អូនអ៊ីស្លាមនៅហ្នឹងពេញនោះឯង។ បើ កែ ពក គ្រប់គ្រងភូមិភាគដាក់ផែនការកម្ទេចនោះ អស់បងប្អូនអ៊ីស្លាមនៅហ្នឹងហើយ។

**ស៖** នៅត្រពាំងឈូកហ្នឹង លោកមានទំនាក់ទំនងអ្វី ឬក៏សមត្ថកិច្ចអ្វីក្នុងការគ្រប់គ្រងនៅត្រពាំងឈូក ដែរឬទេ?

**ឆ៖** បាទ អត់ទេ។ ប៉ុន្តែខ្ញុំដឹងថា បងប្អូនចាមនៅត្រពាំងឈូក គឺគាត់នៅធម្មតា នៅហ្នឹងឯង បាទ ដូចគ្មានផែនការបោសសម្អាតទេ ព្រោះតាមឮពីដើម តែខ្ញុំមិនច្បាស់ទេ ប៉ុន្តែថា ព្រោះការពូជសាសន៍មានតែមួយទេវៀតណាមទេបាទ អាហ្នឹងច្បាស់ហ្មង។ បើថាជាមួយបងអ៊ីស្លាម មានតែមិនឲ្យសូត្រធម៌ មិនឲ្យថ្វាយបង្គំ ដូចជាខ្មែរ មិនឲ្យបួសអីចឹងឯង។ ប៉ុណ្ណឹងឯង ខ្ញុំដឹងតែប៉ុណ្ណឹងទេលោក។

**ស៖** បាទ សូមអរគុណ។ ខ្ញុំមានសំណួរមួយទាក់ទងទៅនឹងសក្ខីកម្មរបស់លោក កាលពីម្សិលមិញនៅម៉ោង ១០:៤៦:១១ ក្រោមហ្នឹងបន្តិច លោកមានប្រសាសន៍អំពីការទៅធ្វើជាលេខាស្រុក ហើយនៅពេលនោះលោកបានបញ្ជាក់អំពីការគ្រប់គ្រងឃុំពីរ គឺឃុំល្វា និងឃុំចំការអណ្ដូង ហើយឃុំដទៃទៀតលោកថាឃុំគេធ្វើការដោយឯករាជ្យ ដោយខ្លួនគេ។ គឺខ្ញុំចង់សួរលោកថា តើឃុំដែលធ្វើការឯករាជ្យលោកមានប្រសាសន៍ហ្នឹង មានន័យដូចម្ដេច?

**ឆ៖** បាទ ពេលនោះខ្ញុំមិនមែនស្រុកក្រូចឆ្មារទេ ស្រុកចំការលើ ដែលបងឲ្យទៅធ្វើឃុំពីរ ព្រោះខ្ញុំដែលធ្វើថ្មីនោះ ព្រោះឃុំគេនេះមានសមាជិកមួយទៀតទទួលឃុំបីបួនឯណោះ។ ដល់អីចឹងឃុំដទៃទៀតដែលជិតៗហ្នឹង គឺគេឯករាជ្យបាន ធ្វើការទៅបានហើយ។ ដូច្នេះ ខ្ញុំទៅធ្វើឃុំពីរដើម្បីចុះការដ្ឋាន

៥កុម្ភ: ហើយចុះការដ្ឋាននៅទំនប់នៅស្វាយទាបអីហ្នឹង។ ចូលទៅខំប្រឹងធ្វើការ។

[១៥:២១:១០]

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំ ចង់ឲ្យលោកបញ្ជាក់ពីពាក្យថា ការងារឯករាជ្យហ្នឹង គឺគេធ្វើអ្វីខ្លះ សម្រាប់ឃុំដែលមានការងារឯករាជ្យនោះ?

**ឆ៖** បាទ ពេលនោះស្រុក បើនិយាយពីស្រុកចំការលើ អស់មានអីការបោសសម្អាតអីទៀតហើយ ព្រោះពួកដែលក្បត់ដែលថា សេ.អ៊ី.អា ហ្នឹងអស់ទាំងពីក្រោមដល់លើ។ ដូច្នេះពួកថ្មីមកពីនិរតីមក គេមកគ្រប់គ្រងរៀបចំឃុំរឿងគេទៅ។ ឯយើងចំការលើ យើងរៀបចំឃុំខ្លួនឯង។ ដូច្នេះបញ្ហាអីដែលរៀបចំហ្នឹង គឺយើងរៀបចំតាមស្គាល់ តាមការទំនាក់ទំនងដើម្បីការរៀបចំហ្នឹងហើយ ហើយខាងលើចុះទៅចាត់តាំងរៀបចំទៅបាទ។

**ស៖** លោកមានប្រសាសន៍អំពីការរៀបចំឃុំហ្នឹង លោកចង់និយាយអំពីការចាត់តាំងកម្មាភិបាល ឬក៏បុគ្គលិកនៅក្នុងឃុំ ឬមួយក៏ការរៀបចំអ្វីផ្សេង លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទលោក រៀបចំមេឃុំ ហើយរៀបចំមេឃុំហើយ បានមេឃុំរៀបចំអនុទៅ ហើយរៀបចំ ថារៀបចំសហករណ៍ សហករណ៍ទៅជាប្រធានសហករណ៍មួយៗតែម្តង។ បាទ ពេលនោះរៀបចំសហករណ៍លោក។

**ស៖** បាទសូមអរគុណ។ ចុះទាក់ទងនឹងការងារផ្សេងទៀត ឧទាហរណ៍ខាងការងារបង្កបង្កើនផល ឬខាងម្ហូបអាហារជាដើម។ តើឃុំដែលឯករាជ្យហ្នឹង គឺធ្វើការដូចម្តេចដែរ?

**ឆ៖** បាទ ពេលនោះ គឺថាកាលពីមុននឹងដែលថាពួក សេ.អ៊ី.អា ហ្នឹងមានការបងប្អូនហូបជួនណាហូបពោតតែមួយទៅ ដល់ពេលក្រោយមកក៏នៅតែហូបបាយលាយដែរ អត់បានហូបបាយសុទ្ធទេ មានបបរអីចឹង។ បើអ្នកណាទៅការដ្ឋានហូបបបរទៅ ហូបបាយទៅ។ ដូច្នេះខំបង្កបង្កើនផល ដើម្បីដាំពោត សំខាន់ដាំពោតច្រើនជាងគេ ដើម្បីបានពោតហ្នឹងលីងជាមួយអង្ករ។ ខ្ញុំមិនដឹងថាស្រូវអង្ករហ្នឹងមិនដឹងយកទៅណាទេ ព្រោះខ្ញុំទៅហ្នឹងមិនដឹងជាយកទៅណា ស្រាប់តែអត់ ប្រជាជនអត់បាយតែម្តង។ អីចឹងបានប្រជាជនគេធ្វើពាក្យស្លោកមួយថា -- កាលហ្នឹងខ្ញុំប្រាប់ថា កុំថា ប្រយ័ត្នវើយ គេថាកុំទៅទើសកង់ប្រវត្តិសាស្ត្រ គេថា "ធ្វើស្រែនឹងទឹក ហូបបាយ ធ្វើស្រែនឹងប្រឡាយ ហូបបបរ"។ ដូច្នេះ ខ្ញុំថា "អ្អែ កុំថាវើយប្រយ័ត្នវើយ"។ ប៉ុណ្ណឹងឯងលោក។

[១៥:២៤:០៩]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការបះបោរដែលលោកមានប្រសាសន៍ថាមានការបាញ់ប្រហារអនុស្រុករបស់លោកម្នាក់រងរបួស។ លោកចាំពីកាលបរិច្ឆេទទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ចាំទេ ព្រោះទៅរយៈពេលតែ រយៈពេលខ្លីហ្នឹង ប៉ុន្តែបានប្រហែលជាមួយខែកន្លះហ្នឹង ស្រាប់តែខ្ញុំនៅការដ្ឋាន ស្រាប់គេថា អ៊ូ! ឱ របួសខ្លាំងណាស់ បាញ់ពីស្មាទៅ ព្រោះអត់ចំបេះដូងទេ មកត្រូវចេញមកណេះ។ ដូច្នេះ ឱ ហ្នឹងរស់ទាល់តែទើបស្លាប់មុនឆ្នាំ ប្រហែលស្លាប់ឆ្នាំ៩០។ ឆ្នាំ៩០ហ្នឹង គាត់ស្លាប់។

**ស៖** លោកអាចកំណត់នូវកាលបរិច្ឆេទថា ក្នុងអំឡុងពេលបន្ទាប់ពីមានការបាញ់ប្រហារហ្នឹងរហូតមកដល់ពេលដួលរលំរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងមានរយៈពេលប៉ុន្មានដែរទេ?

**ឆ៖** តាមខ្ញុំដឹងប្រហែលជាបីខែ ព្រោះខ្ញុំខាងលើឱ្យមកនៅស្រុកចំការលើវិញហ្នឹង ប្រហែលជាជិតមួយខែ មិនទាន់បានត្រជាក់ខ្លួនស្រួលបួលផង ស្រាប់តែផ្អើលៗប្រជាជនមកហ្នឹង វគាត់វតាយហ្នឹងបានឮសួរ អឿនហ្នឹងហៅថា ន៎បង ន៎ សុន សេន ឱ្យបងឯងទៅជួយប្រាប់ បង្ហាញមុខប្រជាជន។ ប្រជាជនថាយកមកសម្លាប់បះបោរហើយ ព្រោះសភាពការណ៍ខាងត្រើយខាងនោះ សភាពការណ៍អត់ល្អទេ ព្រោះឥឡូវហ្នឹងកងឈ្លបនោះទប់ទល់គ្នាខ្លះហើយ។ អ៊ីចឹង បានឱ្យខ្ញុំទៅបង្ហាញថាអត់ស្លាប់ទេ ខ្ញុំនៅទេ ខ្ញុំនៅរស់ទេ បងមើលខ្ញុំនៅរស់អីតើ ខ្ញុំមានស្លាប់ឯណា? បងប្អូនគ្រវីក្បាល គាត់មិនជឿ ចេះតែមក គាត់លំបាកគាត់ គាត់មិនចង់ឆ្លងមកខាងយើងទេណ៎ា គាត់មិនទុកចិត្តយើងទេ បងប្អូននោះ។

[១៥:២៦:១៨]

**ស៖** បាទសូមអរគុណ។ លោកមានប្រសាសន៍អំពីការបះបោររបស់ឈ្លប ហើយអម្បាញ់មិញក៏លោកមានប្រសាសន៍បន្ថែមទៀតដែរ។ ខ្ញុំចង់ដឹងថា តើការបះបោរហ្នឹងរបស់ឈ្លបហ្នឹងនៅទូទាំងស្រុកដែលលោកគ្រប់គ្រងនោះ ឬមួយក៏កើតឡើងតែក្នុងតំបន់តូចៗណាមួយទេ?

**ឆ៖** បាទអ្នកដែលផ្តាច់ខ្លួន ដែលយើងរៀបចំទ័ពបំពាក់អាវុធហើយហ្នឹង មិនដឹងជាគាត់ទៅចូលព្រៃនៅកន្លែងណា ប៉ុន្តែគ្រាន់ថា គេមកប្រាប់ថាទ័ពហ្នឹងចូលព្រៃអស់ហើយ។ ហើយទាំងទ័ពបញ្ជូនទៅដល់ហ្នឹងក៏ចូលព្រៃដែរ។ ដូច្នេះ កម្លាំងហ្នឹងវាត្រូវស្មើគ្នាហើយ។ ដូច្នេះ ស្រាប់តែបានតែពីរបីបួនថ្ងៃផ្លាស់មកខ្លួនទទេ មកចំការលើដែរ មកអត់មានទ័ពដែរ មកទទេមកដែរ។ រួចដល់សួរថា អ្នក! ម៉េចមកធ្វើអី? អ្ហែ ខ្ញុំសម្រាក។ ដល់ទៅបាត់ រ៉ន ហ្នឹងមិនដឹងទៅណាទៀតបាទ ពេលនោះមកធ្វើការ។ រួចទៅគេជម្លៀសមកៗ បានប៉ុន្មានថ្ងៃមិនទាន់បានអីផង សុន សេន មក ដើរមកនៅជិតបុសខ្នុរហ្នឹង ក៏គេទៅ

វិញអស់ទៅ បាទ អត់បានអីផង។

**ស៖** បាទ លោកមានប្រសាសន៍ផងដែរអំពីការចល័តទីតាំងធ្វើការរបស់លោកផ្ទាល់ ក្នុងពេលចុងក្រោយ។ ខ្ញុំចង់សួរថាតើ ខាងណាជាអ្នកគ្រប់គ្រងប្រជាជននៅពេលនោះ? ខាងក្រុមរបស់លោកគឺក្រុមកម្ពុជាប្រជាធិបតេយ្យ? ឬខាងក្រុមអ្នកតស៊ូ ឬក្រុមអ្នកបះបោរ ឬក្រុមណាមួយដែលលោកអាចបញ្ជាក់ថាជាអ្នកគ្រប់គ្រងប្រជាជននៅពេលនោះបាទ?

**ឆ៖** បាទ ខាងនោះប្រជាជនដូចជាត្រីចង្វាអ៊ីចឹង ភ្លឹបភ្លែតៗ ដាក់អត់នៅទេ។ អារម្មណ៍គាត់វាមិនស្អាតមក។ ដូច្នេះ យើងកំណត់ថាប្រជាជនហ្នឹងមិនពេញចិត្តជាមួយអ្នកដឹកនាំរបស់យើងទាំងអស់នេះទេ មិនទទួលយកបានទេ។ ដូច្នេះ យើងរើសទ័ពទៅ គេទៅកាន់អាវុធ គេស្រុះគ្នាទៅកាន់អាវុធ។ ដល់ហាត់បានឲ្យទៅនោះ ១០០ទៅ នៅ១០០ ខ្ញុំនេះ មកឯនេះទៀត អ្នកនុំងលែងឡើងគោកបានហើយ ជម្លៀសពីកងទ័ពមក ទៅជាកៀរប្រជាជន ចុះមក រួចប៉ុន្មានគេយក ដីយកអស់ហើយពេលនុំង គេយកអស់ហើយ ចុងរនាមគេនៅ ឯយើងមានគ្រាប់ផ្លោងឯណាៗ បើរថក្រោះរថអី ចាញ់គេអស់ហើយ។

**ស៖** បាទ អ៊ីចឹងតាមដែលលោកមានប្រសាសន៍អម្បាញ់មិញនេះ គឺក្នុងអំឡុងពេលបីខែចុងក្រោយ ការគ្រប់គ្រងនៅតំបន់លោក ប្រជាជន ក៏ដូចជាទីតាំងភូមិសាស្ត្រ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកតស៊ូបះបោរប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ តើអ៊ីចឹងត្រឹមត្រូវទេ?

[១៥:២៩:៣៩]

**ឆ៖** បាទ មិនត្រឹមត្រូវទេ ព្រោះពេលនោះ កម្លាំងយើងនៅមានកម្លាំងខ្លាំងជាង ព្រោះកម្លាំងយើងនៅខាងមុខក៏មាន នៅកណ្ដាលក៏មាន។ ដូច្នេះ ហើយពួកបះបោរហ្នឹងវាជាប់នៅព្រៃអាងុយៗហ្នឹង វាជាប់នឹងក្រូចឆ្មារ វាជាប់គ្នានឹងភូមិហ្នឹង រួចវាភ្ជាប់គ្នាអស់ហើយ ហើយចុះព្រៃអាងុយមក ព្រៃរនាមទាំងអស់។ ដូច្នេះ គេមិនទាន់វ៉ៃទ្រង់ទ្រាយធំទេ ប៉ុន្តែគេធ្វើជាកងឈ្លប ឯអ្នកឡើងច្រាំង បាញ់។ ដូច្នេះ ដូចជាសង្គ្រាមវាផ្ទុះគ្នាទៅហើយ។ អ៊ីចឹងបានជាកងទ័ពគេកម្លាំងធំ គេកៀរប្រជាជនមក ដាក់កម្លាំងកៀរតែម្ដង កៀរមក គេយកមកឲ្យស្រុកក្រូចឆ្មារនេះ -- អ៎! ស្រុកចំការលើនេះបាទ។ ប៉ុណ្ណឹងលោក។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាទ សវនាការស្ដាប់សក្ខីកម្មសាក្សី បាន សៀក បានដល់ទីបញ្ចប់ហើយ អង្គជំនុំជម្រះអរគុណលោក បាន សៀក ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោក នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៅរឿងក្ដីនេះ។ វត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកជួបតែសំណាងល្អ មានសេចក្ដីសុខ សេចក្ដីចម្រើន ហើយអង្គជំនុំជម្រះ ក៏សូមអរគុណដែរលោក ឌុច ផារី មេធាវីប្រឹក្សាសាក្សី ឥឡូវនេះការស្ដាប់សក្ខីកម្មសាក្សី បាន សៀក បានចប់ហើយលោកអាចសម្រាកបានហើយ។

[១៥:៣១:០៩]

ហើយបង្គាប់មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនលោក បាន សៀក វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយនិងជាបន្តអង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-904 និងបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 2-TCW-904 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

អញ្ជើញលោក ផារី!

**លោក ឌុច ផារី៖**

សូមគោរពឯកឧត្ដមប្រធាន ដោយសារខ្ញុំត្រូវធ្វើជាមេធាវីប្រឹក្សារបស់សាក្សីបន្ទាប់ តើខ្ញុំគួរនៅទីនេះ ឬក៏ខ្ញុំសម្រាកត្រឹមប៉ុណ្ណឹងសិនបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បើៗអ៊ីចឹង អង្គុយនៅទីនេះចុះ!

*(មន្ត្រីតុលាការនាំសាក្សីចូលបន្ទប់សវនាការ)*

[១៥:៣៤:០៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ទុកម្ដុំសិន លោកសាក្សី។ សាក្សីតើលោកឈ្មោះអី?

**លោក សុះ រំលី៖**

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំឈ្មោះ សុះ រំលី។

**ស៖** អរគុណលោក សុះ រំលី តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ?

**ឆ៖** ខ្ញុំកើតនៅឆ្នាំ១៩៥៥។

**ស៖** អរគុណ ទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទ នៅភូមិទ្រា២ ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។

[១៥:៣៥:០៤]

**ស៖** អរគុណ។ ចុះទីលំនៅសព្វថ្ងៃ តើលោកនៅទីកន្លែងណា ហើយលោកប្រកបមុខរបរអ្វីដែរ?

**ឆ៖** សព្វថ្ងៃ ខ្ញុំនៅភូមិទ្រា២ ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ ហើយមានមុខរបរធ្វើស្រែចំការ។

**ស៖** អរគុណ។ ចុះឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ ម៉ាត់ យូសុះ។ ម្តាយរបស់ខ្ញុំឈ្មោះ ទូនី អែសះ។

**ស៖** អរគុណ។ ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធរបស់ខ្ញុំឈ្មោះ អែល អែសះ។ ខ្ញុំមានកូនប្រាំមួយនាក់។

**ស៖** លោក សុះ រំលី តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញ ថាតាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោកខៀវ សំផន និងបុគ្គលទាំងឡាយដែលបានទទួលយកជាភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះទេ។ តើពិតមែនដែរទេ?

**ឆ៖** បាទ ពិតមែន។

**ស៖** ហើយលោកកាន់ជំនឿខាងសាសនាអីដែរ លោក សុះ រំលី?

**ឆ៖** ខ្ញុំកាន់សាសនាអ៊ីស្លាម។

**ស៖** បាទ អរគុណ។ ឥឡូវនេះ អង្គជំនុំជម្រះបង្គាប់ឲ្យក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ាយ ធ្វើការសម្របសម្រួល ណែនាំឲ្យសាក្សីធ្វើសម្បថតាមជំនឿរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ។

**ក្រឡាបញ្ជី៖**

បាទ ជម្រាបសួរលោកសាក្សី។ ជាបន្តទៅនេះ ខ្ញុំនឹងរៀបចំពិធីសម្បថដល់លោក សូមលោក

សាក្សីដាក់បាតដៃនៅលើគម្ពីរអាល់គូរ៉អានដែលនៅពីមុខលោក ខ្ញុំនឹងអានទូវពាក្យសម្បថ ហើយសូមលោកនិយាយតាមពាក្យសម្បថនេះតាមខ្ញុំលោកសាក្សី។ ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់ក្នុងនាមខ្ញុំជាអ្នកកាន់សាសនាអ៊ីស្លាម ដែលមានអល់ឡោះជាម្ចាស់តែមួយ និងម៉ូហាម៉ាត់ជាបម្រើរបស់អល់ឡោះ និងមានគម្ពីរអាល់គូរ៉អាន ជាសម្ពីរបស់អល់ឡោះ ដែលជាគោលសម្រាប់យើងខ្ញុំអនុវត្តតាម។ ខ្ញុំសូមស្បថដោយមានគម្ពីរអាល់គូរ៉អាននៅពីមុខខ្ញុំស្រាប់ “វល់-ឡ-ហ៊ី ពិល-ឡា-ហ៊ី” បញ្ជាក់ថាអ្វីៗដែលខ្ញុំនិយាយ សុទ្ធតែជាការពិតទាំងអស់។ សូមសាក្សីអានតាម!

[១៥:៣៨:៣៣]

**លោក សុះ វំលី៖**

ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។ ក្នុងនាមខ្ញុំជាអ្នកកាន់សាសនាអ៊ីស្លាម ដែលមានអល់ឡោះជាម្ចាស់តែមួយ និងម៉ូហាម៉ាត់ ជាបម្រើរបស់អល់ឡោះ និងមានគម្ពីរអាល់គូរ៉អានជាគម្ពីររបស់អល់ឡោះ ដែលជាគោលសម្រាប់យើងខ្ញុំអនុវត្តតាម។ ខ្ញុំសូមស្បថដោយមានគម្ពីរអាល់គូរ៉អាននៅពីមុខខ្ញុំស្រាប់ “វល់-ឡ-ហ៊ី ពិល-ឡា-ហ៊ី” បញ្ជាក់ថាអ្វីៗដែលខ្ញុំនិយាយសុទ្ធតែជាការពិតទាំងអស់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមប្រាប់ពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិលោក សុះ វំលី ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងនោះនាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ អំពីករណីយកិច្ច លោក សុះ វំលី ក្នុងឋានៈលោកជាសាក្សី ត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការចំពោះមុខអង្គជំនុំជម្រះនេះត្រូវតែឆ្លើយតបទៅរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯងដូចយើងប្រាប់អំពីសិទ្ធិរបស់សាក្សីរួចហើយអម្បាញ់មិញនេះ។

ហើយក្នុងឋានៈជាសាក្សី ត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮបានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក សុះ រំលី តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងរយៈពេលកន្លងប៉ុន្មានឆ្នាំកន្លងមកនេះ? ហើយប្រសិនបើមាន ធ្វើប៉ុន្មានដង? ធ្វើនៅកន្លែងណា? នៅពេលណា?

**លោក សុះ រំលី៖**

**ឆ៖** បាទខ្ញុំសូមជម្រាបថា ខ្ញុំធ្លាប់ផ្តល់សក្ខីកម្មដល់ការស៊ើបអង្កេតហ្នឹងចំនួនបីដង។ ពីរដងនៅផ្ទះរបស់ខ្ញុំ ម្តងនៅកំពង់ចាម ក្រុងកំពង់ចាម។

**ស៖** បាទ អរគុណ ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យមើល ឬក៏បានអានន្ទូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មចំពោះមុខអ្នកស៊ើបអង្កេត កាលពីមុនចំនួនបីដងនៅផ្ទះរបស់លោក និងនៅក្រុងកំពង់ចាម ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានអាន។

**ស៖** បាទ អរគុណ ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំថា តើលោកអាចបញ្ជាក់បានដែរឬទេថា កំណត់ហេតុស្តាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំ គឺពិតជាត្រឹមត្រូវ សមស្រប ស៊ីចង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេល -- បីដង កាលពីពេលមុននោះដែរឬទេ?

**ឆ៖** ភាគច្រើនស៊ីចង្វាក់ តែមានចំនួនខ្លះមិនទាន់ស៊ីចង្វាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី សុះ រំលី មុនភាគីដទៃទៀតនៃរឿងក្តី។

សូមអញ្ជើញលោក មេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនទាន់យល់ យល់មិនទាន់ច្បាស់ថា ហេតុអ្វីបានជាសាក្សីរូបនេះ<ត្រូវការ>មេធាវីប្រឹក្សា <ការពិតវាស្រេចតែគាត់ទេ ប៉ុន្តែ>អ្វីដែលខ្ញុំរកឃើញ<ថាមានបញ្ហា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នោះ>គឺថា គាត់ត្រូវបានផ្តល់ជំនួយការដោយមេប្រឹក្សាមេធាវី<ដដែល> ដូចសាក្សីមុនដែរ <ហើយលោកប្រធានប្រហែលអាចចាំបានថាមួយម៉ោងមុននេះ> មេធាវីការពារក្តីក្រុមខៀវ សំផន បានប្រឈមមុខជាមួយនឹងសាក្សីមុនដែរ <គឺកំណត់ហេតុសម្តាប់ចម្លើយរបស់សាក្សីរូបនេះនៅចំពោះមុខលោកប្រធាន។> ដូច្នេះហាក់បីដូចជាមានទំនាស់ផលប្រយោជន៍ជាមួយនឹងមេធាវីប្រឹក្សា នួន ជា ខ្ញុំមិនច្បាស់ថា តើសាក្សីរូបនេះត្រូវទទួលបាននូវជំនួយការពីមេធាវីប្រឹក្សាតែមួយឬក៏យ៉ាងណា?

[១៥:៤៣:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៧:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមតិយោបល់របស់លោកមេធាវី វ៉ិចទ័រ កូប៉េ ចំពោះបញ្ហានេះ អង្គជំនុំជម្រះក៏មិនទាន់ប្រាកដដែរ ហើយខ្ញុំផ្ទាល់ជាប្រធានសវនាការក៏មិនដឹងដែរ។ ទើបតែទទួលព័ត៌មានអម្បាញ់មិញជាក់ស្តែង គឺនៅមុខទាំងអស់គ្នាហើយ គឺមិនបានទទួលព័ត៌មាននេះមុនទេ ហើយម្យ៉ាងទៀតហ្នឹងរវាងមេធាវីប្រឹក្សាសាក្សី ហើយនិងមិនមែនជាមេធាវីតំណាង ឬក៏មេធាវីការពារសាក្សីនេះ វាស្ថិតនៅក្នុងស្ថានភាពមួយដែលត្រូវពិនិត្យពិច័យផងដែរ ដោយប្រៀបធៀបទៅនឹងការលើកឡើងរបស់មេធាវី កូប៉េ។ ហេតុដូច្នេះ ដោយសារបញ្ហានេះផង ហើយពេលវេលាក៏ជិតដល់ពេលឈប់សម្រាកហើយដែរ ដូច្នេះ អង្គជំនុំជម្រះសម្រេចថាសវនាការនៅថ្ងៃនេះ គឺសម្រាកត្រឹមនេះ ហើយសវនាការលើកទៅបន្តទៅធ្វើនៅថ្ងៃស្អែក ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនៅថ្ងៃស្អែកនេះ ថ្ងៃទី០៧ ខែតុលា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះ ហើយនិងមានសាក្សីបម្រុងមួយរូបទៀតគឺ 2-TCW-996 ពាក់ព័ន្ធនឹងអង្គហេតុការដ្ឋានទំនប់ត្រពាំងថ្ម នេះគឺជាសាក្សីបម្រុង។ ហើយសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។ ហើយដោយឡែកបញ្ហានេះ អង្គជំនុំជម្រះនឹងជម្រាបជូនភាគីពាក់ព័ន្ធ ដោយដោះស្រាយឲ្យបានមុនពេលអង្គជំនុំជម្រះដំណើរការស្តាប់សក្ខីកម្មសាក្សីរូបនេះនៅព្រឹកថ្ងៃស្អែក។

ហើយអង្គជំនុំជម្រះអរគុណលោក សុះ រំលី ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ហើយក៏សូមអរគុណដែរលោក ឌុច ផារី ដោយ

បញ្ហានេះជាបញ្ហាថ្មីសម្រាប់យើងខ្ញុំដែលនឹងទើបតែជួបប្រទះដែរ ដូច្នេះយើងនឹងពិនិត្យលើបញ្ហានេះដើម្បីដោះស្រាយយ៉ាងម៉េច យើងនឹងជម្រាបជូនក្នុងពេលឆាប់ៗបំផុត ឲ្យបានមុនពេលដំណើរការសវនាការនៅព្រឹកថ្ងៃស្អែក។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនលោក សុះ រំលី ត្រឡប់ទៅកាន់ដែលគាត់ស្នាក់នៅវិញ និងឲ្យអញ្ជើញគាត់មកចូលរួមសវនាការវិញនៅថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥០ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*